ត្បូងឃ្មុំ

ខេត្តថ្មីលើធីកដីចាស់



ផ្សព្វផ្សាយដោយ

សាលាខេត្តត្បូងឃ្មុំ

២០១៧

ត្បូងឃ្មុំ៖ ខេត្តថ្មីលើទឹកដីចាស់

អារម្ភកថា

សេចក្តីផ្តើម

ជំពូកទី១

ទឹកដី និង មនុស្ស

១. ទឹកដី

- ១.១. ភូមិសាស្ត្រ
- ១.២. សណ្ឋានដី
- ១.៣. បរិស្ថាន

២. មនុស្ស

- ២.១. ស្ថិតិប្រជាជន
- ២.២. ជាតិសាសន៍
- ២.៣. មុខរបរ
- ២.៤. ជំនឿ សាសនា និងទំនៀមទម្លាប់

ជំពូកទី២

តឹកតាងប្រវត្តិសាស្ត្រ

១. ស្ថានីយបុរាណ

- **១.១. សម័យបុរេប្រវត្តិសាស្ត្រ**
  - ក. ស្ថានីយភូមិមូល ឬបន្ទាយគូ
  - ខ. ស្ថានីយទីទួល
- **១. ២. សម័យប្រវត្តិសាស្ត្រ**

ក. សម័យមុនអង្គរ
ខ. សម័យអង្គរ
គ. សម័យក្រោយអង្គរ

២. អក្សរសិល្ប៍, រឿងព្រេងទាក់ទងនឹងឈ្មោះខេត្ត

២.១. អក្សរសិល្ប៍

ក. ហ្លួងព្រះស្តេចកន
ខ. ប្រវត្តិរឿងទុំទាវ

២.២. រឿងព្រេងទាក់ទងនឹងឈ្មោះខេត្ត

ក. រឿងអ្នកតាបេង
ខ. ពិចារណាអំពីឈ្មោះ "ត្បូងឃ្មុំ"
គ. ពិធីទ្បើងអ្នកតាបេង ឬហ៊ីរចៅហ្វាយស្រុក

ជំពូកទី៣

១. សាវតារនៃខេត្តត្បូងឃ្មុំ

១.១. ឯកសារជាភាសាខ្មែរ
១.២. ឯកសារជាភាសាបរទេស

២. ការប្រែក្លាយដែនដីត្បូងឃ្មុំ២ឆ្នាំទៅខេត្តឡើងវិញ

២.១. បុរីរដ្ឋបាលសាលាខេត្ត

២. ២. និមិត្តសញ្ញាខេត្ត

ឯកសារពិគ្រោះ

អារម្ភកថា

សៀវភៅ **ត្បូងឃ្មុំ៖ ខេត្តថ្មីលើទឹកដីចាស់** គឺជាសមិទ្ធិផលថ្មីមួយទៀត របស់ខេត្តត្បូងឃ្មុំ បន្ទាប់ពីខេត្តនេះត្រូវបានបង្កើតឡើងវិញជាផ្លូវការតាមព្រះរាជក្រឹត្យលេខ នស១៤៤៥/១២១៣/រកត ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៤ ដោយបំបែកចេញពីខេត្តកំពង់ចាម។ ការចងក្រងសៀវភៅនេះឡើងមានគោលបំណងសំខាន់ពីរយ៉ាង៖

ទី១. ដើម្បីចូលរួមអបអរសាទរពិធីដាក់សម្ពោធឲ្យដំណើរការជាផ្លូវការនូវបុរីរដ្ឋបាលប្រមូលផ្តុំរបស់ខេត្តត្បូងឃ្មុំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ដែលនឹងប្រព្រឹត្តទៅនាដំណាច់ខែឧសភា ឆ្នាំ២០១៧។

ទី២. ដើម្បីជាជំនួយស្មារតីសម្រាប់ស្វែងយល់ពីប្រវត្តិនៃឈ្មោះខេត្ត ភូមិសាស្ត្រ ប្រវត្តិសាស្ត្រ បុរាណវិទ្យា រឿងព្រេងនិទាននិងព្រឹត្តិការណ៍សំខាន់ៗកើតមានតាំងពីអតីតកាលរហូតមកដល់បច្ចុប្បន្ន។ ទន្ទឹមនឹងនេះក៏បង្ហាញអំពីកាលប្បវត្តិរបស់ខេត្ត បរិស្ថាន ប្រជាជន ហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងសក្តានុពលសេដ្ឋកិច្ចនៅក្នុងខេត្ត។ លើសពីនេះទៅទៀត ក៏ជាវិភាគទានក្នុងការរួមចំណែកលើកកម្ពស់ចំណេះដឹង ដល់សាធារណជន ពិសេសស្រទាប់យុវជន ឲ្យបានយល់ជ្រួតជ្រាបអំពីតម្លៃនិងសារៈសំខាន់នៃមរតកវប្បធម៌ជាតិទាំងរូបីនិងអរូបី ដែលជាអត្តសញ្ញាណនិងដួងព្រលឹងជាតិ ហើយចូលរួមថែរក្សា ការពារឲ្យបានគង់វង្សយូរអង្វែងសម្រាប់មនុស្សជំនាន់ក្រោយ។

យោងតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវបង្ហាញឲ្យឃើញថា នៅលើដែនដីនៃខេត្តត្បូងឃ្មុំគឺមានភស្តុតាងបញ្ជាក់ពីការរស់នៅរបស់មនុស្សប្រមូលផ្តុំជាសហគមន៍ តាំងពីសម័យបុរេប្រវត្តិសាស្ត្រមកម្ល៉េះ។ មកដល់សម័យអង្គរ ទឹកដីត្បូងឃ្មុំ គឺជារាជធានីដំបូងរបស់ព្រះបាទជ័យវរ្មន់ទី២ មានឈ្មោះថា «ឥន្ទ្របុរ» នៅសតវត្សន៍ទី៩ លុះក្រោយមកអ្នកស្រុកស្គាល់ថា «បន្ទាយព្រៃនគរ» ជារាជធានីរបស់ហ្លួងព្រះស្តេចកន។ រីឯវិស័យរដ្ឋបាលវិញ ក៏មានប្រវត្តិយូរអង្វែង និងឆ្លងកាត់ការផ្លាស់ប្តូរជាច្រើនដំណាក់កាល ពិសេសក្នុងសម័យអាណាព្យាបាលបារាំង ហើយទីបំផុតក៏ត្រូវបានបង្កើតជាខេត្តឡើងវិញនាពេលសព្វថ្ងៃនេះ។ ឈ្មោះរបស់ខេត្តត្រូវបានគេស្គាល់តាំងពីសម័យលង្វែកឯណោះ ពិសេសតាមរយៈប្រលោមលោកដ៏ល្បីល្បាញគឺរឿងទុំទាវ។ ដើម្បីបានជាពុទ្ធិដល់អ្នកអានទូទៅដែលចាប់អារម្មណ៍ចង់ស្វែងយល់អំពីសាវតារនៃខេត្តថ្មីមួយនេះឲ្យកាន់តែច្បាស់ ទើបរដ្ឋបាលសាលាខេត្តបានផ្តើមគំនិតឲ្យមានការសិក្សាស្រាវជ្រាវប្រមូលពត៌មានមកតាក់តែងបោះពុម្ពជាសៀវភៅ ដោយសហការជាមួយក្រុមអ្នកស្រាវជ្រាវ ដែលមានឯកទេស

ផ្សេងៗដូចជា បុរាណវិទូ ប្រវត្តិវិទូ ស្ថាបត្យករ និងសិល្បករសូនរូប ដែលជាអ្នកមានបទពិសោធន៍ក្នុងការសិក្សាស្រាវជ្រាវក្នុងវិស័យនេះ។

ឆ្លៀតក្នុងឱកាសនេះ ក្នុងនាមរដ្ឋបាលខេត្តត្បូងឃ្មុំ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ និងសូមកោតសសើរដោយស្មោះ ចំពោះក្រុមអ្នកស្រាវជ្រាវទាំងអស់ ដែលបានសហការណ៍យ៉ាងប្រសើរក្នុងការស្រាវជ្រាវប្រមូលពត៌មានមកសិក្សាវិភាគ និងចងក្រងរហូតសម្រេចបានជាសៀវភៅនេះឡើង។

សូមគោរពជូនពរលោក អ្នកទាំងអស់ សូមប្រកបដោយសុខភាពល្អបរិបូរណ៍ កម្លាំងពលំខ្លាំងក្លា បញ្ញាឈ្លាសវៃ ជោគជ័យគ្រប់ការកិច្ច និងទទួលបានព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ធ្វើនៅខេត្តត្បូងឃ្មុំ ថ្ងៃទី..... ខែ..... ឆ្នាំ.....

អភិបាល នៃគណៈអភិបាលខេត្តត្បូងឃ្មុំ

សេចក្តីផ្តើម

ការបង្កើតខេត្តត្បូងឃ្មុំឡើងវិញនាពេលនេះ ពុំមែនជារឿងថ្មីស្រឡាង ហើយក៏វិតតែពុំមែនជាការចៃដន្យដែរ។ តាមពិតទៅឈ្មោះស្រុកឬខេត្តត្បូងឃ្មុំ បានលេចឡើងដំបូងក្នុងសិលាចារឹកសម័យក្រោយអង្គរ(IMA. ៣៧) ចារនៅលើជញ្ជាំងនៃស្លាបខាងជើង រោងទងខាងកើតនៃប្រាសាទអង្គរវត្តរួចទៅហើយ។ សិលាចារឹកនោះចារដោយបុរសម្នាក់ឈ្មោះជយនន្ទនៅឆ្នាំ១៧០១។ ក្នុងសិលាចារឹកដដែលនេះ គឺចារៀបរាប់ពីព្រឹត្តិការណ៍ដែលព្រះរាជាបានតម្លើងបុណ្យសក្តិឲ្យគាត់មានងារជាស្តេចត្រាញ់«**អរជ្ជុន**»ត្រួតត្រាដែនដីខេត្តត្បូងឃ្មុំ។រហូតដល់ដើមសតវត្សទី១៩ ឃើញមានឯកសារមួយចំនួនដូចជាព្រះរាជពង្សាវតារ ស្នាដៃអក្សរសិល្ប៍រឿងទុំទាវ រឿងហ្លួងព្រះស្តេចកន ដែលជារឿងព្រេងនិទានបែបប្រវត្តិសាស្ត្រ ព្រមទាំងឯកសារប្រវត្តិសាស្ត្រជាច្រើនទៀត ទាំងភាសាខ្មែរនិងភាសាបរទេស ហើយភាគច្រើនឯកសារជាភាសាបារាំងសុទ្ធតែបានសរសេររៀបរាប់អំពីឈ្មោះស្រុកឬខេត្តត្បូងឃ្មុំ។ នៅពេលប្រទេសខ្មែរស្ថិតក្រោមរបបអាណាព្យាបាលរបស់បារាំងចន្លោះឆ្នាំ១៨៦៣ ដល់១៩៥៣ ឃើញមានឯកសារដែលសរសេរពីការបង្កើតខេត្ត ស្រុក ខណ្ឌ ឃុំ និងភូមិ។ ជាក់ស្តែងខេត្តកំពង់ចាមបង្កើតនៅថ្ងៃទី១ ខែមករា ឆ្នាំ១៨៨៥ ហើយមន្ត្រីបារាំងម្នាក់ឈ្មោះ ហ្វ្រង់ស័រ បូឌាន់ (François Baudoin) ជាអ្នកត្រួតត្រាពីលើចៅហ្វាយខេត្តខ្មែរ។ ខេត្តកំពង់ចាមកាលណោះមានស្រុកចំនួនដប់ជាចំណុះគឺ៖ ស្រុកកំពង់សៀម, ក្រូចឆ្មារ, ព្រៃឈរ, ជើងព្រៃ, កងមាស, កោះសូទិន, ស្រីសន្ធរ, មេមត់, ស្ទឹងត្រង់និងស្រុកត្បូងឃ្មុំ។ កំណែទម្រង់លើវិស័យរដ្ឋបាលនៅក្នុងរបបអាណាព្យាបាលបារាំង បានធ្វើឡើងជាបន្តបន្ទាប់ពិសេសក្នុងរាជព្រះបាទអង្គឌួង និងព្រះបាទនរោត្តម។ នៅក្នុងឆ្នាំ១៨៩៧ ត្បូងឃ្មុំត្រូវគេតម្លើងពីស្រុកឲ្យទៅជាខេត្ត ដែលកាលណោះមានខេត្តចំនួន៥៧ ប៉ុន្តែពុំមានខេត្តកំពង់ចាមទេ។ លុះដល់ឆ្នាំ១៩១៧ មានការរុះរើ ចំនួនខេត្តម្តងទៀត ដោយបន្ថយពី៥៧ខេត្តមកនៅត្រឹម៥១ខេត្តវិញ ហើយត្បូងឃ្មុំនៅជាខេត្តដដែល។ រហូតដល់ទសវត្ស១៩២០ ក៏មានកំណែទម្រង់រចនាសម្ព័ន្ធវិស័យរដ្ឋបាលជាថ្មីទៀត ហើយនៅពេលនោះរក្សាទុកខេត្តតែ១៣ប៉ុណ្ណោះ ដោយត្បូងឃ្មុំធ្លាប់ជាខេត្តកាលពីមុនមកនោះ ត្រូវប្រែក្លាយឲ្យទៅជាស្រុកមួយរបស់ខេត្តកំពង់ចាមវិញ។ ចាប់តាំងពីពេលនោះមក យើងពុំឃើញមានការផ្លាស់ប្តូរទៀតឡើយ រហូតមកទល់នឹងឆ្នាំ២០១៤ ទើបរាជរដ្ឋាភិបាលកម្ពុជាសម្រេចប្រែក្លាយដីត្បូងឃ្មុំឲ្យទៅជាខេត្តវិញដូចពីអតីតកាលជាង១០០ឆ្នាំមុន។

បើពិនិត្យលើកេរ្តិ៍ដំណែលប្រវត្តិសាស្ត្រវិញឃើញថា នៅលើទឹកដីនៃខេត្តត្បូងឃ្មុំ គឺមានទាំងមរតករូបីនិងអរូបី។ រូបីមានដូចជាបន្ទាយគូឬភូមិមូល ទីបញ្ចុះសព របស់របរប្រើប្រាស់ប្រចាំថ្ងៃ សំណង់សាសនា សំណង់រក្សាទឹកជាដើម ដែលបង្កើតឡើងដោយមនុស្សតាំងពីរាប់ពាន់ឆ្នាំមុន។ រីឯមរតកវប្ផធម៌អរូបីវិញ មានច្រើនទម្រង់ បានបន្តរស់នៅជាមួយប្រជាជន ដូចជាស្នាដៃអក្សរសិល្ប៍ និងរឿងព្រេងនិទានផ្សេងៗ ដែលខ្លះជាប់ទាក់ទងជាមួយកំណើតទឹកដី និងឈ្មោះខេត្ត គឺដក់ជាប់ក្នុងការចងចាំរបស់អ្នកស្រុកនៅ

ឡើយ។ មិនតែប៉ុណ្ណោះគេថែមទាំងបង្កើតឲ្យមានរូបរាងឡើង ហាក់ដូចសាច់រឿងទាំងនោះជារឿងពិតអញ្ចឹង។ ការដែលគេខិតខំប្រឌិតឡើងនេះ ពុំមែនជាការខុសឆ្គងនោះឡើយ ព្រោះអ្វីៗទាំងនោះគឺធ្វើឡើងក្នុងក្របខ័ណ្ឌនៃការគោរពប្រតិបត្តិផង និងជាផ្នែកមួយចូលរួមក្នុងការថែរក្សាមរតកផង។ តាមរយៈឈុតឆាកខ្លះនៃសាច់រឿងទាំងនោះ យើងសង្កេតឃើញថា ភូមិ ឃុំ ស្រុកមួយចំនួន ជាប់ឈ្មោះទៅតាមសាច់រឿង ហើយក្លាយជាឈ្មោះផ្លូវការរហូតដល់សព្វថ្ងៃនេះ។ ដូច្នេះ ខេត្តត្បូងឃ្មុំដែលបង្កើតថ្មីឡើងវិញនាពេលនេះ គឺក្នុងន័យរដ្ឋបាលប៉ុណ្ណោះ ឯទឹកដីវិញគឺពុំមែនថ្មីឡើយ។

ជំពូកទី១

ទឹកដី និង មនុស្ស

១. ទឹកដី

ក. ភូមិសាស្ត្រ

ខេត្តត្បូងឃ្មុំមានទីតាំងស្ថិតនៅត្រើយខាងកើតទន្លេមេគង្គ ភាគអាគ្នេយ៍រាជធានីភ្នំពេញ គិតត្រឹមបុរីរដ្ឋបាលសាលាខេត្តគឺមានចម្ងាយប្រហែល១៧២គីឡូម៉ែត្រ។ ខេត្តនេះមានព្រំប្រទល់ខាងលិចជាប់ទន្លេមេគង្គ (ប្រវែង៧៩គីឡូម៉ែត្រ) ខាងត្បូងជាប់ខេត្តព្រៃវែង ខាងជើងនិងខាងកើតជាប់ខេត្តក្រចេះនិងមួយផ្នែកទៀតនៅភាគខាងកើតជាប់ព្រំដែនជាមួយប្រទេសវៀតណាម(ប្រវែង១៤២,៧គីឡូម៉ែត្រ)។

ត្បូងឃ្មុំ ត្រូវបានរាជរដ្ឋាភិបាលសម្រេចបង្កើតជាខេត្តឡើងវិញនៅឆ្នាំ២០១៤ ដោយបំបែកចេញពីខេត្តកំពង់ចាម ពោលគឺគ្របដណ្ដប់ដែនដីត្រើយខាងកើតទន្លេមេគង្គដែលជាព្រំប្រទល់រវាងខេត្តទាំងពីរ។ ខេត្តត្បូងឃ្មុំសព្វថ្ងៃមានផ្ទៃដីសរុបទំហំ៥២៥០,៥១គីឡូម៉ែត្រក្រឡា ចែកចេញជា៦ស្រុកគឺអូររាំងឪ,តំបែ, ពញ្ញាក្រែក, មេមត់, ក្រូចឆ្មារ និងស្រុកត្បូងឃ្មុំ ដោយចែកជា៦២ឃុំ ស្មើនឹង៨៦៥ភូមិ ហើយមានក្រុងចាស់មួយគឺសួង ដែលមាន២សង្កាត់(រូបលេខ១)។



រូបលេខ១៖ ផែនទីខេត្តត្បូងឃ្មុំ

ខ. សណ្ឋានដី

ផ្នែដ៏មួយភាគធំនៃខេត្តត្បូងឃ្មុំ គឺជាខ្ពង់រាបគ្របដណ្ដប់ដោយដីក្រហមដែលកើតពីបន្ទុះភ្នំភ្លើង។ ជាទូទៅស្ថានភាពដីមានលក្ខណៈខ្ពស់ ទាប ឡើង ចុះ ដែលជាលទ្ធផលនៃចលនាពំនើងផ្ទៃត់របស់ផែនដីកាលពីរាប់លានឆ្នាំមុន[1](រូបលេខ២)។ ពីខ្ពង់រាបមួយទៅខ្ពង់មួយទៀតខណ្ឌដោយជ្រលង ហើយនៅក្នុងជ្រលងនោះមានអូរតូចៗដែលមានទឹកចេញពីក្នុងដីខួប ប្រាំងរស្សា។ អូរខ្លះហូរពីជើងទៅត្បូង ឯខ្លះទៀតហូរពីកើតទៅលិច ស្របទៅតាមស្ថានភាពដី រួចឆ្ពោះទៅរកអូរធំៗឬទៅទន្លេមេគង្គ។ ផ្នែកខ្លះទៀតនៃទឹកដីខេត្តនេះ គឺជាដីដម្រាល និងទំនាបស្ថិតនៅចន្លោះខ្ពង់រាបដីក្រហមនិងនៅតាមដងទន្លេមេគង្គ ដែលជាប្រភេទដីល្អាយខ្សាច់។ តំបន់ទំនាបខ្លះទៀត ពិសេសទំនាបនៅជាប់ដងទន្លេមេគង្គគឺលិចទឹកនៅរដូវរស្សា។ ក្រៅពីនេះ យើងសង្កេតឃើញមានបឹង, ស្ទឹង, អូរ, ត្រពាំង កើតឡើងដោយធម្មជាតិ និងស្រះ, ប្រឡាយ ជាដើមដែលកើតពីការកែច្នៃដោយមនុស្ស។ បើពោលពីតំបន់ដីក្រហមស្ថិតនៅខាងកើតនៃទន្លេមេគង្គ ក្នុងខេត្តត្បូងឃ្មុំគឺផ្តើមចេញពីតំបន់ជប់, ថ្មពេជ្រ, តាប៉ាវ, ពាមជាំង រហូតដល់ក្រែក, មេមត់ ដែលមានរយៈកម្ពស់ចាប់ពី៥០ដល់២០០ម៉ែត្រធៀបនឹងផ្ទៃទឹកសមុទ្រ។ ដីក្រហមតំបន់នេះសម្បូណ៌ដោយជាតិដែកបង្កបានជាថ្មបាយក្រៀម។ ក្រៅពីនោះសម្បូណ៌ ថ្មបាសាល់ដែលកប់នៅក្នុងដីក្រហម[2]។

រូបលេខ២៖ ទិដ្ឋភាពទូទៅនៃខ្ពង់រាបដីក្រហមខេត្តត្បូងឃ្មុំ

[1] JEANS Pierre Carbonnel, 1972: p. 125-129
[2] JEANS Pierre Carbonnel, 1972: p. 125-129

គ. បរិស្ថាន

ខេត្តត្បូងឃ្មុំមានអាកាសធាតុមិនខុសពីខេត្តដទៃទៀតប៉ុន្មានទេ គឺស្ថិតនៅក្នុងតំបន់ត្រូពិក មានអាកាសធាតុក្តៅហើយសើម ដែលជាឥទ្ធិពលរបបខ្យល់មូសុង។ តាមឯកសារចាស់ៗនិងការដំណាលរបស់អ្នកស្រុកចាស់ៗថា តំបន់នេះពីមុនមកសម្បូណ៌ដោយព្រៃក្រាស់មានឈើច្រើនប្រភេទដូចបេង ធ្នង់ កកោះ និងព្រៃឫស្សី ហើយមានសត្វច្រើនប្រភេទ។ ដើមទ.ស.១៩៥០មក តំបន់នេះចាប់ផ្តើមមានការអភិវឌ្ឍដាំដំណាំកៅស៊ូ បានធ្វើឲ្យបរិស្ថានតំបន់នេះត្រូវគ្របដណ្តប់ដោយដំណាំកែច្នៃនិងដំណាំហូបផ្លែផ្សេងៗវិញជាបន្តបន្ទាប់ដោយសារតំបន់នេះមានភ្លៀងធ្លាក់ជោគជាំនារដូវវស្សា គួបផ្សំនឹងផ្ទៃដីមួយភាគធំជាដីក្រហមសម្បូណ៌ដីជាតិ នាំឲ្យមានអំណោយផលល្អសម្រាប់ដំណាំចម្ការផ្សេងៗដែលក្រៅពីកៅស៊ូ មានដូចជា៖ ការ្ហូ, ម្រេច, ដំឡូងមី, សណ្តែកដី, ស្វាយចន្ទី និងរុក្ខជាតិហូបផ្លែមួយចំនួនទៀតរួមមានសាវម៉ាវ, មង្ឃុត, ទុរេន ខ្នុរ ចម្ប៉ាដក់ជាដើម ដែលធ្វើឲ្យតំបន់នោះមានពណ៌តែបងជាប្រចាំ(រូបលេខ៣)។

រូបលេខ៣៖ ចម្ការកៅស៊ូនិងដំឡូងមីនៅមេមត់

បើពិនិត្យឲ្យបានជិតដល់ទៅ តំបន់នេះពុំសម្បូណ៌ស្រូវទេ ដ្បិតផ្ទៃដីស្រែនៅតំបន់នោះពុំមានវិសាលភាពធំធេង បើប្រៀបជាមួយផ្ទៃដីដំណាំចម្ការផ្សេងៗ។ បើទោះបីដូច្នោះក្តី យើងសង្កេតឃើញមានដំណាំស្រូវពីរប្រភេទ ដែលអ្នកស្រុកបន្តធ្វើរហូតមកដល់សព្វថ្ងៃ គឺស្រូវសន្ធូងនិងស្រូវចម្ការ។ ស្រូវសន្ធូង

ធ្វើនៅតាមតំបន់ទំនាប និងជ្រលងនៃខ្ពង់រាបដីក្រហម រីឯស្រូវចម្ការដាំនៅលើខ្នងទួល ឬតាមជម្រាលនៃខ្ពង់រាប។

២. មនុស្ស

ក. ស្ថិតិប្រជាជន

ប្រជាជនភាគច្រើនរស់នៅក្នុងខេត្តត្បូងឃ្មុំសព្វថ្ងៃ គឺជាអ្នកចំណូលស្រុក ដែលមកពីតំបន់ផ្សេងៗ តាំងពីសម័យអាណាព្យាបាលបារាំងមកម្ល៉េះ ក្រៅពីខ្មែរមានដូចជាចិន, ចាម, វៀតណាម រីឯជនជាតិដើមភាគតិចក៏មានរស់នៅក្នុងខេត្តនេះដែរ។ ប្រជាជនខ្លះត្រូវគេបញ្ជូនទៅរស់នៅធ្វើជាកម្មករចម្ការកៅស៊ូ ពិសេសសម័យអាណាព្យាបាលបារាំង និងខ្លះទៀតចូលទៅរស់នៅដោយស្ម័គ្រចិត្ត ដើម្បីប្រកបរបរជាអ្នកចម្ការ នេសាទ ជំនួញ អ្នករាជការ និងកម្មករចម្ការកៅស៊ូ។

គិតត្រឹមឆ្នាំ២០១៥ ប្រជាជនដែលកំពុងរស់នៅលើទឹកដីខេត្តត្បូង មានចំនួន១៨៥ ៨៥០គ្រួសារ និងសមាជិកសរុបប្រហែល៨៤៤.៨៥៣នាក់ ក្នុងនោះ ប្រុសមានចំនួន៤១៦.០២១នាក់ និងស្រីមានចំនួន៤២៨ ៨៣២នាក់។ តំបន់ដែលមានដង់ស៊ីតេប្រជាជនខ្ពស់ គឺនៅតាមទំនាបទន្លេមេគង្គ និងទីប្រជុំជនតាមបណ្តាស្រុកនានា ដូចជាក្រុងសួងជាដើម។ ដង់ស៊ីតេប្រជាជនគិតជាមធ្យមមានចំនួនប្រហែល ១៤១,៦នាក់ក្នុងមួយគីឡូម៉ែត្រក្រឡា[3]។

ខ. ជាតិសាសន៍

ក្នុងចំណោមប្រជាជនដែលកំពុងរស់នៅលើទឹកដីខ្មែរសព្វថ្ងៃ គឺមានជាតិសាសន៍ផ្សេងៗរស់នៅលាយឡំជាមួយខ្មែរដែលជាម្ចាស់ស្រុក ហើយមានច្រើនជាងគេ ម្ល៉ោះហើយទើបសង្កេតឃើញខ្មែររស់នៅគ្រប់ច្រកល្ហកក្នុងខេត្តទាំងមូល។ សាសន៍ទាំងនោះរួមមានសហគមន៍ជនជាតិដើមភាគតិច អ្នកចំណូលស្រុកដែលមករស់នៅប្រទេសខ្មែរជាប់លាប់ និងអ្នកចំណូលស្រុកដែលមករស់នៅមិនស្ថិតស្ថេរ។ នៅក្នុងខេត្តត្បូងឃ្មុំ ក៏មិនខុសពីខេត្តដទៃទៀតដែរ គឺមានសាសន៍ផ្សេងៗរស់នៅខ្លះជាប់លាប់និងខ្លះទៀតស្នាក់នៅបណ្តោះអាសន្ន។ បើយោងលើលិខិតលេខ៣៧៦ ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩០៤ របស់ឧកញ្ញា អរជូន ចៅហ្វាយស្រុក/ខេត្តត្បូងឃ្មុំ ជម្រាបទៅលោកវ៉ូស៊ីដង់បារាំង កាលជំនាន់នោះ គឺក្នុងខេត្តត្បូងឃ្មុំ មានជន

[3] ស្ថិតិមន្ទីរធម្មការនិងសាសនាខេត្តត្បូងឃ្មុំ ឆ្នាំ២០១៦

ជាតិស្ទៀង ព្នង និងតួន (ទំពូន) រស់នៅ។ ស្ទៀងមានចំនួន៥៤៧នាក់ ព្នង៣៩៤នាក់ និងទំពូន១១៩នាក់ សរុបទាំងអស់១០៦០នាក់[4](រូបលេខ៤)។



រូបលេខ៤៖ លិខិតរបស់ឧកញ្ញាអរជួន ចៅហ្វាយខេត្តត្បូងឃ្មុំជម្រាបជូនលោកអ៊ីស៊ីដង់ បារ៉ាង អំពីចំនួនជនជាតិដើមភាគតិចរស់នៅក្នុងដែនដីរបស់ខ្លួន(ប្រភព៖ A. Leclère, 1904)

មកដល់សព្វថ្ងៃ ជនជាតិដើមភាគតិចដែលរៀបរាប់ខាងលើនោះ ឃើញនៅសល់តែជនជាតិស្ទៀងមួយចំនួនតូចប៉ុណ្ណោះ បន្តរស់នៅតាមភូមិមួយចំនួនឆ្ងាយពីទីប្រជុំជននៃខេត្តនេះ ដូចជាភូមិកន្ធ្ត, ទួល

[4] ADHÉMARD Leclère, 1904

ក្រួស, កោះថ្ម, ដើ, សាទុំនិងភូមិជ្រៃជាដើម(រូបលេខ៥)។ សព្វថ្ងៃជនជាតិស្ទៀងទាំងនោះ លែងប្រតិបត្តិទំនៀមទម្លាប់និងប្រពៃណីបុរាណរបស់ខ្លួនខ្ជាប់ខ្ជួនដូចពីដើមទៀតឡើយ។ សូម្បីតែភាសាក៏ភ្លេចស្ទើរគ្មានសល់ មានតែចាស់ៗមួយចំនួនតូចប៉ុណ្ណោះ ដែលនៅចេះចាំអាចនិយាយបាន តែមិនប្រើសម្រាប់ប្រាស្រ័យទាក់ទងប្រចាំថ្ងៃនោះទេ លើកលែងតែក្នុងកិច្ចពិធីទើបគេប្រើ។ ពីដើមគេនាំគ្នាធ្វើចម្ការព្រៃដុតដូចជនជាតិដើមភាគតិចរស់នៅតំបន់ខ្ពង់រាបភាគឦសានដូច្នោះដែរ។ ប៉ុន្តែសព្វថ្ងៃ ទម្លាប់ធ្វើចម្ការបែបនោះកំពុងបាត់បង់ជាបណ្តើរៗ ហើយអាចនឹងបាត់បង់ទាំងស្រុងក្នុងពេលដ៏ខ្លី ដោយសារវឌ្ឍនភាពនៃសង្គមនិងកត្តាធម្មជាតិ។ ចំណែកក្មេងៗជំនាន់ក្រោយវិញ ពួកគេបានចាប់យករបៀបរបបរស់នៅថ្មីតាមបែបសម័យទំនើប។ មិនតែប៉ុណ្ណោះ គេថែមទាំងមិនហ៊ានប្រាប់ថាខ្លួនគេជាជនជាតិស្ទៀងទៀតផង ដ្បិតយល់ថានាំឲ្យខ្មាស់គេ។

រូបលេខ៥៖ ផ្ទះប្រក់ស្លឹងទ្រាំងរបស់ជនជាតិស្ទៀងនៅភូមិកោះថ្ម

ក្រៅពីជនជាតិដើមភាគតិច ក៏មានជនជាតិផ្សេងៗចូលមករស់នៅតាមតំបន់នានាក្នុងខេត្តដូចជាចាម,ចិននិងវៀតណាម។ ចាមច្រើនរស់នៅតាមភូមិក្បែរមាត់ទន្លេ និងភូមិនៅតាមបណ្តោយផ្លូវជាតិ

សំខាន់ៗ ព្រមទាំងភូមិដទៃទៀតនៅក្បែរទីប្រជុំជន។ ចំណែកកូនចៅចិននិងវៀតណាមភាគច្រើនរស់នៅប្រមូលផ្តុំតាមផ្សារក្នុងក្រុង តាមទីរួមស្រុក និងតាមទីប្រជុំជននានាក្នុងខេត្ត។

គ. មុខរបរ

ការប្រកបរបរចិញ្ចឹមជីវិតរបស់មនុស្សម្នាក់ៗមិនដូចគ្នាទេ គឺអាស្រ័យលើលទ្ធភាព សមត្ថភាព ធនធាន និងទីកន្លែងដែលគេរស់នៅ។ ក្នុងខេត្តត្បូងឃ្មុំមានស្ថានភាពភូមិសាស្ត្រផ្សេងៗគ្នា ដូចជាទំនាបទន្លេមេគង្គ ខ្ពង់រាបដីក្រហម ទីក្រុងនិងទីប្រជុំជននានា។ អ្នករស់នៅតាមទំនាបទន្លេមេគង្គ ភាគច្រើនប្រកបរបរធ្វើស្រែ ចម្ការ និងនេសាទ។ ចំណែកអ្នករស់នៅតំបន់ខ្ពង់រាបដីក្រហមច្រើនជាអ្នកចម្ការ រួមជាមួយរបរបន្ទាប់បន្សំផ្សេងៗ។ រីឯអ្នករស់នៅតាមទីប្រជុំជនធំៗភាគច្រើនជាអាជីវករ, ពាណិជ្ជករ, មន្ត្រីរាជការ ខ្លះទៀតបម្រើការនៅតាមគ្រឹះស្ថានឯកជននានា ព្រមទាំងអង្គការក្រៅរដ្ឋាភិបាលដែលមានស្នាក់ការក្នុងមូលដ្ឋានរបស់ខ្លួន។ សព្វថ្ងៃ មានក្រុមហ៊ុនឯកជនមកពីបរទេសមួយចំនួន បានចូលមកបណ្តាក់ទុនរកស៊ីលើវិស័យផ្សេងៗជាច្រើន ហើយបានស្រូបទាញកម្លាំងពលកម្មក្នុងស្រុករាប់ពាន់នាក់។ ក្រៅពីធ្វើការក្នុងខេត្ត ក៏មានគ្រួសារខ្លះអនុញ្ញាតឲ្យកូនចៅធ្វើចំណាកស្រុកទៅប្រកបធ្វើការនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តមួយចំនួនដូចជាកណ្តាល កំពង់ចាម ស្វាយរៀង កំពង់ស្ពឺជាដើម។ ក្រៅពីនេះ ក៏មានសមាជិកគ្រួសារផ្សេងទៀតបានធ្វើចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេស ដែលជាចរន្តមួយកើតមាននៅទូទាំងប្រទេសនាពេលសព្វថ្ងៃ។

ឃ. ជំនឿ សាសនា និងទំនៀមទម្លាប់

នៅក្នុងប្រវត្តិរបស់ខ្លួន ខ្មែរបានទទួលឥទ្ធិពលសាសនាពីឥណ្ឌាទាំងព្រហ្មញ្ញសាសនាផងនិងព្រះពុទ្ធសាសនាផង។ សាសនាទាំងពីរបានហូរចូលមកក្នុងដែនដីខ្មែរ យ៉ាងហោចណាស់ក៏ចាប់ពីរវាងស.វ.ទី៣មកដែរ។ សាសនាទាំងពីរបានជ្រួតជ្រាបក្នុងសង្គមខ្មែរគ្រប់ស្រទាប់វណ្ណៈរហូតមកដល់ចុងសម័យអង្គរនាស.វ.ទី១៤។ នៅចុងសម័យអង្គរប្រទេសខ្មែរបានទទួលឥទ្ធិពលព្រះពុទ្ធសាសនាថ្មីមួយផ្សេងទៀត គឺពុទ្ធសាសនាថេរវាទ ដែលមានមណ្ឌលនៅប្រទេសស្រីលង្កា ហើយហូរចូលមកប្រទេសមន, ភូមា, សៀម ប្រជាជននៅក្នុងខេត្តត្បូងឃ្មុំទាំងមូលក៏មិនខុសពីប្រជាជននៅតាមបណ្តាខេត្តដទៃទៀតនៅទូទាំងប្រទេស គឺភាគច្រើនជាពុទ្ធសាសនិកជន។ នាពេលបច្ចុប្បន្ននៅក្នុងខេត្តមានវត្តសរុបចំនួន២៤៥ និងមានរហូតមក

ដល់ខ្មែរ។ ដោយសារពុទ្ធសាសនាបានគ្របដណ្ដប់និងចាក់ឫសជ្រៅមាំក្នុងសង្គមខ្មែរយូរមកហើយ ទើបរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលកំណត់យកព្រះពុទ្ធសាសនាគឺជាសាសនារបស់រដ្ឋ [5]។

ព្រះសង្ឆចំនួន២៨៥៥អង្គ[6] គង់នៅតាមទីវត្តអារាមទាំងនោះ។ ទីអារាមទាំងឡាយមិនត្រឹមតែជាកន្លែងសម្រាប់ប្រជាជនគោរពប្រតិបត្តិប៉ុណ្ណោះទេ គឺថែមទាំងជាមណ្ឌលអប់រំនិងវប្បធម៌ ផ្ដល់នូវចំណេះដឹងទាំងផ្លូវលោកនិងផ្លូវធម៌ដល់មនុស្សគ្រប់រូប។ ក្រៅពីវត្តព្រះពុទ្ធសាសនាក៏មានវិហារឥស្លាម និងវិហារគ្រិស្តសាសនា នៅតាមភូមិដ្ឋាននិងទីប្រជុំជនមួយចំនួនដែរ។ នៅក្នុងខេត្តទាំងមូលមានវិហារឥស្លាមចំនួន ១៣០កន្លែងនិងវិហារគ្រិស្តសាសនាចំនួន៨កន្លែង[7]។

អ្នកតាគឺជាជំនឿដើមរបស់អ្នកស្រុក ដែលពួកគាត់នាំគ្នាប្រតិបត្តិតាំងពីមិនទាន់មានសាសនាហូរចូលមកម្ល៉េះ។ ក្នុងខេត្តត្បូងឃ្មុំមានអ្នកតាជាច្រើនខ្លះស្ថិតក្នុងបរិវេណទីអារាម ខ្លះទៀតនៅលើទួលក្នុងនិងក្រៅភូមិនិងតាមទីស្ថានដទៃទៀត ក្រោមដើមឈើធំៗ និងនៅតាមដីដំបូកជាដើម។ អ្នកតាខ្លះមានរូបជាតំណាង(រូបលេខ៦) ឯខ្លះទៀតមានតែដំបូកនិងដុំថ្មតែប៉ុណ្ណោះ។

រូបលេខ៦៖ តាប្រាក់និងយាយស នៅភូមិអង្គរក្នុង

[5] មាត្រា៤៣ចែងថា "ប្រជាពលរដ្ឋទាំងពីរភេទ មានសិទ្ធិពេញទីខាងជំនឿ។ សេរីភាពខាងជំនឿ និង ការប្រតិបត្តិខាងផ្លូវសាសនា ត្រូវបានរដ្ឋធានាក្នុងលក្ខខ័ណ្ឌដែលមិនប៉ះពាល់ដល់ជំនឿ ឬ សាសនាដទៃទៀត ដល់សណ្ដាប់ធ្នាប់ និងសន្ដិសុខសាធារណៈ។ ព្រះពុទ្ធសាសនាគឺជាសាសនារបស់រដ្ឋ។

[6] ស្ថិតិមន្ទីរធម្មការនិងសាសនាខេត្តឆ្នាំ២០១៦

[7] ស្ថិតិមន្ទីរធម្មការនិងសាសនាខេត្តត្បូងឃ្មុំ ឆ្នាំ២០១៦

តើអ្នកតាជាអ្វី? អ្នកតាជាអមនុស្សដែលសំខាន់, មានរោងឬទីអ្វីមួយជាសម្គាល់, មានវត្ថុស្នង, មិនតែប៉ុណ្ណោះអាចមានដល់ទៅ"រូប"ជាមនុស្សស្នងសម្រាប់បញ្ជាន់ឆ្លងឆ្លើយនិងអ្នកស្រុកទៀតផង[8] (រូបលេខ ៧)។

រូបទី៧៖ ស្ទឹងកំពុងចូលរូបនៅក្នុងពិធីឡើងអ្នកតានៅភូមិសាទុំ

យើងអាចពន្យល់បានម្យ៉ាងទៀតថា៖ អ្នកតាជាបុព្វការីជននៃសហគមន៍ជនបទមួយ បើទោះជាមានប្រវត្តិច្បាស់លាស់ក្តី ឬប្រវត្តិនោះប្រឌិតឡើងក្តី តែត្រូវបានអ្នកផងទាំងពួងនាំគ្នាជឿនិងគោរពប្រតិបត្តិតៗគ្នារហូតមក។ អ្នកតាគឺជាវរជនម្នាក់ដែលបានទៅកាប់ឆ្ការព្រៃទីកន្លែងណាដំបូងគេ ហើយទប់ទល់នឹងខ្មោចព្រៃ ព្រមទាំងជម្នះការចាញ់ទឹកដីនៅទីនោះបាន។ គាត់ជាអ្នកដែលបានប្រែក្លាយព្រៃមួយកន្លែង ឲ្យទៅជាភូមិ ស្រុក ធ្វើឲ្យតំបន់មួយដែលជាព្រៃរហោស្ថាន ហើយពោពេញទៅដោយឧបទ្រពចង្រៃ ឲ្យក្លាយទៅជាភូមិការប្រកបដោយសេចក្តីសុខ បរិបូរដោយភោគផល។ ជនទីមួយនោះហើយ ដែលទាក់ទាញជនដទៃទៀតឲ្យមកពង្រីកសហគមន៍នោះកាន់តែធំឡើងៗ ឲ្យមានអារ្យធម៌មានទីអារាម។ល។ នៅក្នុងខេត្តត្បូងឃ្មុំមានអ្នកតាមួយកន្លែងស្ថិតនៅមិនឆ្ងាយប៉ុន្មានពីទីប្រជុំជនសួង ដែលល្បីល្បាញជាងគេក្នុងតំបន់នោះ ហើយអ្នកស្រុកនាំគេហៅថា «**អ្នកតាបេង**»។ ពត៌មានអំពីប្រវត្តិអ្នកតានេះ នឹងមានបរិយាយពិស្តារនៅក្នុងជំពូកទី២។

[8] អាំង ជូលាន, មនុស្សនិងដី ខែមីនា ឆ្នាំ២០០០

ក្រៅពីពិធីបុណ្យធំៗដែលជាទំនៀមទម្លាប់ ប្រពៃណីជាតិដូចជាចូលឆ្នាំថ្មី, ភ្ជុំបិណ្ឌ, អុំទូក, អកអំបុក, សំពះព្រះខែ, មាឃបូជា, វិសាកបូជា, ចូលព្រះវស្សា, ចេញព្រះវស្សា, កឋិនទាន គឺនៅមានបុណ្យផ្សេងៗទៀត ដែលអ្នកស្រុកតែងប្រារព្ធនៅតាមភូមិនានាទៅតាមទំនៀមទម្លាប់ និងប្រពៃណីដូចជាពិធីឡើងអ្នកតា, បុណ្យដារលាន, បុណ្យកម្សាន្តភូមិ ព្រមទាំងបុណ្យដទៃទៀត ទាក់ទងនឹងព្រះពុទ្ធសាសនា។ បុណ្យទាំងអស់នេះធ្វើឡើងក្នុងគោលបំណងដូចគ្នា គឺសុំសេចក្ដីសុខ និងភាពសម្បូណ៌សប្បាយដល់សមាជិកក្នុងភូមិ និងក្រុមគ្រួសារ គ្រាន់តែការរៀបចំកិច្ចពិធីខ្លះដូចគ្នា ខ្លះទៀតប្រហាក់ប្រហែលគ្នា ឬខុសគ្នាទាំងស្រុងអាស្រ័យទៅតាមទំនៀមនៃតំបន់នីមួយៗ។ ដូចជាអ្នករស់នៅតាមជងទន្លេ ប្រារព្ធពិធីតាមរបៀបអ្នកទន្លេ អ្នករស់នៅតាមតំបន់ខ្ពង់រាបរៀបចំពិធីតាមរបៀបអ្នកខ្ពង់រាប ស្របតាមបរិបទនិងបរិស្ថានរស់នៅរបស់សហគមន៍រៀងៗខ្លួន។

ជំពូកទី២
តឹកតាងប្រវត្តិសាស្ត្រ

១. ស្ថានីយបុរាណ

ផ្អែកលើកស្តុតាងនានាដែលនៅសេសសល់ លើទឹកដីខេត្តត្បូងឃ្មុំ អាចបញ្ជាក់ច្បាស់ថា ខេត្តមួយនេះ ក៏មិនខុសប្លែកពីបណ្តាខេត្តផ្សេងៗទៀត នៃព្រះរាជាណាចក្រកម្ពុជានោះទេ គឺបានបង្ហាញឲ្យឃើញនិងឆ្លុះបញ្ចាំងពីខឿនអារ្យធម៌ចាស់ និងច្រើនប្លែកៗចាប់តាំងពីសម័យបុរេប្រវត្តិសាស្ត្រ រហូតដល់សម័យក្រោយៗមកទៀត។ សំណល់បុរាណវត្ថុទាំងនោះ បានក្លាយជាមរតកវប្បធម៌ជាតិយ៉ាងសំខាន់ ប្រកបដោយសក្តានុពល សម្រាប់ការសិក្សាស្រាវជ្រាវខាងវិស័យបុរាណវិទ្យា ប្រវត្តិសាស្ត្រ សិល្បៈ សាសនា ហើយក៏ជាគោលដៅទេសចរណ៍ដ៏ទាក់ទាញផងដែរ។

១.១. សម័យបុរេប្រវត្តិសាស្ត្រ

បុរេប្រវត្តិសាស្ត្រជាសម័យដែលពុំទាន់មានសំណេរជាអក្សរប្រើប្រាស់សម្រាប់កត់ត្រានិងប្រាស្រ័យទាក់ទងជាផ្លូវការក្នុងសង្គមមនុស្សនៅឡើយ។ កាលពីសម័យនោះមនុស្សអាចទាក់ទងគ្នាបានតាមរយៈភាសា កាយវិការ និងសញ្ញាសម្គាល់ផ្សេងៗប្រចាំក្រុមនីមួយៗ។ សម័យបុរេប្រវត្តិសាស្ត្រនៅតាមតំបន់នីមួយៗនៃពិភពលោកគឺពុំដូចគ្នាទេ។ រីឯទម្រង់និងរចនាសម្ព័ន្ធនៃស្ថានីយក៏ពុំដូចគ្នាទាំងអស់ដែរ។ ជាក់ស្តែងនៅតំបន់ខ្ពង់រាបដីក្រហមនៃខេត្តត្បូងឃ្មុំ មានស្ថានីយបុរេប្រវត្តិសាស្ត្របីប្រភេទខុសគ្នាគឺស្ថានីយបន្ទាយគូឬភូមិមូល ស្ថានីយបញ្ចុះសព និងស្ថានីយមានសណ្ឋានជាបណ្តុំនៃទួល។

- ស្ថានីយបន្ទាយគូឬភូមិមូល៖

អ្វីទៅជាបន្ទាយគូឬភូមិមូល? គឺជាកន្លែងរស់នៅរបស់មនុស្សសម័យបុរេប្រវត្តិសាស្ត្រ យ៉ាងហោចណាស់ក៏ចាប់តាំងពីយុគថ្មរំលីង រហូតមកដល់ចុងយុគលោហៈដែរ។ ពាក្យ "**ភូមិមូល**" គឺអ្នកស្រាវជ្រាវខ្មែរប្រែមកពីភាសាបរទេស ដែលភាសាអង់គ្លេសគេសរសេរថា Circular Earthwork ឯភាសាបារាំងវិញគេសរសេរថា Circular en terre ។

ចំពោះអ្នកស្រុករស់នៅក្បែរស្ថានីយភូមិមូលទាំងនោះ ហៅសំណង់ដីរាងមូលថា"បន្ទាយគូ"ឬ"គូ"។ ព្រោះគេពន្យល់ថា"បន្ទាយគូ" ជាកំពែងការពារក្នុងពេលសង្គ្រាម ឬអាចជាមូលដ្ឋានទ័ពកាលពីសម័យសង្គ្រាមឥណ្ឌូចិន(រូបទី៨-៩)។

រូបលេខ៨៖ ស្ថានីយភូមិមូលឬបន្ទាយគូមើលពីអាកាស (ប្រភពរូប៖ Kyle Lartinis)

រូបលេខ៩៖ កំពែងដីនិងគូនៃស្ថានីយបន្ទាយគូមួយនៅស្រុកមេមត់(ប្រភពរូប៖ អ៊ុក សុខា)

ស្ថានីយបន្ទាយគូមានលក្ខណៈខុសប្លែកពីស្ថានីយបុរេប្រវត្តិសាស្ត្រដទៃ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ បន្ទាយគូឬភូមិមូល មានសណ្ឋាននិងរចនាសម្ព័ន្ធដូចតទៅ៖ មានកំពែងដីព័ទ្ធជុំវិញនិងមានគូទឹកព័ទ្ធជុំវិញផ្នែកខាងក្នុង ព្រមទាំងមានផ្ទៃរាបនៅកណ្តាល។ ផ្ទៃរាបនៅកណ្តាលទាបជាងផ្ទៃដីជុំវិញផ្នែកខាងក្រៅកំពែង។ បន្ទាយគូឬភូមិមូលនីមួយៗជាទូទៅមានអង្កត់ផ្ចិតចន្លោះពី១៥០ទៅ៣៥០ម៉ែត្រ លើកលែងតែបន្ទាយគូមួយនៅភូមិត្របែក មិនឆ្ងាយប៉ុន្មានពីសាលាស្រុកមេមត់ មានអង្កត់ផ្ចិតរហូតដល់ជាង៤០០ម៉ែត្រ។ ស្ថានីយបន្ទាយគូភាគច្រើនមានច្រកចេញចូលពីរស្ថិតនៅទល់មុខគ្នា ដោយច្រកមួយសំដៅឆ្ពោះទៅរកប្រភពទឹកដែលនៅជិតៗនោះ ដូចជាអូរឬប្រឡាយធម្មជាតិជាដើម។ ឯកច្រកមួយទៀតប្រហែលចេញទៅទីផ្សេងៗ។ កំពែងដីបន្ទាយគូមានកម្ពស់ចាប់ពី១,៥០ទៅ៣ម៉ែត្រ ប៉ុន្តែកន្លែងខ្លះនៃបន្ទាយអាចសល់ខ្ពស់ជាងនេះក៏មាន ទាបជាងនេះក៏មាន។ កំពែងទាំងនេះសឹករេចរឹលដោយធម្មជាតិ និងដោយមនុស្ស។ កំពែងដីមានទទឹងមធ្យមពី២០ទៅ២៥ម៉ែត្រ។ ចំណែកគូដែលព័ទ្ធពីខាងក្នុងមានជម្រៅចាប់ពី១ម៉ែត្រទៅ២ម៉ែត្រ ទាបជាងផ្ទៃរាបខាងក្នុង និងផ្ទៃដីខាងក្រៅ ហើយមានទទឹងប្រហាក់ប្រហែលនឹងទទឹងនៃកំពែងដីដែរ។

ស្ថានីយបន្ទាយគូ មានតែនៅតំបន់ខ្ពង់រាបដីក្រហមប៉ែកខាងកើតទន្លេមេគង្គក្នុងខេត្តត្បូងឃ្មុំ និងស្រុកស្ទឹងខេត្តក្រចេះ ព្រមទាំងនៅខ្ពង់រាបដីក្រហមផ្នែកខាងត្បូងនៃប្រទេសវៀតណាមប៉ុណ្ណោះ។ រហូតមកដល់សព្វថ្ងៃនេះ ក្រុមស្រាវជ្រាវនៃមជ្ឈមណ្ឌលបុរាណវិទ្យាមេមត់នៃក្រសួងវប្ផធម៌និងវិចិត្រសិល្ប: បានស្រាវជ្រាវនិងចុះបញ្ជីស្ថានីយបន្ទាយគូ បានចំនួន៣៧កន្លែង ក្នុងនោះ១កន្លែងស្ថិតក្នុងចម្ការកៅស៊ូ ៣មជាំងនៃស្រុកអូររាំងឪ, ៥កន្លែងស្ថិតក្នុងស្រុកពញាក្រែក, ២៦កន្លែងស្ថិតក្នុងស្រុកមេមត់នៃខេត្តត្បូងឃ្មុំនិង៥កន្លែងទៀតស្ថិតក្នុងស្រុកស្ទឹងខេត្តក្រចេះ។ ដោយឡែកនៅវៀតណាមឯណោះវិញ មានស្ថានីយបន្ទាយគូចំនួន១៩ ដែលនៅតាមជាយដែនជាប់នឹងកម្ពុជាក៏បានចុះបញ្ជីសារពើភណ្ឌជាបេតិកភណ្ឌជាតិរបស់ប្រទេសគេដែរ(រូបលេខ១០)។



រូបលេខ១០៖ ទីតាំងស្ថានីយបន្ទាយគូនៅកម្ពុជានិងវៀតណាម (កែសម្រួលពី៖ Haidle et al. 2014)

កំណាយស្រាវជ្រាវនៅតាមស្ថានីយបន្ទាយគូមួយចំនួនតាំងពីទសវត្ស១៩៦០មកគេបានរកឃើញឧបករណ៍ប្រើប្រាស់ប្រចាំថ្ងៃជាច្រើន ដូចជាពូថៅថ្មរំលីង, កុលាលភាជន៍, ថ្មសំលៀង, បំណែកភាជន៍, ខ្នារអំបោះ, គ្រាប់លុញ, កូនក្លឹងប្រើសម្រាប់ផលិតភាជន៍, កងដៃថ្ម, អង្ការ៉ាថ្ម និងបំណែកកងដៃធ្វើពីកែវ ព្រម

ទាំងវត្ថុផ្សេងៗទៀត[9](រូបលេខ១១-១២)។ផ្អែកលើរចនាសម្ព័ន្ធនៃបន្ទាយគូនិងសំណល់វត្ថុប្រើប្រាស់ប្រចាំថ្ងៃដែលបានរកឃើញអាចឲ្យយើងសន្និដ្ឋានបានថា សហគមន៍មនុស្សរស់នៅក្នុងបន្ទាយគូ គឺជាក្រុមដែលមានវប្ផធម៌លូតលាស់ មានគំនិតច្នៃប្រឌិតខ្ពស់អំពីសុវត្ថិភាពការរស់នៅ មានរចនាសម្ព័ន្ធដឹកនាំច្បាស់លាស់ មានការឯកភាពគ្នាល្អនៅក្នុងក្រុម មានទំនាក់ទំនងវិស័យជំនួញនិងវិស័យផ្សេងៗជាមួយសហគមន៍ខាងក្រៅ។ តាមរយៈកស្តុតាងទាំងនេះ បានធ្វើឲ្យលោកបែណាហ្ស៊ីលីព ហ្ស្ហូសលីយេ ជាបុរាណវិទូបារាំងដ៏ល្បីល្បាញ សន្ទតឲ្យឈ្មោះថា "អារ្យធម៌មេមត់" ជាភាសាបារាំងហៅថា «Mimotien» គឺសំដៅ លើវប្ផធម៌របស់ក្រុមមនុស្ស ដែលបានកសាងនិងរស់នៅក្នុងបន្ទាយគូកាលពីសម័យនោះ។

រូបលេខ១១៖ កំណាយនៅស្ថានីយបន្ទាយគូមួយ
ក្នុងចម្ការកៅស៊ូក្រែក កាលពីឆ្នាំ២០០៣
(ប្រភពរូប៖មជ្ឈមណ្ឌលបុរាណវិទ្យាមេមត់)

រូបលេខ១២៖ ជើងពានរកឃើញពីកំណាយនៅស្ថានីយ
បន្ទាយគូក្នុងចម្ការកៅស៊ូក្រែក ហើយបានសម្រេចយកមក
ប្រើជានិម្មិតសញ្ញាខេត្ត
(ប្រភពរូប៖មជ្ឈមណ្ឌលបុរាណវិទ្យាមេមត់)

- ស្ថានីយបញ្ចុះសព៖

មានទីតាំងនៅក្នុងភូមិ១០.ជ ឃុំវ៉ាលម្ហូ ស្រុកពញ្ញាក្រែក ខេត្តត្បូងឃ្មុំ។ ម្ល៉ោះហើយទើបសម្រេចឲ្យឈ្មោះថា "ស្ថានីយភូមិ១០.ជ" គឺហៅតាមឈ្មោះភូមិនោះ។ យើងស្គាល់ទីបញ្ចុះសពស្ថិតក្នុងយុគដែកមួយកន្លែងនេះ ដោយចៃដន្យក្នុងពេលដែលក្រុមហ៊ុនចម្ការកៅស៊ូក្រែក ជីកយកដីក្រួសក្រហមកាលពីឆ្នាំ

[9] ហេង សុផាឌី, រិន ឡៃជ្ជរ, សេង សុនេត្រា, សៀវភៅបញ្ជីសារពើភណ្ឌ និងមគ្គុទេសក៍សារមន្ទីរបុរាណវិទ្យាមេមត់ ខេត្តកំពង់ចាម, ២០១៤

២០០០។ លទ្ធផលនៃការធ្វើកំណាយ ជាបន្តបន្ទាប់តាំងពីឆ្នាំ២០០១ រហូតដល់ឆ្នាំ២០០៨ បានរកឃើញផ្ទះសពជាច្រើន រួមទាំងថ្លាងធំៗចំនួន១៣ ដែលប្រហែលជាផ្ទះសពកូនក្មេង(រូបលេខ១៣-១៤)។ ផ្ទះទាំងអស់ដែលបានរកឃើញនៅស្ថានីយខាងលើគឺពុំមានសល់គ្រោងឆ្អឹងឡើយ ប៉ុន្តែនៅពេលធ្វើការជួសជុលសម្អាតច្រេះនិងស្នឹមដែលគ្របពីលើគ្រឿងអលង្ការ ដូចជាកងដៃសំរឹទ្ធិនិងដែក ក៏ប្រទះឃើញសំណល់ឆ្អឹងខ្លះៗ នៅសេសសល់ជិតជាប់ជាមួយស្នឹមនិងច្រេះនៃវត្ថុមួយចំនួនៗជាមួយគ្នានោះដែរក៏ប្រទះឃើញស្នាមក្រណាត់និងសំណល់ឈើជិតជាប់ជាមួយច្រេះ និងស្នឹមនៃវត្ថុមួយចំនួនទៀតដែរ។

រូបលេខ១៣៖ ផ្ទះសពតម្រៀបដោយបំណែកភាជន៍ និងមានឧបករណ៍ធ្វើពីលោហៈជាសំណែន (ប្រភពរូបៈមជ្ឈមណ្ឌលបុរាណវិទ្យាមេមត់)

រូបលេខ១៥៖ ថ្លាង ប្រហែលជាផ្ទះសពកូនក្មេងរកឃើញនៅស្ថានីយភូមិ១០.៨ (ប្រភពរូបៈមជ្ឈមណ្ឌលបុរាណវិទ្យាមេមត់)

ផ្ទះទាំងនោះភាគច្រើនសុទ្ធតែមានកប់សម្ភារៈប្រើប្រាស់ប្រចាំថ្ងៃទៅជាមួយសព គ្រាន់តែផ្ទះខ្លះមានតិច ខ្លះមានទៀតច្រើន តែក៏មានផ្ទះមួយចំនួនតូចគ្មានអ្វីផ្សេងក្រៅតែពីបំណែកភាជន៍ដែលមានទម្រង់ជាផ្ទះប៉ុណ្ណោះ។ វត្ថុកប់ជាមួយសពរួមមាន៖ កុលាលភាជន៍ច្រើនប្រភេទ ច្រើនទំហំ ខ្លះមានជើងទម្រ ឯខ្លះទៀតពុំមានឡើយ។ គ្រឿងអលង្ការមានដូចជាអង្កាំកែវ អង្កាំថ្ម កងដៃសំរឹទ្ធិមានក្បាច់លម្អប្លែកៗ និងក្រវិលកែវ។ ចំណែកវត្ថុធ្វើពីដែកមានដូចជាកាំបិតស្នៀត កាំបិត លំពែង ជំនីក កងដៃវេញដូចខ្សែ កងដៃត្រួតគ្នាច្រើនជាន់និងកងដៃបន្ទះ។ ក្រៅពីនេះ ក៏មានថាសសំរឹទ្ធចំនួនមួយផងដែរ(រូបលេខ៖១៥-១៦)។ ជាមួយគ្នានោះយើងក៏បានរកឃើញបំណែកស្ពរមហោរធ្លីកមួយចំនួនក្នុងពេលចុះអង្កេតកាលពីឆ្នាំ២០០១។

រូបលេខ១៥៖ អង្កាំកែវ, ក្រវិលកែវនិងអង្កាំថ្មរកឃើញនៅស្ថានីយ ភូមិ១០.៨
(ប្រភពរូប៖ មជ្ឈមណ្ឌលបុរាណវិទ្យាមេមត់)

រូបលេខ១៦៖ ១. កងដៃសំរឹទ្ធមានដៃនៅខាងក្នុង, ២. ថាសសំរឹទ្ធ, ៣.កងដៃដែកមានស្នាមក្រណាត់ជិតជាប់ច្រេះរុំពីក្រៅ, ៤. ផ្លែលំពែងមានសំណល់ក្រណាត់ជិតជាប់ច្រេះរុំពីក្រៅ, ៥. កាំបិតស្នៀតមានសំណល់ឈើជិតជាប់ច្រេះដែក, ៦. ផ្លែជំនីក និង៧. ផ្លែកាំបិត ដែលមានសារធាតុសរីរាង្គរុំពីក្រៅ។
(ប្រភពរូប៖ ហេង សុផានី)

ស្ថានីយបញ្ចុះសពយុគដែកនៅភូមិ១០.៨ គឺមានទំនៀមកប់សពប្រហាក់ប្រហែលជាមួយស្ថានីយបញ្ចុះសពយុគដែកដទៃទៀតដូចជាស្ថានីយព្រហារ និងបិតមាស នៅខេត្តព្រៃវែង និងស្ថានីយភូមិស្នាយ ភូមិសុកី និងគោកទ្រាសក្នុងខេត្តបន្ទាយមានជ័យនិងស្ថានីយមួយចំនួនក្នុងតំបន់អាស៊ីអាគ្នេយ៍ដីគោក។ មិនតែប៉ុណ្ណោះស្ថានីយបញ្ចុះសពមួយនេះប្រហែលមានទំនាក់ទំនងជាមួយអារ្យធម៌ដុងសឺន ដែលមានប្រភពនៅប្រទេសវៀតណាមភាគខាងជើងទៀតផង។

យោងលើលទ្ធផលកំណាយដូចបានបញ្ជាក់ខាងលើ អាចសន្និដ្ឋានបានថាស្ថានីយមួយនេះពិតជាមានតម្លៃនិងអត្ថប្រយោជន៍ធំធេង សម្រាប់វិស័យសិក្សាស្រាវជ្រាវខាងបុរាណវិទ្យា នរវិទ្យា សង្គមវិទ្យា ជំនឿ ទំនៀមទម្លាប់ ប្រពៃណី និងវិស័យពាក់ព័ន្ធសំខាន់ៗ ជាច្រើនទៀតដែលឆ្លុះបញ្ចាំងពីជីវិតប្រចាំថ្ងៃរបស់មនុស្សនាសម័យអតីតកាល។ ម្យ៉ាងទៀត ក៏ជាមរតកវប្ប្ធធម៌ដ៏មានតម្លៃរបស់ជាតិ ជាជង្រុកនៃពត៌មាន សម្រាប់សិក្សាស្វែងយល់អំពីទំនាក់ទំនងសេដ្ឋកិច្ច, ជំនួញ, បច្ចេកវិទ្យានៃការស្មិតនិងផែរលោហៈ

ដើម្បីផលិតជាគ្រឿងអលង្ការ ឧបករណ៍កសិកម្ម និងអាវុធដែលជាកត្តាជំរុញឲ្យសហគមន៍មនុស្សមានការផ្លាស់ប្តូររបត់ជីវិត ហើយកែប្រែសង្គមទាំងមូលឈានឆ្ពោះទៅរកវឌ្ឍនភាពនិងឥទ្ធិពល រហូតក្លាយជារដ្ឋដែលមានរចនាសម្ព័ន្ធដឹកនាំច្បាស់លាស់។ ហេតុនេះ ចាំបាច់ណាស់ត្រូវតែរក្សា ការពារឲ្យបានគង់វង្សស្ថិតស្ថេរតរៀងទៅ។

ចំពោះវត្ថុទាំងឡាយបានមកពីការធ្វើកំណាយទាំងនៅស្ថានីយបន្ទាយគូ និងស្ថានីយបញ្ចុះសពភូមិ១០.៨ មួយភាគធំកំពុងតាំងបង្ហាញនៅក្នុងសារមន្ទីរបុរាណវិទ្យាមេមត់ ស្ថិតក្នុងបរិវេណសាលាស្រុកមេមត់ខេត្តត្បូងឃ្មុំ។ សារមន្ទីរនេះបង្កើតឡើងនៅឆ្នាំ២០០២ ក្រោមកិច្ចសហប្រតិបត្តិការរវាងក្រសួងវប្ប‌ធម៌ និងវិចិត្រសិល្ប: ជាមួយស្ថានទូតអាល្លឺម៉ង់ប្រចាំនៅកម្ពុជា ដោយមានការឧបត្ថម្ភពីអង្គការរបស់អាល្លឺម៉ង់មួយចំនួនដូចជាដេអាអាដេ មូលនិធិ ហិនរិចបូល ព្រមទាំងសប្បុ‌រសជនអាល្លឺម៉ង់មួយចំនួនទៀត។ សព្វថ្ងៃសារមន្ទីរបុរាណវិទ្យាមេមត់កំពុងដើរតួយ៉ាងសំខាន់ក្នុងការចូលរួមចំណែកថែរក្សា ការពារមរតកវប្ប‌ធម៌ជាតិ តាមរយ:ការអប់រំ ផ្សព្វផ្សាយដល់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ពិសេសប្រជាជននិងសិស្សានុសិស្សដែលកំពុងរស់នៅក្នុងតំបន់ដីក្រហម។ ចំណែកវត្ថុមួយភាគតូចកំពុងតាំងបង្ហាញភ្ញៀវនៅក្នុងសារមន្ទីរជាតិភ្នំពេញ។

- ស្ថានីយមានសណ្ឋានជាបណ្តុំនៃទួល

ស្ថានីយមានសណ្ឋានជាបណ្តុំនៃទួលយើងសង្កេតឃើញមានពីរកន្លែងនៅតំបន់ដីក្រហមនៃខេត្តត្បូងឃ្មុំ។ទីមួយស្ថិតនៅក្នុងឃុំព្រះធាតុ ស្រុកអូររាំងឪ ហើយទួលទាំងនោះអ្នកស្រុកហៅថា "ភ្នំអំបែង" និងមួយកន្លែងទៀតស្ថិតនៅក្នុងឃុំថ្មពេជ្រ ស្រុកត្បូងឃ្មុំ ហើយអ្នកស្រុកហៅថា "ទួលអំបែងចេះ"(រូបលេខ៖ ១៧-១៨)។ ទីតាំងនីមួយៗ មានទួលពីប្រាំទៅប្រាំមួយស្ថិតនៅជាប់ៗគ្នា ដោយទួលនីមួយៗមានកម្ពស់ចាប់ពី១ម៉ែត្ររហូតដល់២,៥ម៉ែត្រ ហើយនៅលើទួលទាំងនោះមានសុទ្ធតែអំបែងក្អម ឆ្នាំងនិងមានពូថៅថ្មខ្លះដែរ។

ទួលទាំងអស់នេះរកឃើញនិងសិក្សាជាបឋមដោយលោក ហ្សង់ព្យែ‌រ កាបូណែលនៅក្នុងទសវត្ស១៩៧០ ហើយគាត់ហៅទួលទាំងនោះជាភាសាបរទេសថា "Tumuli" គឺមានន័យថាជាទួលកើតដោយស្នាដៃមនុស្ស ហើយអាចជាទីបញ្ចុះសពផង។ ប៉ុន្តែ‌រហូតទល់ពេលនេះពុំមានការសិក្សាស្រាវជ្រាវស៊ីជម្រៅទៅលើទួលទាំងនោះ ដើម្បីបញ្ជាក់បន្ថែ‌មអំពីមុខងារថាជាកន្លែងអ្វីឲ្យប្រាកដនៅឡើយ។ លោ‌ក‌កាបូណែ‌ល‌ពុ‌ំ‌ប‌ាន‌ដ‌ែ‌ល‌ប‌ាន‌ធ្វ‌ើ‌ក‌ំណ‌ាយ‌ទ‌ាល់‌ត‌ែ‌សោ: ‌គ‌ឺ‌គ‌ាត់‌រ‌ួ‌ម‌ជ‌ាម‌ួ‌យ‌ស‌ហ‌ការ‌ី‌ត្រ‌ាន់‌ត‌ែ‌សិ‌ក្ស‌ាវ‌ិ‌ភ‌ាគ‌ពី‌ស្ថ‌ាន‌ភ‌ាព‌ខ‌ាង‌ក្រ‌ៅ ‌ហ‌ើ‌យ‌ក‌ំណ‌ត់‌អ‌ាយ‌ុ‌ក‌ាល‌លើ‌វ‌ត្ថ‌ុ‌ដ‌ែ‌ល‌ប្រ‌ម‌ូ‌ល‌ប‌ាន‌នៅ‌លើ‌ទ‌ួ‌ល‌ទ‌ាំ‌ង‌នោ‌ះ‌ប‌ុ‌ណ្ណោ‌ះ។ ‌ល‌ទ្ធ‌ផ‌ល‌ប‌ាន‌ម‌ក‌ពី

ការវិភាគឲ្យដឹងថាស្ថានីយដែលជាបណ្តុំនៃទួលទាំងពីរកន្លែងនោះមានអាយុចន្លោះពី១១៥០ឆ្នាំ ដល់២១៣០ឆ្នាំមុនពេលបច្ចុប្បន្ន។ លទ្ធផលនេះបញ្ជាក់ថា ទួលទាំងនោះកើតឡើងដោយស្នាដៃមនុស្ស ស្ថិតនៅចុងយុគដែក ឬក៏ដើមសម័យប្រវត្តិសាស្ត្រ។ ផ្អែកលើបរិមាណនៃបំណែកក្អម ឆ្នាំងដ៏សន្ធឹកសន្ធាប់ នៅលើទួលអាចឲ្យយើងសន្និដ្ឋានបានថាបណ្តុំទួលដែលស្ថិតនៅទីតាំងទាំងពីរខាងលើ ប្រហែលជាកន្លែងស្នាក់អាស្រ័យរបស់មនុស្ស ឬក៏អាចជាកន្លែងផលិតក្អម ឆ្នាំងផងក៏អាចថាបាន។ យ៉ាងណាក៏ដោយ មានតែកាសិក្សាតាមបែបវិទ្យាសាស្ត្រប៉ុណ្ណោះ ទើបអាចបញ្ជាក់ការពិតបាន។ ដូច្នេះ ចាំបាច់ណាស់ត្រូវថែរក្សាវាឲ្យបានគង់វង្ស យូរអង្វែងក្រែងមានឱកាសបានសិក្សាស្រាវជ្រាវដិតដល់ក្នុងពេលអនាគត។

រូបលេខ១៧៖ ទួលអំបែងឬក្ដុំអំបែងនៅស្រុកអូររាំងឪ
(ប្រភពរូប៖ ហេង សុផានី)

រូបលេខ១៨៖ បំណែកកាជន៍នីលើទួលអំបែងឬក្ដុំអំបែង
(ប្រភពរូប៖ ហេង សុផានី)

១.២. សម័យប្រវត្តិសាស្ត្រ

ឯកសារស្រាវជ្រាវតាំងពីពាក់កណ្តាលសតវត្សទី១៩ បានឲ្យដឹងថាសំណល់ស្ថាបត្យកម្មនិងកូមិករបុរាណនានាក្នុងខេត្តត្បូងឃ្មុំ បានកសាងឡើងយ៉ាងហោចណាស់ចាប់ពីចុងសតវត្សទី៦នៃគ្រឹស្តសករាជ។ សំណល់ស្ថាបត្យកម្មទាំងនោះ ភាគច្រើនប្រទះឃើញនៅលើដីទំនាបចន្លោះទន្លេធំនៅផ្នែកខាងលិច និងតំបន់ខ្ពង់រាបដីក្រហមនៅផ្នែកខាងកើត។ ផ្អែកលើការសិក្សាទៅលើប្លង់នៃសំណង់ សិល្ប: និងសិលាចារឹក បានញ៉ាំងឲ្យអ្នកស្រាវជ្រាវបែងចែកសំណង់ស្ថាបត្យកម្មទាំងនោះជាបីសម័យកាលធំៗគឺ សម័យមុនអង្គរ សម័យអង្គរ និងសម័យក្រោយអង្គរឬសម័យកណ្តាល។ សំណង់នៅសម័យមុនអង្គរ និងសម័យអង្គរ ជាទូទៅសាងពីថ្មសម្រាប់គោរពដល់សាសនាហិណ្ឌូផងនិងសាសនាព្រះពុទ្ធផង។ លុះនៅសម័យក្រោយអង្គរ

សំណង់សាសនាដែលកាលពីមុនជាប្រាសាទសាងពីថ្ម បានប្តូមកជាវត្តអារាមសាងពីឈើ ហើយទីអារាមទាំងនោះ ជាកន្លែងមនុស្សរស់នៅ ទាំងព្រះសង្ឆ ទាំងឧបាសកព្រមទាំងជាទីដែលអ្នកស្រុកឆ្លងចេញចូលជាធម្មតា។ សំណង់សាសនានោះ ក៏មានការផ្លាស់ប្តូរជាហូរហែពីសម័យកាលមួយទៅសម័យកាលមួយដែរ។

ក. សម័យមុនអង្គរ

សំណល់បុរាណសម័យមុនអង្គរភាគច្រើនផ្ចុំគ្នានៅតំបន់ដីទំនាបឆ្ងាយពីទន្លេធំ គឺចន្លោះបន្ទាយព្រៃនគរទៅប្រាសាទព្រះធាតុព្រះស្រី ហើយក៏មានសំណង់សង់នៅជាប់តែឯងក្បែរដែទន្លេមេគង្គ(ទន្លេធំ)ដែរ។ សំណង់ខ្លះនៅសល់ប្រាង្គ ខ្លះសល់ត្រឹះឬខឿន ឯខ្លះទៀតនៅសល់តែបំណែកគ្រឿងសំណង់ និងសិលាចារឹក ដែលក្រោយមកគេយកទៅរក្សាទុកនៅទីតាំងផ្សេងៗ។ សំណង់មួយចំនួនសង់ក្នុងសម័យអន្តរកាលរវាងសម័យហ្វូណន និងសម័យចេនឡា ឬភាគខាងដើមបង្អស់នៃសម័យចេនឡា ហើយសំណង់ភាគច្រើនសម្រាប់គោរពបូជាសាសនាព្រាហ្មណ៍។ លោកហ្សក សឺដេស បានកត់សម្គាល់ថាចំពោះសំណង់ស្ថាបត្យកម្មមុនអង្គរ មានពីរគឺសម័យហ្វូណន និងសម័យបុរេអង្គរ[10]។ រីឯប្រាសាទភាគច្រើនសង់នៅភាគកណ្តាលនិងភាគខាងត្បូងប្រទេសហើយកម្រមានកាលបរិច្ឆេទជាក់លាក់ណាស់។ ប្រាង្គប្រាសាទទាំងនោះពុំមានទ្វារបញ្ហោតនិងមានថ្នាក់តូចហើយទាបៗ ព្រមទាំងមានទំហំតូចៗ[11]។ នៅក្នុងប្រាសាទខ្លះមានតម្កល់រូបបដិមាក្នុងសម័យកាលផ្សេងគ្នា។ រីឯសំណង់ប្រាសាទទៀតសោតក៏សង្កេតឃើញមានការកែកុន និងថែទាំឬបន្តគោរពបូជាមិនដាច់អស់រយៈកាលច្រើនជំនាន់។ ឧទាហរណ៍ ដូចជាប្រាសាទព្រះធាតុធំ សង់ក្នុងរាជ្យព្រះបាទភវរ្ម័នទី១ ហើយបានកែកុននិងពង្រីកសំណង់បន្ថែមនៅលើខឿនប្រាសាទចាស់នោះជាបន្តបន្ទាប់ (រូបលេខ៖ ១៩)។

រីឯប្រាសាទព្រះធាតុព្រះស្រីវិញក៏ដូច្នោះដែរ គេបានប្រទះឃើញសិលាចារឹក(K. ១០២)ចារក្នុងសតវត្សទី៦ និយាយពីព្រះបាទឦសានវរ្ម័នទី១យាងមកតំបន់ក្បែរប្រាសាទព្រះធាតុព្រះស្រី ហើយបានធ្វើអំណោយដីធ្លី សត្វក្របី និងអ្នកបម្រើមួយចំនួនដល់តំបន់នេះ។ តាមរយៈសិលាចារឹកនេះ លោក ហ្សក សឺដេស សន្និដ្ឋានថានៅប្រាសាទព្រះធាតុព្រះស្រីប្រហែលមានសំណង់មួយឬពីរសង់មុនប្រាសាទព្រះធាតុព្រះស្រីនេះទៅទៀត។

---

[10] ហ្សក សឺដេស, ដើម្បីយល់កាន់តែច្បាស់អំពីអង្គរ,ប៉ារីស្ត, ១៩៤៧, ៤

[11] ហ្សក សឺដេស, ដើម្បីយល់កាន់តែច្បាស់អំពីអង្គរ,ប៉ារីស្ត, ១៩៤៧, ៥

សំណង់ប្រាសាទនិងសំណល់ស្ថាបត្យកម្មសម័យមុនអង្គរ ដែលនៅសល់រហូតសព្វថ្ងៃ មានដូចជា ប្រាសាទខ្នាយវានសង់នៅសតវត្សទី៦-៧, ប្រាសាទព្រះធាតុសង់នៅឆ្នាំ៦៥៥, ប្រាសាទដំរិល, ប្រាសាទ ព្រះធាតុស្រម, ទួលយាយទេព និងផ្នែរនៅវត្តដូនរតន៍។

រូបលេខ១៩៖ ប្រាង្គទាំងពីរនៃប្រាសាទព្រះធាតុធំ

ខ. សម័យអង្គរ

ស្នាដៃសិល្ប: សំណង់សាសនា ព្រមទាំងសិលាចារឹកដែលនៅសល់នៅលើទឹកដីត្បូងឃ្មុំគឺជាប្រភព ពត៌មានបញ្ជាក់ពី លក្ខណៈពិសេសនៃអារ្យធម៌អង្គរ។ សិលាចារឹកដែលប្រទះឃើញនៅតំបន់នានាក្នុងខេត្ត អនុញ្ញាតឲ្យអ្នកស្រាវជ្រាវយល់ថា ព្រះបាទជ័យវរ្ម័នទី២ បានបង្កើតទីក្រុងមួយឈ្មោះឥន្ទ្របុរ នៅចន្លោះ ចុងសតវត្សទី៨និងដើមសតវត្សទី៩។ អ្នកស្រាវជ្រាវយល់ទៀតថា រាជធានីឥន្ទ្របុរប្រហែលស្ថិតនៅផ្ទុំ បន្ទាយព្រៃនគរ[12]។ ក្នុងរយៈពេលនេះ មានហេតុការណ៍មួយចំនួនកើតឡើង ហើយពុំមែនតែអ្នកសិក្សា ស្រាវជ្រាវទេដែលយល់យ៉ាងនេះ ខ្មែរខ្លួនឯងនៅសតវត្សទី៩ដល់ទី១១ក៏បានចងចាំព្រឹត្តិការណ៍នោះខ្ជាប់ ខ្ជួនដែរ។ ព្រោះថា រវាងបីសតវត្សនោះមានសិលាចារឹកជាច្រើនដែលចារពីសកម្មភាពឡើងសោយរាជ្យ និង រាជធានីដំបូងៗរបស់ព្រះបាទជ័យវរ្ម័នទី២ មុនពេលព្រះអង្គទៅគង់នៅជាអចិន្ត្រៃយ៍នៅតំបន់អង្គរក្នុងខេត្ត សៀមរាប។

[12] George Coedès, 1989, Articles sur le Pays Khmer, Paris, 132

សិលាចារឹកស្តុកកក់ធំ(K.២៣៥)ចារនៅឆ្នាំ១០៥២នៃគ្រឹស្តសករាជបានឲ្យដឹងថានៅចុងសតវត្ស ទី៨ ព្រះបាទជ័យវ៉ារ្មន់ទី២ ដែលជាប់ព្រះញាតិវង្សនឹងស្តេចនៅវ៉ាធបុរ បានយាងមកពីកោះជ្វាទៅសោយ រាជ្យនៅឥន្ទ្របុរ ដែលជាក្រុងដំបូងក្នុងចំណោមក្រុងទាំង៥។ បន្ទាប់មក ព្រះអង្គបានបង្ក្រាបនិងបង្រួប បង្រួមសហគមន៍មនុស្សដែលធ្លាប់តែមិនចុះសម្រុងគ្នាពីមុន ឲ្យស្រុះស្រួលគ្នាឡើងវិញ ព្រមទាំងទឹកដីខ្មែរ ដែលបែកខ្ទេកគ្នាជាតំបន់ឬនគរតូចៗនៅសតវត្សនោះផងឲ្យក្លាយជាទឹកដីតែមួយ។ ក្រោយពីសម្រេចការ បង្រួបបង្រួមក្លាម ព្រះអង្គបានប្តូរក្រុងឆ្ពោះទៅទិសខាងកើត។ ព្រះអង្គបញ្ជារឲ្យគេសាងស្រុកមួយឈ្មោះ កុដិ ទុកឲ្យក្រុមគ្រួសារនៅទីនោះ។ ក្រុងបន្ទាប់នៅហរិហរាល័យ ហើយទៅរៀបចំក្រុងថ្មីមួយទៀតនៅ អមរេន្ទ្របុរ ចុងក្រោយព្រះអង្គបានឡើងទៅសោយរាជ្យនៅមហេន្ទ្របព៌ត(ភ្នំគូលេន)ក្នុងឆ្នាំ៨០២។ រីង ទីតាំងឥន្ទ្របុរវិញ ក៏មិនមែនកសាងឡើងនៅទីរហោស្ថានដែលគ្មានសហគមន៍មនុស្សពីមុនមកនោះទេ។ ជាក់ស្តែង នៅក្បែរបរិវេណឥន្ទ្របុរ គឺមានប្រាសាទព្រះធាតុ សង់នៅឆ្នាំ៦៥៥នៃគ្រឹស្តសករាជ្យ ក្នុងរាជ្យ របស់ព្រះបាទជ័យវ៉ារ្មន់ទី១[13]។ ចំណែកក្នុងបរិវេណបន្ទាយព្រៃនគរវិញ មានប្រាសាទព្រះធាតុធំ ដែលនៅ សល់ប្រាង្គពីរមានលក្ខណៈសិល្បៈខុសគ្នា។ ប្រាង្គតូចខាងត្បូង សង់ក្នុងសម័យអន្តរកាលរវាងសម័យ ហ្វូណន និងសម័យចេនឡា ឬភាគខាងដើមនៃសម័យចេនឡា និងប្រាង្គខាងជើងសង់ក្នុងរាជ្យព្រះបាទ ជ័យវ៉ារ្មន់ទី២។ រីងប្រាសាទព្រះធាតុតូច(ចេតិយ៣)សង់នៅចន្លោះសតវត្សទី៦និងទី៧។ ដូច្នេះ យើង ឃើញថាឥន្ទ្របុរ ឬបន្ទាយព្រៃនគរ គឺកសាងឡើងនៅកន្លែង ដែលមានទីសក្តារៈបូជាស្រាប់ទៅហើយ។

សរុបមក យើងសង្កេតឃើញថាស្ថានីយបុរាណក្នុងសម័យអង្គរមានដូចជា សំណង់សាសនា សំណល់ភូមិដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងសំណង់រក្សាទឹកជាដើម ដែលខ្លះនៅសល់រូបរាង ខ្លះ សល់តែគ្រឹះ និងខ្លះទៀតខូចខាតស្ទើទាំងស្រុង។ សព្វថ្ងៃសំណង់បុរាណក្នុងខេត្តត្បូងឃ្មុំមានចំនួនសរុប ៩៥កន្លែង ក្នុងនោះប្រាសាទសល់រូបរាងមានចំនួន១៨, ទួលប្រាសាទមានចំនួន៥៥, សំណង់រក្សាទឹក ចំនួន១១ និងផ្លូវបុរាណមានមួយខ្សែ(រូបលេខ៖ ២០)។

[13] អ៊ិន សុក្រិត្យា, ផេង សំអឿន, បន្ទាយព្រៃនគរ, ១៩៩៨, ២



រូបលេខ២០៖ ទីតាំងស្ថានីយបុរាណក្នុងខេត្តតាកែវ

ក្រុងឥន្ទ្របុរ

ការឲ្យឈ្មោះក្រុងឥន្ទ្របុរ បានមកពីពាក្យ ***ឥន្ទ្រ*** ផ្សំនិងពាក្យ ***បុរ*** ។ វចនានុក្រមខ្មែររបស់សម្តេចសង្ឆ **ជួន ណាត** បានពន្យល់ថា៖

ឥន្ទ្រ ឬ ឥន្ទ (គុ.) = ដែលជាធំ ជាឥស្សរៈ ជាចម្បងលើគេ។

(ន.) = ព្រះនាមទេវរាជ ជាអធិបតីនៃពួកទេវតាក្នុងឋានត្រៃត្រឹង្សសួគ៌។

= ជាទេវរាជសក្តិសិទ្ធ វិសេសមួយអង្គក្នុងពួកទេវតាជាព្រាហ្មណិក និង ពុទ្ធសាសនិកផងទាំងពួង។

បុរ(បុរី ឬបុរិ) (ន.) = ក្រុង ខេត្តធំ រដ្ឋមណ្ឌល។

យើងអាចបង្រួមន័យនៃពាក្យ **ឥន្ទ្របុរ** ដោយផ្សំពាក្យទាំងពីរមកវិញ បានជាន័យមួយពេញលេញ ថាឥន្ទ្របុរ គឺជាទីក្រុងធំ ជាចម្បងលើសគេ ឬជាទីក្រុងរបស់ព្រះឥន្ទ្រ ដែលជាទេវរាជស្តេចនៃពួកទេវតា ទាំងឡាយនាឋានត្រៃត្រឹង្សសួគ៌។

ឥន្ទ្របុរ ប្រហែលស្ថិតនៅតំបន់បន្ទាយព្រៃនគរ ក្នុងភូមិបន្ទាយព្រៃនគរក្នុង(អង្គរក្នុង) ឃុំដូនតី ស្រុកពញាក្រែក(រូបលេខ៖ ២១)។ បន្ទាយព្រៃនគរសង់លើតំបន់ដីទួលខ្ពស់ជាងតំបន់ជុំវិញ និងមានសណ្ឋានដីជម្រាលពីកើតទៅលិច។ នៅផ្នែកខាងត្បូងជាតំបន់វាលស្រែល្វឹងល្វើយ ឯផ្នែកខាងកើតមានស្ទឹងស្ពានជ្រៃដែលមានប្រភពមកពីឆ្លូង ខេត្តក្រចេះ ហូរឆ្លាក់ទៅខេត្តព្រៃវែង ស្វាយរៀង និងហូរកាត់ប្រទេសវៀតណាមមុនដល់ទីបញ្ចប់។ បន្ទាយព្រៃនគរ គឺជាបន្ទាយដីលើកដោយមនុស្ស មានរាងបួនជ្រុង ហើយជ្រុងនីមួយៗមានប្រវែង២៥០០ម៉ែត្រ។ បន្ទាយមានកម្ពស់ចន្លោះពី៥ម៉ែត្រ ទៅ៧ម៉ែត្រ និងបាតមានទទឹងប្រវែងពី២០ម៉ែត្រ ទៅ២៥ម៉ែត្រ។ សព្វថ្ងៃនៅលើខ្នង និងតាមជើងទេរបន្ទាយមានដុះឈើតូចធំ និងមានដើមឫស្សីដុះស៊ីបទ្រុប។ តាមលោកអាយម៉ូនីញ បានកត់សម្គាល់ថាបន្ទាយព្រៃនគរមានស្នាមខឿនឥដ្ឋ ដែលគេតំរៀបដើម្បីទប់ដីកុំឲ្យបាក់[14]។ បន្ទាយដីនេះព័ទ្ធជុំវិញដោយកសិន្ទុទឹកដែលមានទទឹងប្រវែង១០០ម៉ែត្រ និងជម្រៅពី១ម៉ែត្រទៅ២ម៉ែត្រនៅរដូវវស្សា(មុនពេលដីកស្ពារ)។ នៅក្នុងបន្ទាយមានត្រពាំង និងព្រៃតូចៗដេរដាស់ មានវាលស្រែនិងវាលស្មៅ។ កំពែងនីមួយៗ មានទ្វារបីសមាមាត្រគ្នា ហើយមានផ្លូវទាក់ទងគ្នាពីទ្វារមួយទៅទ្វារមួយទៀត។ ផ្លូវសំខាន់សម្រាប់ភ្ជាប់ទៅមជ្ឈដ្ឋានខាងក្រៅប្រហែលចេញតាមច្រកទ្វារនាងច្រឡែង ទ្វារចំន្ទខែ ទ្វារមាស និងទ្វារឆ្លក[15](រូបលេខ៖ ២២)។ ផ្លូវសំខាន់ជាងគេគឺផ្លូវចេញតាមទ្វារឆ្លកមានប្រវែងប្រហែល២៥ ទៅ៣០គីឡូម៉ែត្រ។ ចំណែកផ្លូវចេញតាមច្រកបីទៀតប្រហែលជាផ្លូវបន្ទាប់បន្សំសម្រាប់ប្រើប្រាស់ទៅទីជិត។ ផ្លូវបុរាណបានកប់បាត់ក្នុងព្រៃស៊ីបទ្រុប និងដាច់ដោយកន្លែង។ ផ្លូវនេះកាត់តាមភូមិជាច្រើនមានផ្ទះរង្វើលៗ តែនៅផ្ទុំគ្នាជាក្រុមជុំវិញសំណង់សាសនា។ ម្យ៉ាងទៀតគេអាចស្គាល់យ៉ាងច្បាស់ពីដានផ្លូវចេញពីព្រះធាតុព្រះស្រីឆ្ពោះទៅទន្លេធំ(មេគង្គ)។ បើតាមលោកវ៉ីកតូហ្ការ្លេបេវបានបរិយាយថា ផ្លូវចេញពីបន្ទាយព្រៃនគរឆ្ពោះទៅទន្លេធំមានចំនួនពីរខ្សែ។ ខ្សែទី១ មានពីរផ្លូវ៖ ផ្លូវទី១ ចេញពីបឹងក្រពិត(ប្រហែលភូមិបឹងក្រពីសសព្វថ្ងៃ) នៅខាងលិចបន្ទាយព្រៃនគរ។ ចំណែកផ្លូវទី២ ស្ថិតនៅអាគ្នេយ៍នៃបន្ទាយព្រៃនគរចេញទៅដល់ភូមិប្រជាជនដែលនៅជិតនោះ។ តាមបណ្តោយផ្លូវបុរាណ មានភូមិធំៗជាច្រើនដែលប្រមូលផ្ទុំគ្នាក្បែរសំណង់នាចុងសតវត្សទី៦ឬដើមសតវត្សទី៧ ដូចជាក្រុមព្រះធាតុព្រះស្រី ប្រាសាទហាន់ដែជាដើម។ ផ្លូវនេះប្រហែលឡើងទៅភាគខាងជើងឆ្ពោះទៅក្រចេះតាមទន្លេធំឬតាមព្រៃកទេរ ឆ្ពោះទៅប្រាសាទព្រះធាតុក្ងាន់ពីរ ហើយបញ្ចប់នៅក្រុងស្ទឹងត្រែង

[14] ÉTIENNE Aymonier, Le Cambodge I, ១៩០០, ២៨៩

[15] ÉTIENNE Aymonier, Le Cambodge I, ១៩០០, ២៩០

និងថាឡាបរិវ៉ាត់[16]។ ចំណែកខ្សែទី២ គឺផ្លូវភ្ជាប់ទៅប្រទេសខាងក្រៅ ប្រហែលចេញពីខាងត្បូងបន្ទាយ ឆ្ពោះទៅជើងភ្នំអណ្ដែង ហើយភ្ជាប់ទៅដល់ប្រទេសចម្ប៉ា(វៀតណាមកណ្ដាលសព្វថ្ងៃ)[17]។



រូបលេខ២១៖ ទីតាំងរាជធានីឥន្ទ្របុរ

[16] GOLOUBEW, V., BEFEO, Tome XXXVI, 1936

[17] អ៊ិន សុក្រិត្យា, ផេង សំអឿន, បន្ទាយព្រៃនគរ, ១៩៩៨, ២១



រូបលេខ២២៖ ប្លង់រាជធានីឥន្ទ្របុរ និងច្រកសំខាន់ៗចេញពីរាជធានី។ ផែនទីនេះ
គូរដោយលោក E. Aymonier នៅឆ្នាំ១៩០០

គ. សម័យក្រោយអង្គរ

រហូតដល់ពាក់កណ្តាលទី២ នៃសតវត្សទី១៦ បើពិនិត្យលើការកត់ត្រារបស់អ្នកស្រាវជ្រាវ យើងអាចយល់ថា ខេត្តត្បូងឃ្មុំក្នុងសម័យកណ្តាល មានកើតនូវព្រឹត្តិការណ៍ពីរ គឺរឿងហ្លួងព្រះស្តេចកន និងរឿងទុំទាវ។ ព្រឹត្តិការណ៍ទាំងពីរនេះ ស្ថិតនៅក្នុងការចងចាំនៃអ្នកស្រុកផង និងមានកត់ត្រាក្នុងព្រះរាជពង្សាវតា របាក្សត្រ ឯកសារចិន សំណេររបស់សាសនទូតអឺរ៉ុប និងអត្ថបទអក្សរសិល្ប៍ ព្រមទាំងរឿងព្រេងមួយចំនួន។

ព្រឹត្តិការណ៍ទី១ កើតឡើងពីសកម្មភាពប៉ះបោររបស់ប្រជារាស្ត្រប្រឆាំងនឹងព្រះបាទសុគន្ធបទ។ លោក Gaspar da Cruz ជាសាសនទូតព័រទុយហ្គេ ដែលបានមកដល់កម្ពុជានៅចន្លោះឆ្នាំ១៥៥៥ ដល់ ១៥៥៧ បានសរសេរថា "ប្រជានុរាស្ត្រប៉ះបោរប្រឆាំងនឹងព្រះរាម[18] ដែលឡើងសោយរាជ្យ ហើយព្រះអង្គបានបង្ក្រាបពួកប៉ះបោរទាំងនោះ បន្ទាប់មកព្រះរាមព្រះអង្គបានប្រទានឲ្យព្រះអង្គដឹកនាំ"។ តាមព្រះរាជពង្សាវតា ព្រឹត្តិការណ៍នេះ គឺជាការប៉ះបោររបស់ស្តេចកន[19]ដែលបានធ្វើគត់ព្រះបាទសុគន្ធបទនៅដងស្ទឹងសែនក្នុងឆ្នាំ១៥១២។ ពេលធ្វើគត់ព្រះបាទសុគន្ធបទហើយស្តេចកន[20] បានគ្រប់គ្រងដែនដីកម្ពុជាទាំងអស់ជំនួស ព្រមទាំងទៅបង្ក្រាបខេត្តខណ្ឌនានា រួមមាននៅភូមិភាគខាងជើងជាប់ប្រទេសលាវ ខាងលិចជាប់សៀម ខាងជើងជាប់នគរចាម និងខាងត្បូងជាប់សមុទ្រ[21]។ ស្តេចកនបានសោយរាជ្យនៅរាជធានីស្រីសណ្ឋរយៈពេលប្រហែល២ឆ្នាំ។ នៅឆ្នាំ១៥១៤ ស្តេចកនបញ្ជាឲ្យគេសាងសង់រាជធានីថ្មីមួយនៅម្តុំភូមិចន្លក់ដូនតី ឬចម្លក់ព្រះស្រី[22] សម្រាប់ទុកជាស្នាដៃ និងជាកេរ្តិ៍ដំណែលនៃរាជវង្សថ្មីរបស់ខ្លួន។ រាជធានីនេះ សង់បានរយៈពេល៥ខែ[23] ក៏ប្រោះបង់ចោល ហើយប្តូរទៅសង់រាជធានីថ្មីនៅភូមិស្រឡប់ស្ថិតនៅចុងខេត្តត្បូងឃ្មុំទល់ដែនបាត់ភ្នំវិញ។

ការប្តូររាជធានីទៅស្រឡប់ដូនតីបន្ទាយព្រៃនគរនោះអាចបណ្តាលមកពីស្តេចកនព្រួយបារម្ភនឹងការរៀយលុករបស់ព្រះបាទអង្គចន្ទ្ររាជា។ ស្តេចកនយល់ថា ព្រះបាទអង្គចន្ទ្ររាជាបានស្គាល់យ៉ាងច្បាស់នូវភូមិសាស្ត្រប្រទេសកម្ពុជាភាគកណ្តាល ជាពិសេសទួលបាសានដែលស្ថិតនៅជាប់នឹងទន្លេ ព្រៃក និងបឹងជាច្រើន។ ដូច្នេះ ស្តេចកនទុកក្រុងស្រីសណ្ឋរ ឬទួលបាសានជាបន្ទាយកន្លែងយុទ្ធសាស្ត្រចាំទប់ទល់នឹងព្រះបាទអង្គចន្ទ្ររាជា[24]។

ចំពោះរាជធានីថ្មី លោក ហ្សក សឺដេស យល់ឃើញថា ស្តេចកនប្រហែលមិនសង់រាជធានីថ្មីទាំងស្រុងទេ គឺបានជ្រើសរើសរាជធានីចាស់របស់ព្រះបាទជ័យវ៉ែនទី២ ដែលមានជ័យភូមិល្អរួចហើយមកកែកុន ស្តារគូទឹកឡើងវិញ លើកកំពែង និងសង់សំណង់ខ្លះបន្ថែម។ រីឯភូមិសាស្ត្រឥន្ទ្របុរវិញ គឺជារាជធានី

---

[18] ព្រះបាទសុគន្ធបទ គឺជាព្រះរាមរបស់ព្រះបាទអង្គចន្ទ្ર

[19] ឯកសារខ្លះសរសេរថា ព្រះស្រីជេដ្ឋាស្តេចកន

[20] តាមពង្សាវតា ស្តេចកនមុនពេលឡើងសោយរាជ្យមានងារជាព្រះមហាឧបរាជ ភ្ងសម្រេចរាជការមហាក្សត្រសឹក កន។ នៅពេលឡើងសោយរាជ្យមានព្រះនាមថា ព្រះបាទសម្តេចព្រះស្រីជេដ្ឋាធិរាជរាមាធិបតី ក្រុងស្រីសណ្ឋរ បវរបាសាន។

[21] រស់ ចន្ត្រាបុត្រ, ព្រះស្តេចកន, ២០០៧, ៨៧

[22] KHIN Sok " Chroniques Royales du Cambodge" EFEO XIII, Paris 1988, 119

[23] ក្នុងអត្ថបទរបស់លោករស់ ចន្ត្រាបុត្រ សរសេរថា ស្តេចកនស្នាក់នៅចន្លក់ដូនតីរយៈពេល៦ខែ

[24] រស់ ចន្ត្រាបុត្រ, ព្រះស្តេចកន, ២០០៧, ២៦៧

សង់នៅលើទួលផុតពីទឹក មានអំណោយផលដល់កសិកម្ម មានទន្លេមេគង្គជារបាំងធម្មជាតិការពារពីការយារយីរបស់សត្រូវផង និងងាយស្រួលទាក់ទងពាណិជ្ជកម្មផង។

រាជធានីបន្ទាយព្រៃនគរ

ស្ថានភាពភូមិសាស្ត្របច្ចុប្បន្ន រាជធានីរបស់ស្តេចកនស្ថិតនៅចម្ងាយជាង៦០គីឡូម៉ែត្រពីទន្លេបិទ។ ព្រះអង្គបានបញ្ជាឲ្យគេឈូសឆាយ កាប់ឆ្ការដីរាបស្មើ ដុតក្បឿង ដុតឥដ្ឋ ដុតកំបោរ ជីកគូទឹកធំៗ ព័ទ្ធជុំវិញទិសទាំងបួន ហើយលើកដីធ្វើកំពែងការពារក្រុង។ កំពែងក្រុងនីមួយៗមានប្រវែង២៥០០ម៉ែត្រ[25] ។ តាមទិសនីមួយៗមានទ្វារចំនួន៣[26](រូបលេខ៖ ២៣)៖

- ទិសខាងដើង: ទ្វារមាស, ទ្វារគ្រាច, ទ្វារគ្នោតកណ្ឌ
- ទិសខាងកើត: ទ្វារចក្រឯក[27], ទ្វារនាងដីលែង, ទ្វារអន្ទាក់
- ទិសខាងត្បូង: ទ្វាររាម, ទ្វារចចកខាំ, ទ្វារទំនប់តាដី
- ទិសខាងលិច: ទ្វារចែនកែ, ទ្វារពោធ៍ធំ, ទ្វារក្ដុក

នៅកណ្ដាលរាជធានីស្តេចកនបានចាត់ឲ្យគេស្ថាបនាវត្តអារាម និងសាងប្រាសាទមួយ ហើយយកមាសខ្មៅសាងព្រះពុទ្ធរូបមួយ មានព្រះភ្នែន១២ផ្ទាប់ កម្ពស់២០ផ្ទាប់ តម្កល់ក្នុងប្រាសាទនោះ។ ព្រះពុទ្ធរូបនោះហៅថា ព្រះអង្គខ្មៅ និងតាំងនាមចៅអធិការវត្តនោះថា ព្រះអរិយញ្ញាណសាគរអាប៉ា ព្រមទាំងប្រគេនរហ័ពលចំនួន៥០០នាក់សម្រាប់វត្ត។ ទ្រង់តាំងនាមវត្តនោះថាវត្តប្រាសាទឬវត្តខ្មៅ[28] (រូបលេខ៖ ២៤)។

---

[25] រស់ ចន្ត្រាបុត្រ, ព្រះស្តេចកន, ២០០៧, ៩២

[26] ADHÉMAR Leclere, Le sdach Kân, Bulletin de la société des Etudes Indochinoises(BESI), No.59, Saigon, 1910, 35

[27] សំណេរចាស់ៗ តែងប្រទះឃើញគេហៅទ្វារនេះឈ្មោះថា ទ្វារចក្រឯក។ ប៉ុន្តែ អ្នកស្រុកសព្វថ្ងៃហៅទ្វារនេះថាទ្វារដូនអាចម៍ទៅវិញ

[28] អេង សុត, មហាបុរសខ្មែរ, ភ្នំពេញ, ១៩៩១, ១៦៩

រូបលេខ២៣៖ វត្តប្រាសាទឬវត្តខ្មៅ។ ក្រោយមកវត្តនេះ ត្រូវបានអ្នកស្រុកហៅឈ្មោះថា វត្តព្រៃនគរក្នុង

បន្ទាប់មកស្តេចកនបានឲ្យគេជីកអូរ សង់ប្រាសាទ ព្រះរាជមន្ទីរ ត្រឡែងកែងចុងរោង រោងទង រោងជួង រោងទីនាំង ឃ្លាំង និងសួនមានគ្រប់ប្រការ។ នៅផ្នែកខាងលិច គេសង់ព្រះរាជវាំង ដែលមានបន្ទាយការពារ ដោយមានទទឹងប្រវែង២០០ម៉ែត្រ បណ្តោយប្រវែង៣០០ម៉ែត្រ និងកម្ពស់៦ម៉ែត្រ។ នៅក្នុងបន្ទាយព្រះរាជវាំង គេសង់អគារចំនួន២២ សម្រាប់ដាក់ព្រះរាជរថ និងសម្រាប់ធ្វើរោងសេះ ដំរី។ ក្រៅពីនោះ ស្តេចកនបានចាត់ឲ្យសង់ព្រះវិហារចំនួន២ ប្រាសាទចន្ទធាយា និងអគារចំនួន២០ទៀត ក្នុងរាជវាំងសម្រាប់ស្រីស្នំ ព្រះដំណាក់ រោងជំនុំ និងបន្ទប់សំអាងចំនួន៧ សម្រាប់តុបតែងព្រះមហាក្សត្រទៅតាមថ្ងៃទាំង៧នៃសប្តាហ៍[29]។ តែរាជធានីថ្មីនេះ ពុំមានប្រភពទឹក ទើបទ្រង់បង្គាប់ឲ្យឧកញ៉ារៀងមួយ ឧកញ៉ារាំងមួយ ឧកញ៉ាលំពាំងមួយ ឧកញ៉ាស្រាលមួយ ឲ្យជីកស្រះធំរាងបួនជ្រុងនៅកណ្តាលកំពែងព្រះនគរ។ លុះជីកបានទឹកស្រេច ស្តេចសន្ទ្ធត់ឲ្យហៅជ្រុងនីមួយៗថា កំពង់រៀង កំពង់រាំង កំពង់លំពាំង និងកំពង់ស្រាល។ ពេលសង់រួចរាល់ស្តេចកនបានដាក់ឈ្មោះរាជធានីថ្មីនេះថា "ក្រុងសន្ធប់ជ្ជនតីព្រៃនគរបវរារាជធានី"[30] ។ ស្តេចកន បានចាត់រៀបចំសាងផ្លូវក្នុងព្រះនគរ និងផ្លូវភ្ជាប់ពីរាជធានីទៅខេត្តរោងដំរី ដើម្បីភ្ជាប់ទៅនឹងសមុទ្រ។ ក្រៅពីនោះ ព្រះអង្គបានចាត់ចែងបោះប្រាក់ស្លឹង ជាមាស ប្រាក់ ដែលមានត្រារូបនាគជាសម្គាល់សម្រាប់ដោះដូរ ធ្វើចរាចរក្នុងប្រទេស។

---

[29] រស់ ចន្ត្រាបុត្រ, ព្រះស្តេចកន, ២០០៧, ៨៧

[30] តាមព្រះរាជពង្សាវតារខ្មែរ រៀបរៀងដោយលោកយិន សុក បានសរសេរថា ក្រុងថ្មីមានឈ្មោះថា "ក្រុងស្រឡប់ពិជ័យនគរបុរាណរាជធានី"វិញ។

ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយបែបទៀត គឺទាក់ទងនឹងអក្សរសិល្ប៍រឿងទុំទាវ ដែលក្នុងស្រទាប់មហាជនទូទៅគិតថាជារឿងព្រេងផង និងប្រវត្តិសាស្ត្រផង។ អក្សរសិល្ប៍នេះ ប្រហែលកើតឡើងតាំងពីសតវត្សទី១៦មកម្ល៉េះ ហើយអ្នកស្រុកនៅចងចាំយ៉ាងខ្ជាប់ខ្ជួនក្នុងស្មារតីដូចរឿងនោះកើតឡើងថ្មីៗនៅឡើយ។ ឯឈ្មោះទីកន្លែងមួយចំនួនដូចជា ទឹកដី ភូមិ ស្រុក ក៏បង្ហាញពីការជាប់ពាក់ព័ន្ធនឹងរឿងព្រេងនោះដែរ។ មិនត្រឹមតែប៉ុណ្ណោះ យើងសង្កេតឃើញថា សាច់រឿង និងសកម្មភាពរបស់តួអង្គខ្លះត្រូវបានអ្នកស្រុកលើកមកបង្ហាញតាមបែបអបីជំនឿយ៉ាងមុតមាំ។ យើងអាចលើកឧទាហរណ៍ ប្តីប្រពន្ធពីរនាក់រស់នៅក្បែរក្រុងសួង គឺជារូបស្នងដូនផាន់ និងនេនទុំ។ រូបស្នងរបស់ដូនផាន់ជាអ្នកមានកំណើតនៅត្បូងឃ្មុំ ឯរូបស្នងរបស់នេនទុំមានកំណើតនៅខេត្តព្រៃវែង។ អ្នកស្រុកជឿតឲ្យជឿថា រូបស្នងទាំងពីរជាគ្រូអាចព្យាបាលជំងឺ ឬជួយដោះស្រាយបញ្ហាគ្រប់បែបយ៉ាង។ ម្យ៉ាងទៀត តួអង្គដូនផាន់ នាងទាវ និងនេនទុំ បានក្លាយទៅជាអ្នកតាចាស់ស្រុកដ៏សំខាន់ក្នុងតំបន់នេះ។ យើងពុំដឹងថា អ្នកតានៃតួអង្គទាំងបីនេះ មានកើតតាំងពីពេលណាឲ្យប្រាកដទេ ហើយក៏ពុំដឹងថាមានរូបដូចម្តេចដែរ ប៉ុន្តែរូបអ្នកតាទាំងបី សព្វថ្ងៃគេបានសាងពីស៊ីម៉ង់ត៍ដាក់តម្កល់ក្នុងខ្ទមធ្វើពីស៊ីម៉ង់ត៍ដែរ។ រូបទាំងនោះគេបានដាក់តម្កល់នៅទីទួលផ្សេងគ្នាគឺ ដូនផាន់ និងនាងទាវដាក់នៅទួលដែលគេយល់ថាជាទួលផ្ទះដូនផាន់ ឯរូបតំណាងនេនទុំដាក់នៅទួលផ្សេង ដែលគេយល់ថាជាកន្លែងដែលគេយកទុំទៅសម្លាប់នៅទីនោះ។

ថ្មីត្បិតតែយើងមានពត៌មានស្ពួចស្ដើងពីកស្ដុតាងនៃការប្រែប្រួលសហគមន៍មនុស្ស និងប្រវត្តិទឹកដីខេត្តត្បូងឃ្មុំនៅចន្លោះសតវត្សទី១៧ និង១៨ រហូតពេលពួកអ៊ីរ៉ុបបានឃើញ ហើយធ្វើការពិពណ៌នានៅពាក់កណ្ដាលសតវត្សទី១៩ ពោលគឺសម័យកាលមួយដែលកម្ពុជាឱនថយខ្លាំង ក៏យើងជឿជាក់ថាទឹកដីខេត្តត្បូងឃ្មុំទាំងមូលពុំត្រូវបានគេបោះបង់ចោលទាំងស្រុងនោះឡើយ។ ភូមិករ និងសំណង់សាសនាមួយចំនួននៅមានវត្តមានមនុស្សបន្តរស់នៅ និងថែរក្សាឥតដាច់។ ចុងសតវត្សទី១៩ ដើមសតវត្សទី២០ អ្នកស្រាវជ្រាវបារាំងមួយចំនួន បានធ្វើដំណើរទៅដល់បន្ទាយព្រៃនគរ មិនមែនឃើញរហោស្ថានទេ គឺពួកគេបានឃើញសហគមន៍មនុស្ស ភូមិដ្ឋានប្រមូលផ្ដុំគ្នានៅក្បែរសំណង់សាសនានានា។ នៅឆ្នាំ១៨៨៣ លោកអ៊ីម៉ូនីញ៉ូ បានមកដល់បន្ទាយព្រៃនគរ ហើយបានឃើញវត្ត និងកុដិតូចៗមួយចំនួន ដែលគេបានសាងសម្រាប់គោរពបូជាព្រះពុទ្ធសាសនា ស្ថិតនៅបរិវេណប្រាសាទព្រះធាតុធំស្ថិតក្នុងបន្ទាយព្រៃនគរ។ នៅក្នុងព្រះវិហារ មានតម្កល់ព្រះពុទ្ធរូបមួយអង្គតូចនៅលើអាសនៈ និងមានព្រះសង្ឆពីរអង្គគង់នៅក្នុងវត្តនគរក្នុង ហើយសង្ឆមួយអង្គជាប្រធានហៅថា "មហាបា"។

ចំណែកខាងក្រៅបន្ទាយព្រៃនគរវិញ លោកអ៊ីម៉ូនីញ៉ូ បានឃើញវត្តព្រះធាតុព្រះស្រីដែលមានសហគមន៍មនុស្សនៅកុះករ និងមានសកម្មភាពខ្លាំងក្លាជាងវត្តព្រៃនគរក្នុង។ នៅពីលើទួលប្រាសាទមានអគារពុទ្ធសាសនាចំនួនពីរសង់ដាច់ពីគ្នា គឺអគារមួយមានរាងជាបុស្សុកសង់ពីបាយអរគ្របពីលើប្រាង្ក

ប្រាសាទបុរាណ និងអគារពុទ្ធសាសនាមួយទៀត ជាព្រះវិហារសង់គ្រប់ពីលើមណ្ឌបដែលសង់ក្នុងរាជ្យរបស់ព្រះបាទយសោវ៉ារ្ម(រូបលេខ៖២4)។ នៅចន្លោះអគារទាំងពីរគេបានរក្សាទុកសសរផ្ទោបចំនួនពីរសម្រាប់ទ្រផ្តែ ដែលមានលក្ខណៈដូចក្លោងទ្វាប្រាសាទ។ បើនិយាយពីតួប្រាសាទបុរាណវិញមានទំហំ៨ម៉ែត្របួនជ្រុង មានទ្វារចូលពីខាងកើត និងទ្វារបញ្ជោតចំនួន៣។ យើងអាចសន្និដ្ឋានថា នៅសម័យនោះ ហើយដែលគេបានចោះទ្វារបញ្ជោតខាងជើង និងខាងត្បូងសម្រាប់ពុទ្ធបរិស័ទ្ធចេញចូលគោរពបូជា។ សព្វថ្ងៃបុស្សរ៉ុក និងប្រាង្គបុរាណមានទ្វារចេញចូលចំនួន៣ គឺខាងកើត ខាងជើងនិងខាងត្បូង។ ខាងក្នុងបុស្សរ៉ុកគេរៀបចំកន្លែងដាក់តម្កល់បល្ល័ង្គព្រះ ដោយមានទុកកន្លែងតម្កល់ព្រះពុទ្ធរូបផ្សេងៗផង។ បច្ចុប្បន្ន បើទោះបីវត្តនោះទ្រុឌទ្រោមយ៉ាងណា ក៏នៅមានអ្នកស្រុកគោរពជឿថា ជាលំនៅនៃអ្នកតាផ្សេងៗ ហើយតែងធ្វើតង្វាយពុំដាច់។ ជួនកាលគេធ្វើពិធីបញ្ជាន់រូប ឬលេងភ្លេងថ្វាយដល់អ្នកតា ដោយគេជឿថាជាអ្នកតាប្រចាំសហគមន៍របស់គេ។

ឧទាហរណ៍ទាំងនេះ សឲ្យឃើញថាទឹកដីត្បូងឃ្មុំ និងបុរាណដ្ឋាននានា ជាទីដែលមានជីវិតរស់រវើក មិនមែនជារហោស្ថានដែលគេបោះបង់ ឬលែងនឹកនានោះឡើយ។

រូបលេខ២៥៖ វិហារព្រះធាតុព្រះស្រីសង់គ្របលើប្រាសាទសតវត្សទី៨

២. អក្សរសិល្ប៍, ទឿងព្រេង និងឈ្មោះខេត្ត

២.១. អក្សរសិល្ប៍

ក. ហ្លួងព្រះស្តេចកនតាមរយៈព្រះរាជពង្សាវតារ

ការសិក្សាប្រវត្តិសាស្ត្រខ្មែរចាប់ពីសម័យកណ្តាល[31]មក គឺពឹងផ្អែកលើឯកសារព្រះរាជពង្សាវតារដែលចារនៅលើស្លឹករឹត។ ក្រៅពីនេះ មានឯកសារបរទេសខ្លះទៀតដូចជាចិន,សៀម,វៀតណាម,អេស្ប៉ាញ និងព័រទុយហ្គាល់ព្រមទាំងសិលាចារឹកប្រមាណ៤០ផ្ទាំង ចារលើសសរនៅជាន់"ព្រះពន់"និងជាន់"បាកាន្ត" នៃប្រាសាទអង្គរវត្ត[32] (រូបលេខ៖ ២៦)។



រូបលេខ ២៦៖ សិលាចារឹកស្ថិតនៅជាន់បាកាន្តនៃប្រាសាទអង្គរវត្ត (ប្រភពរូប៖ ហេង ថាន, ២០១៦)

---

[31] អ្នកស្រាវជ្រាវបែបវិទ្យាសាស្ត្រនិយមចែកប្រវត្តិសាស្ត្រប្រទេសកម្ពុជាជាបីផ្នែក ពោលគឺសម័យចាស់ ឬបុរាណ (រួមមានសម័យមុនអង្គរចាប់ពីស.វ.ទី៧-៩ និងសម័យអង្គរស.វ.ទី៩-១៤/១៥), សម័យកណ្តាល (ស.វ.ទី១៤/១៥-ពាក់កណ្តាលស.វ.ទី១៩), សម័យថ្មីចាប់ពីពាក់កណ្តាលស.វ.ទី១៩រៀងមក។

32 ប្រសិនបើចង់ជ្រាបច្បាស់ពីសិលាចារឹកនៅអង្គរវត្តទាំងអស់នោះ សូមអាន៖ មហាពិទូរ ក្រសេម និងពៅ សារ៉ាស, ១៩៨៤។

ឯកសារពង្សាវតារដែលបន្សល់មកទល់សព្វថ្ងៃ មានច្រើនច្បាប់ខុសៗគ្នា ខ្លះខ្លី ខ្លះវែង ខ្លះមានឈ្មោះអ្នកនិពន្ធនិងកាលបរិច្ឆេទនិងខ្លះទៀតពុំមានឡើយ។ ព្រះរាជពង្សាវតារដែលចាស់ជាងគេហៅថា "ពង្សាវតារព្រះអង្គអេង"ដែលផ្ញើទៅក្រុងបាងកកក្នុងឆ្នាំ១៧៩៦ ហើយសព្វថ្ងៃ ច្បាប់ដើមជាភាសាខ្មែរនោះបានបាត់បង់ទៅហើយ គឺនៅសល់តែច្បាប់ដែលបកប្រែទៅជាភាសាសៀមប៉ុណ្ណោះ។ ចំណែកពង្សាវតារដែលប្រវត្តិវិទូបច្ចុប្បន្នចាត់ទុកជាពង្សាវតារផ្លូវការ គឺពង្សាតារឧកញ៉ាវ៉ាំង ជួន។ ពង្សាវតារនេះនិពន្ធរវាងឆ្នាំ ១៩០៣ទៅ១៩៣០។

ក្នុងពង្សាវតាររៀបរាប់ថា មានព្រះរាជាមួយចំនួនបានមកតាំងបន្ទាយ ឬរាជដំណាក់នៅលើទឹកដីត្រើយខាងកើតទន្លេមេគង្គ ដូចជានៅទួលបាសានជាដើម។ ប៉ុន្តែ រឿងរ៉ាវរបស់ព្រះរាជាទាំងនោះហាក់ដូចជាមិនមានប្រជាប្រិយ ឬក៏ជិតនៅក្នុងដួងចិត្តអ្នកស្រុកនៅតំបន់នោះទាល់តែសោះ លើកលែងតែស្តេចមួយអង្គដែលពង្សាវតាររហៅថា "ស្តេចកន" ឬ "ហ្លួងព្រះស្តេចកន"មួយប៉ុណ្ណោះ។ អ្នកស្រុកនៅទីនោះចេះចាំរឿងស្តេចកន ដូចជាចេះចាំរឿងទុំទាវដូច្នោះដែរ។ ប្រហែលហេតុផលសំខាន់មួយដែលធ្វើឲ្យអ្នកស្រុកចងចាំពីស្តេចកន ដោយសារតែក្នុងការនិទានតៗគ្នាក្តី ឬក្នុងពង្សាវតារ[33]ក្តីរៀបរាប់ថា ស្តេចកនបានមកសាងក្រុងដោយលើកកំពែងដីព័ទ្ធជុំវិញជាបន្ទាយយុទ្ធសាស្ត្រយ៉ាងរឹងមាំហើយដាក់ឈ្មោះថា"ក្រុងស្រឡប់ពិជ័យព្រៃនគរ"។ ម្ល៉ោះហើយ បើសួរអ្នកស្រុកនៅតំបន់នោះ គេច្បាស់ជាឆ្លើយថា "បន្ទាយព្រៃនគរ" (អ្នកស្រុកសព្វថ្ងៃហៅថាព្រៃនគរក្នុង) ដែលយើងឃើញសព្វថ្ងៃនេះ គឺជាក្រុងស្រឡប់ពិជ័យព្រៃនគររបស់ស្តេចកន។

ដូចពោលពីខាងលើរួចមកហើយថា ពង្សាវតារមានច្រើនច្បាប់ណាស់ ហើយពង្សាវតារដែលពេញលេញ គឺតែងមានរៀបរាប់ពីរឿងហ្លួងព្រះស្តេចកន។ ប៉ុន្តែ អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះ គឺសេចក្តីរៀបរាប់ទាក់ទងនឹងរឿងរ៉ាវហ្លួងព្រះស្តេចកន ពោលគឺចាប់ពីរាជ្យស្តេចស្រីសុគន្ធបទ, ស្តេចកន និងស្តេចចន្ទ្ររាជានោះ មានសេចក្តីពិស្តារជាងរឿងស្តេចដទៃទៀត។ ឧទាហរណ៍ ដូចជា ឯកសារពង្សាវតារចម្លងដៃមួយនៅឆ្នាំ១៩០៦ ដាក់ចំណងជើងថា "ព្រះរាជពង្សាវតារខ្មែរ" ដែលលោក LECLÈRE អតីតទេសាភិបាលបារាំងប្រចាំកម្ពុជា ជាអ្នកផ្ដួចផ្ដើមឲ្យចម្លងទុក[34]និង"ឯកសារមហាបុរសខ្មែរ" របស់លោក អេង សុត

---

[33] គួរជ្រាបថា រឿងរ៉ាវភាគច្រើនក្នុងពង្សាវតារ គឺចងក្រងតាមសម្តីនិទានរបស់អ្នកស្រុក។

[34] នៅក្នុងអារម្ភកថាសៀវភៅនេះរៀបរាប់ថា តម្រាពង្សាវតារនេះ គឺលោក LECLÈRE ជាអ្នកផ្ដួចផ្ដើមគំនិតនិងឧបត្ថម្ភក្នុងការចម្លងនៅក្នុងឆ្នាំ១៩០៦ (ពុំមានឈ្មោះអ្នកចម្លង) ហើយពុំទាន់បោះពុម្ពនៅឡើយទេ។ ឯកសារនេះត្រូវចម្លងតដោយដៃ ហើយសម្រួលជាអក្ខរាវិរុទ្ធបច្ចុប្បន្ន ហើយបោះពុម្ព ដោយគម្រោងការវប្ប្ធម៌ខ្មែរ J.S.R.C. នៅខៅអ៊ីដាង (ពុំមានឆ្នាំបោះពុម្ព) ដោយដាក់ចំណងជើងថា "ព្រះរាជពង្សាវតារខ្មែរ" និពន្ធដោយលោក អាដឹ*ារឡ*ាក្ល*ារ អតីតរ*ើ*ស*ីដង់បារាំងប្រចាំកម្ពុជា។ លោក LECLÈRE ក៏បានដកស្រង់ពង្សាវតារនេះយកទៅបញ្ចូលនៅក្នុងសៀវភៅរបស់ គាត់ដែលមានចំណងជើងថា "Histoire du Cambodge Depuis de 1er Siècle de Notre Ère" បោះពុម្ពឆ្នាំ១៩១៤ នៅក្រុងប*ារីស*។

ជាដើម។ មិនតែប៉ុណ្ណោះ នៅក្នុងបណ្ណាល័យរបស់វត្តកំពង់ត្រឡាចក្រោម ក្នុងខេត្តកំពង់ឆ្នាំង មានសាស្ត្រាមួយចារពី រឿងស្តេចកននេះដាច់តែឯង ហើយត្រូវគេយកមកបោះពុម្ពជាសៀវភៅ ដោយដាក់ចំណងជើងថា"ប្រវត្តិហ្លួងព្រះស្តេចកន[35]"។ លោក LECLÈRE ក៏បានដកស្រង់យករឿងស្តេចកនពីពង្សាវតារមកបកប្រែជាភាសាបារាំងដោយដាក់ចំណងជើងថា "Le Sdach Kân" ហើយចុះនៅក្នុងទស្សនាវដ្ដី[36]។ ចំណែកលោករស់ ចន្ត្រាបុត្រ ក៏បានបោះពុម្ពផ្សាយសៀវភៅមួយក្បាលមានចំណងជើងថា "ព្រះស្តេចកន"[37]។ ក្រៅពីនេះ រឿងស្តេចកន ត្រូវគេយកទៅនិពន្ធជាប្រលោមលោកនិងកំណាព្យផ្សេងៗ[38]។

ខ. ប្រវត្តិរឿងទុំទាវ

"ទុំទាវ" ជារឿងរ៉ាវប្រវត្តិស្នេហាផ្អែមល្ហែម និងជូរចត់រវាងសាមណេរទុំ មកពីស្រុកបាក្ន និងនាងទាវដែលជាក្រមុំដ៏ស្រស់ប្រិមប្រិយនៅភូមិពោធិ៍ជើងខាល។ អ្នកស្រុកជឿថា ទុំទាវជារឿងកើតមានពិតនៅក្នុងសង្គមខ្មែរកាលពីរវាង៤-៥សតវត្សមុន។ អ្នកស្រុកជឿទៀតថា នៅភូមិពោធិ៍ជើងខាល ខេត្តត្បូងឃ្មុំសព្វថ្ងៃ នៅសេសសល់វត្ថុជាកេរ្ដ៍តំណែលពីរឿងទុំទាវដូចជា កីតម្ពាញនិងត្បាល់បុកអង្ករបស់នាងទាវដើមពោធិ៍ ជាទីដែលយាយផាន់សង់ផ្ទះកែ្ករនិងដើមពោធិ៍ដែលគេយកទុំទៅសម្លាប់ជាដើម(រូបលេខ២៧-២៩)។

ទុំទាវជារឿងដែលមានប្រជាប្រិយពុំចាញ់រឿងរាមកេរ្ដ៍ឡើយ ដ្បិតរឿងនេះត្រូវអ្នកស្រុកយកទៅដំណាលតៗគ្នា, សម្ដែងជាល្ខោន, និទាន, ច្រៀងចាប៉ី និងយកទៅផលិតជាកុន, ចម្រៀងកាយវិការ។ល។ មិនតែប៉ុណ្ណោះ រឿងទុំទាវត្រូវគេចាត់ទុកជាស្នាដៃអក្សរសិល្ប៍យ៉ាងសំខាន់ ពីព្រោះថានៅឆ្នាំ១៩៥៧ នៅពេលដែលរាជរដ្ឋាភិបាលផ្ដើមបញ្ចូលអក្សរសាស្ត្រខ្មែរទៅក្នុងកម្មវិធីសិក្សាជាតិ ក្រោយពេលប្រទេសទទួលបានឯករាជ្យពីអាណានិគមបារាំង[39]នោះ រឿងទុំទាវក៏ត្រូវគេជ្រើសរើសបញ្ចូលទៅក្នុងកម្មវិធីសិក្សានាពេលនោះដែរ[40]។ រហូតមកទល់នឹងឆ្នាំ១៩៦៥ បើទោះជាកម្មវិធីសិក្សាអក្សរសាស្ត្រខ្មែរត្រូវគេកែសម្រួល ហើយមានរឿងជាច្រើនត្រូវគេដកចេញ តែរឿងទុំទាវគេនៅតែរក្សាទុកដដែលរហូតមកទល់សព្វថ្ងៃ។

---

35 សូមអាន៖ សូរ អឿ, ១៩៨៩។

36 សូមអាន៖ LECLÈRE Adhémard, 1910: 17-55.

37 សូមអាន៖ រស់ ចន្ត្រាបុត្រ, ២០០៧។

38 សូមអាន៖ រស់ ចន្ត្រាបុត្រ, ២០០៧៖ ៨-៩។

39 ប្រទេសកម្ពុជាស្ថិតក្រោមអាណានិគមបារាំងរយៈពេល៩០ឆ្នាំ ពេលគឺពីឆ្នាំ១៨៦៣ដល់១៩៥៣។

40 CHIGAS George, 2005: 1។ ប៉ុន្តែ បើតាមបណ្ឌិត យ៉ង ហុកឌី ថាក្រសួងសិក្សាធិការជាតិបញ្ចូល"រឿងទុំទាវ" ទៅក្នុងកម្មវិធីសិក្សាឆ្នាំ១៩៥៨។ សូមអាន៖ យ៉ង ហុកឌី, ២០០៥៖ ៥។



រូបលេខ២៧៖ ដើមពោធិ៍ដែលអ្នកស្រុកជឿថា ផ្ទះយាយផាន់សង់ក្បែរនោះ។ សព្វថ្ងៃស្ថិតនៅភូមិជើងខាល ឃុំមង់រាវ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។ នៅឆ្នាំ២០១៣ អ្នកស្រុកបានសង់ខ្ទមដាក់រូបសំណាកយាយផាន់ និងនាងទាវ នៅក្រោមដើមពោធិ៍នោះ (ប្រភពរូប៖ សាន ផល្លា, ២០១៥)

រូបលេខ២៨៖ រូបសំណាកយាយផាន់ និងនាងទាវ (ប្រភពរូប៖ សាន ផល្លា, ២០១៥)

រូបលេខ២៩៖ ដើមពោធិ៍ដែលអ្នកស្រុកជឿថា គេយកទុំមកសម្លាប់។ សព្វថ្ងៃស្ថិតនៅភូមិជើងខាល ឃុំមង់រាវ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ (ប្រភពរូប៖ សាន ផល្លា, ២០១៥)។

នេះបង្ហាញឲ្យឃើញពីសារសំខាន់នៃរឿងទុំទាវក្នុងអក្សរសាស្ត្រ និងអត្តសញ្ញាណវប្បធម៌ខ្មែរ(រូបលេខ៣០-៣១)[41]។ រឿងទុំទាវជាប្រភេទអក្សរសិល្ប៍ប្រពៃណី ដែលគេជឿថា និពន្ធឡើងដោយផ្អែកលើរឿងរ៉ាវពិត ដែលកើតឡើងក្នុងសង្គមខ្មែរ ហើយបើផ្អែកតាមឯកសារព្រះរាជពង្សាវតារខ្មែរ គឺស្ថិតក្នុងរាជ្យ

[41] THONG Phan, 1976 ដកស្រង់នៅក្នុង CHIGAS George, 2005: 1។

ព្រះបាទរាមាធិបតី[42] សោយរាជ្យនៅអំឡុងស.វ.ទី១៦ ហើយឯកសារខ្លះថាស.វ.ទី១៧។ តាមពិតទៅ សំណេររឿងទុំទាវដែលបន្សល់ទុកមកទល់នឹងបច្ចុប្បន្ន ប្រហែលនិពន្ធឬចងក្រងឡើងដោយផ្អែកលើរឿងដែលគេនិទានតៗគ្នា។

រូបលេខ៣០៖ សព្វថ្ងៃស្ថិតនៅភូមិជើងខាល ស្ត្រីម្នាក់បានអះអាងថាខ្លួនជារូបស្នងរបស់ដូនផាន់។ រូបស្នងនោះបានសង់ប្រាសាទមួយតម្កល់បដិមា ហើយនៅពីមុខបដិមានោះមានរូបសំណាកដូនផាន់ (ប្រភពរូប៖ សាន ផល្លា, ២០១៥)

រូបលេខ៣១៖ ព្រលឹងដូនផាន់កំពុងចូលមកសណ្ឋិតក្នុងរូបស្នង រីឯមនុស្សប្រុសអង្គុយខាងស្តាំនោះ ជាទុំដែលមកចាប់ជាតិ ហើយត្រូវជាប្តីរបស់រូបស្នងដូនផាន់នោះ (ប្រភពរូប៖ សាន ផល្លា, ២០១៥)

រឿងទុំទាវ ក្លាយជាទីចាប់អារម្មណ៍របស់មន្ត្រីអាណាព្យាបាលបារាំងដែលត្រូវគេបញ្ជូនឲ្យមកបំពេញការងារនៅស្រុកខ្មែរ។ នៅឆ្នាំ១៨៨០ លោក AYMONIER បានបកប្រែរឿងទុំទាវលើកទី១ ព្រមទាំងចុះទៅស្រាវជ្រាវផ្ទាល់នៅត្បូងឃ្មុំ ហើយបញ្ចូលព័ត៌មានដែលប្រមូលបាននោះរួមទាំងរឿងទុំទាវដែលលោកបានបកប្រែជាលើកទី២ ទៅក្នុងសៀវភៅមានចំណងជើងថា Le Cambodge I, Le Royaume Actuel បោះពុម្ពនៅឆ្នាំ១៩០០[43]។ ចំណែកលោក DELAPORTE ជាអ្នកដឹកនាំបេសកកម្មមន្ត្រីក្រសួងអប់រំសាធារណៈបារាំងមកកាន់កម្ពុជា។ គាត់ធ្លាប់ឮគេសម្តែងរឿងទុំទាវនៅពេលគាត់ធ្វើដំណើរទៅតាមជនបទ។ ជាក់ស្តែងក្នុងឆ្នាំ១៨៧៣ នៅពេលគាត់ធ្វើដំណើរពីភ្នំពេញទៅខេត្តសៀមរាប គាត់ក៏បានចូលរួមក្នុងពិធីបុណ្យ កឋិនៅភូមិបេងមាលា ដែលក្នុងពិធីនោះ គាត់បានស្តាប់គេសម្តែង(ជានិទាន)រឿងទុំទាវពីដើមដល់ចប់ ដោយមានជំនួយ ពីអ្នកបកប្រែ។ លោក DELAPORTE មានការស្ងើចសរសើររឿងនោះពន់ពេក ហេតុនេះគាត់ក៏សម្រេចបញ្ចូលរឿងទុំទាវដែលបកប្រែលើកទី១ដោយលោក AYMONIER ទៅ

[42] ក្នុងឯកសារព្រះរាជពង្សាវតារខ្មែរ មានព្រះរាជាច្រើនអង្គដែលមានព្រះនាមថា "រាមាធិបតី" នេះ។

[43] THONG Phan, 1976 ដកស្រង់នៅក្នុង CHIGAS George, 2005: 2-3។

ក្នុងសៀវភៅរបស់គាត់ឈ្មោះ Voyage au Cambodge, Architecture Khmère បោះពុម្ពនៅក្នុងឆ្នាំ ១៨៨០[44]។

បើតាម CHIGAS George តួអង្គនិងព្រឹត្តិការណ៍នៅក្នុងសេចក្តីនិទានរឿងទុំទាវ ដែលបោះពុម្ព ដោយលោក DELAPORTE និងលោក AYMONIER គឺស្រដៀងទៅនឹងស្នាដៃរបស់ភិក្ខុសោម។ ប៉ុន្តែក៏ មានការខុសគ្នាខ្លះគួរឲ្យកត់ សម្គាល់។ នៅក្នុងរឿងដែលគេនិទាន តួឯកប្រុសដែលជាសាមណេរមានព្រះ នាម "ឯក" គឺពុំមែន "ទុំ" ឡើយ។ ម្យ៉ាងវិញទៀត នៅក្នុងរឿងនិទានផ្ទាល់មាត់គឺឯក និងទាវបានភ្ជាប់ ពាក្យជាមួយគ្នាតាមប្រពៃណីរួចហើយ មុននឹងត្រូវគេនាំទៅកាន់រាជវាំង ដែលដំណើររឿងនេះគឺខុសពីក្នុង អត្ថបទរបស់ភិក្ខុសោម។ ចុងក្រោយ បើតាមសម្តីនិទាន គឺឧកញ៉ា អរដូននិងកូនប្រុស ជាអ្នករៀបចំល្បិច កល ដើម្បីហៅទាវពីព្រះរាជវាំង ព្រមទាំងបញ្ជុះបញ្ជូលម្តាយទាវឲ្យសរសេរសំបុត្រកុហកថាខ្លួនឈឺធ្ងន់។ រីឯនៅក្នុងអត្ថបទអក្សរសិល្ប៍ គឺម្តាយទាវជាអ្នករៀបចំឧបាយកលដោយខ្លួនឯង[45]។

ក្រៅពីការនិទានផ្ទាល់មាត់ រឿងទុំទាវក៏មានកត់ត្រានៅក្នុងឯកសារព្រះរាជពង្សាវតារដែរ។ ដូច ពោលពីខាងលើរួចមកហើយថា ពង្សាវតារមានច្រើនស្នាដៃ ហើយតាមតឹកតាងដែលនៅសេសសល់ ស្នា ដៃដែលចាស់ជាងគេគឺនិពន្ធក្នុងអំឡុងចុងស.វ.ទី១៨ ហើយចំណែកស្នាដៃថ្មីជាងគេ គឺចងក្រងនៅដើម ស.វ.ទី២០។

ក្នុងចំណោមពង្សាវតារទាំងអម្បាលម៉ានមានច្បាប់ពង្សាវតារពីរដែលមានបញ្ជូលរឿងទុំទាវ។ ច្បាប់ ទី១ពុំមានឈ្មោះអ្នកនិពន្ធនិងកាលបរិច្ឆេទឡើយ ហើយត្រូវកត់ចម្លងដោយសាលាបារាំងចុងបូព៌ាក្នុងឆ្នាំ ១៩១៦ ដោយចុះលេខ "P57" (សព្វថ្ងៃតម្កល់នៅក្នុងបណ្ណាល័យសាលាបារាំងចុងបូព៌ានៅប្រទេស បារាំង)[46]។ តាមរយៈច្បាប់ P57នេះបង្ហាញឲ្យឃើញថា រឿងទុំទាវកើតឡើងនៅក្នុងឆ្នាំ១៦៥៤ ចុងរាជ្យ ស្តេចរាមាធិបតី (១៦៤១-១៦៥៦) ដែលមានរាជធានីនៅឧត្តុង្គ[47]។

ចំណែកពង្សាវតារមួយទៀតដែលរៀបរាប់រឿងទុំទាវនេះដែរ គឺសាស្ត្រាឈ្មោះ"ព្រះរាជពង្សាវតារ" របស់វត្តទឹកវិល ដែលចងក្រងនៅក្នុងឆ្នាំ១៩៤១ តាមសង្ឃដីការបស់ព្រះចៅអធិការវត្តព្រះតេជគុណ ហាស់ ស៊ុក ហើយរក្សាទុកនៅក្នុងព្រះរាជវាំង។ តាមពិតទៅ ព្រះរាជពង្សាវតារថ្មីនេះ គឺចងក្រងដោយផ្អែក លើច្បាប់ "ពង្សាវតារវត្តទឹកវិល"ចាស់ ដែលចងក្រងក្នុងរាជ្យព្រះបាទ នរោត្តម (១៨៦០-១៩០៤) និង

---

[44] CHIGAS George, 2005: 3 និង យីង ហុកឌី, ២០០៥, ៧។

[45] CHIGAS George, 2005: 3.

[46] KHIN Sok, 1988 និង MAK Phoeun, 1981 ដកស្រង់នៅក្នុង CHIGAS George, 2005: 5។

[47] THONG Phan, 1976 ដកស្រង់នៅក្នុង CHIGAS George, 2005: 5។

ព្រះបាទ ស៊ីសុវត្ថិ (១៩០៤-១៩២៧)[48]។ ដូចគ្នានឹងពង្សាវតារ P57ដែរ រឿងទុំទាវមានបរិយាយនៅក្នុងរាជ្យស្តេចរាមាធិបតី តែខុសត្រង់ឆ្នាំសោយរាជ្យនិងរាជធានីពោលគឺពង្សាវតារវត្តទឹកវិលដាក់ឆ្នាំសោយរាជ្យរបស់ស្តេចរាមាធិបតីពីឆ្នាំ១៦៣៨-១៦៥៥ ហើយព្រះអង្គគង់នៅរាជធានីលង្វែក[49]។ នៅក្នុងច្បាប់វត្តទឹកវិល ឈ្មោះតួអង្គ និងព្រឹត្តិការណ៍ខុសគ្នាខ្លះពីច្បាប់P57 ពោលគឺទុំនិងទាវត្រូវម្តាយឪពុកទាំងសងខាងភ្ជាប់ពាក្យតាំងពីនៅក្មេងវ័យ ហើយម្តាយទាវជាអ្នកប្រើល្បិចហៅទាវឲ្យត្រឡប់មកវិញដើម្បីរៀបការជាមួយមឺនងួន[50]។

ក្រៅពីឯកសារដែលរៀបរាប់ខាងលើ រឿងទុំទាវក៏មាននិពន្ធជាកាព្យមួយចប់ ហើយចារនៅលើសាស្ត្រាស្លឹករឹត។ នៅក្នុងឆ្នាំ១៩៥៨ រដ្ឋាភិបាលបានបញ្ចូលរឿងទុំទាវទៅក្នុងកម្មវិធីសិក្សាអនុវិទ្យាល័យ។ នៅពេលនោះ មានរឿងទុំទាវពីរស្នាដៃត្រូវគេបោះពុម្ពរួចហើយ។ រឿងមួយដាក់ចំណងជើងថា "ទុំទាវ" បោះពុម្ពតជាភាគនៅក្នុងទស្សនាវដ្តីកម្ពុជសុរិយា តាំងពីឆ្នាំ១៩៣២។ ស្នាដៃទី២ជារបស់ការី នូ កន មានចំណងជើង "ទាវឯក" បោះពុម្ពនៅក្នុងឆ្នាំ១៩៤៩ និង១៩៥៣[51]។ ប៉ុន្តែគេយល់ថា អត្ថបទរឿងដែលត្រូវយកមកបង្រៀនគឺទាល់តែចម្លងចេញផ្ទាល់ពីសាស្ត្រាទើបត្រឹមត្រូវជាង ម្ល៉ោះហើយទើបគណៈកម្មការ[52] ទទួលខុសត្រូវរឿងនេះ ខំស្វះស្វែងរកសាស្ត្រានៅតាមវត្តទូទាំងប្រទេស។ ទីបំផុត គណៈកម្មការរកបានសាស្ត្រា៤ដែលមានចំណងជើងប្លែកគ្នា ហើយខ្លះពុកផុយខ្លាំង។ សាស្ត្រាទាំង៤ត្រូវចងក្រងបញ្ចូលគ្នាទៅជារឿងតែមួយ ដោយយកសម្តីនិទានមកបញ្ចូលបង្ក្រប់កន្លែងដែលខ្វះ ព្រមទាំងនៅចុងបញ្ចប់ត្រង់ "ព្រះរាជាបញ្ជាឲ្យដាក់ទោសក្រុមគ្រួសារអរជូន" គឺយកស្នាដៃរបស់ភិក្ខុ សោម មកបញ្ចូល [53]។ រឿងដែលចងក្រងបញ្ចូលគ្នានេះដាក់ចំណងជើងថា "ទុំទាវ" ហើយបោះពុម្ពក្នុងឆ្នាំ១៩៦០ ដោយដាក់ឈ្មោះ សន្ទរម៉ុក ដែលជាកវីដ៏ល្បីល្បាញក្នុងស.រ.ទី១៩ (រាជ្យព្រះបាទនរោត្តម) ជាអ្នកនិពន្ធ[54]។

នៅក្នុងអំឡុងពេលនោះ ក៏មានសាស្ត្រាដែលនិពន្ធដោយភិក្ខុ សោម ឆ្នាំ១៩១៥ ជាកាព្យបទ "ពាក្យ៧" នៅសេសសល់ដែរ។ សាស្ត្រានោះចម្លងដោយព្រះតេជគុណ អ៊ុម ក្នុងឆ្នាំ១៩៣៥។ ដោយសារ

---

[48] CHIGAS George, 2005: 7.

[49] CHIGAS George, 2005: 7.

[50] KHIN Sok, 1988 ដកស្រង់នៅក្នុង CHIGAS George, 2005: 10.

[51] THONG Phan, 1976 ដកស្រង់នៅក្នុង CHIGAS George, 2005: 16.

[52] គណៈកម្មការនោះរួមមានសាស្ត្រាចារ្យ ហង់ ធន់ហាក់, អេង សុត, នាង ហ៊ូ និង សម ថាំង។

[53] THONG Phan, 1976 ដកស្រង់នៅក្នុង CHIGAS George, 2005: 17.

[54] លី ធាមតេង, ១៩៦០៖ ១៥២-១៥៧។ អេង សុត, សម ថាំង, ហង់ ធន់ ហាក់, នាង ហ៊ូ, ១៩៦០៖ ៥-១១។ យីង ហុកឌី, ២០០៣៖ ២០២។ JUDITH M. Jacbo, 1996: 74.

សាស្ត្រានេះចប់សព្វគ្រប់ ហើយមានទាំងឈ្មោះអ្នកនិពន្ធនិងកាលបរិច្ឆេទត្រឹមត្រូវ ទើបវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យសម្រេចបោះពុម្ពសាស្ត្រានេះក្នុងឆ្នាំ១៩៦២ ហើយប្រើសម្រាប់បង្រៀននៅសាលា។ ប៉ុន្តែសំណួរបានចោទសួរថា តើច្បាប់ទុំទាវរបស់ភិក្ខុ សោម ជាច្បាប់ដើម ឬក៏និពន្ធដោយយកលំនាំតាមរឿងទុំទាវរបស់សន្ធរម៉ុក? និងសំណួរថាតើនរណាជា "អ្នកនិពន្ធដើម" នេះក្លាយជាប្រធានបទដដែកពិភាក្សាក្នុងចំណោមអ្នកសិក្សាអក្សរសាស្ត្រខ្មែរ[55]។ ប៉ុន្តែ គង់ សម្ភារ ដែលជាអ្នកសិក្សាអក្សរសាស្ត្រនោះយល់ថាស្នាដៃរបស់ភិក្ខុ សោម គឺផ្អែកលើរឿងផ្ទាល់មាត់ ដែលច្រៀងនិងលេងចាប៉ីដោយស្ត្រីម្នាក់ឈ្មោះ សាយ ពួរ នៅស្រុកភូមិនោះ[56]។

រឿងទុំទាវមួយទៀតមានចំណងជើងថា "ទាវឯក"គឺជាស្នាដៃរបស់ នូ កន ដែលជាកវីល្បីឈ្មោះ។ លោក នូ កន និពន្ធរឿងទាវឯកជាកាព្យបទ "ពាក្យ៨" ក្នុងឆ្នាំ១៩៤២ ហើយរឿងនេះទទួលបានពានរង្វាន់លេខ១ នៅក្នុងការប្រឡងអក្សរសាស្ត្រដែលរៀបចំដោយអាណាព្យាបាលបារាំង។ រឿងនេះបោះពុម្ពនៅក្នុងឆ្នាំ១៩៤៩ ដោយគ្រឹះស្ថានបោះពុម្ពផ្សាយ គឹម សេង[57]។ ក្រៅពីនេះ នៅមានឯកសារសាស្ត្រាស្លឹករឹតរឿងទុំទាវ ឬទាវឯក ដែលជាស្នាដៃនិពន្ធផ្សេងៗ តម្កល់នៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ដែលលោក ញ៉ុក ថែម បានស្រង់ជាបញ្ជីសារពើភណ្ឌ ក្នុងនោះរួមទាំងស្នាដៃរបស់ភិក្ខុ សោម ផង។[58]

នៅឆ្នាំ២០០៥ បណ្ឌិត យីង ហុកឌី បានចេញផ្សាយសៀវភៅមួយមានចំណងជើងថា "ទាវឯក" (រូបលេខ៣២) ដោយនៅក្នុងនោះ គឺចុះផ្សាយទាំងសាស្ត្រានិងឯកសារនៅលើក្រដាសចម្លងចេញពីសាស្ត្រានោះ (ជារបស់លោក FINOT Louis) ដែលតម្កល់ទុកនៅបណ្ណាល័យសាលាបារាំងចុងបូព៌ាចុះលេខសម្គាល់149 និង P. camb. 32 ហើយឯកសារទាំងពីរនោះ ដាក់ចំណងជើងថា "ទាវឯក"។ អត្ថបទទាំងពីរនេះពុំឃើញមាននៅបណ្ណាល័យនានាក្នុងប្រទេសកម្ពុជាទេ ហើយសាច់រឿងក៏ខុសប្លែកពី អត្ថបទនានាដែលបានបោះពុម្ពកន្លងមកនៅស្រុកខ្មែរ។ ដ្ឋិតតែសាស្ត្រានោះពុំមានកាលបរិច្ឆេទនៃការនិពន្ធ តែមានចុះកាលបរិច្ឆេទនៃការចម្លង ពោលគឺ "ចារ(ចម្លង) ចប់នៅថ្ងៃសៅរ៍ ១៣កើត ខែអស្សុជ ចុល្លសករាជ ១២៦៦ ឆ្នាំជូត ទោសក" ហើយបើសិនជាគិតជាគ្រិស្តសករាជ គឺប្រហាក់ប្រហែលនឹងឆ្នាំ១៩០4[59]។ ម្ល៉ោះហើយ ត្រឹមតែកាលបរិច្ឆេទនៃការចម្លងនេះក៏ឃើញថា អត្ថបទនោះចាស់ជាងអត្ថបទរបស់ភិក្ខុ សោម (១៩១៥) និង នូ កន (១៩៤២) ១ចទៅហើយ។ យីង ហុកឌី សន្និដ្ឋានថា អត្ថបទដែលរក្សានៅបណ្ណា

---

[55] CHIGAS George, 2005: 17.

[56] គង់ សម្ភារ, ១៩៧១, ដកស្រង់នៅក្នុង CHIGAS George, 2005: 19.

[57] KHING Hoc Dy, 1993 ដកស្រង់ក្នុង CHIGAS George, 2005: 20 និង JUDITH M. Jacbo, 1996: 79.

[58] សូមអាន៖ ញ៉ុក ថែម, ១៩៦៥៖ ១០៥៥-១០៥៦, ១០៦៣-១០៦៤, ១១៥១-១១៥២។

[59] ដើម្បីបានកាលបរិច្ឆេទជាគ្រិស្តសករាជ ត្រូវយកឆ្នាំចុល្លសករាជនោះ បូកនឹង៦៣៨ ឬ៦៣៩ឆ្នាំ។

ល័យនៃសាលាបារាំងចុងបូព៌ាទាំងពីរនោះ ប្រហែលជានិពន្ធនៅពាក់កណ្តាលទី២នៃស.វ.ទី១៨ ឬយ៉ាងហោចណាស់ក៏ស.វ.ទី១៩។[60]

នេះជារឿងគួរឲ្យភ្ញាក់ផ្អើល ដ្បិតជាការរកឃើញឯកសារថ្មីមួយទៀត ដែលមានអាយុកាលកាន់តែចាស់ ដែលនេះជាពន្លឺថ្មីមួយទៀតសម្រាប់ការសិក្សាទៅលើភាពចំណាស់នៃរឿងទុំទាវបន្តទៅទៀត។ ហេតុដូច្នេះ រឿងដែលលើកមកបង្ហាញទាំងអម្បាលម៉ាននេះ គឺគ្រាន់តែជាឧទាហរណ៍ខ្លះៗប៉ុណ្ណោះ។ ចំពោះស្នាដៃអក្សរសិល្ប៍រឿងទុំទាវនេះ ប្រហែលនៅមានស្នាដៃអ្នកនិពន្ធជាច្រើនទៀតដែលផុតរលត់បាត់បង់ទៅដោយសារតែអាយុកាល។ គ្រាន់តែប៉ុណ្ណោះក៏អាចស្មានថា រឿងទុំទាវនេះមានប្រជាប្រិយដល់កម្រិតណា។ បើគិតពីស្នាដៃតែងនិពន្ធវិញគឺថា "សម័យកណ្តាល" នេះ អក្សរសាស្ត្រខ្មែរឡើងដល់កម្រិតកំពូល ហើយបើពោលពីភាពរុងរឿងវិញគឺពុំចាញ់អារ្យធម៌សម័យអង្គរឡើយ គ្រាន់តែមានបែបបទផ្សេងពីសម័យបុរាណប៉ុណ្ណោះ។



រូបលេខ៣២៖ សៀវភៅរឿង "ទាវ ឯក" បោះពុម្ពផ្សាយដោយ ឃឹង ហុកឌី (រូប៖ សាន ផល្លា, ២០១៦)

[60] ឃឹង ហុកឌី, ២០០៥៖ ៦-៧។

គ. រឿងព្រេងអ្នកតាបេង

អ្នកតាបេងស្ថិតនៅក្នុងភូមិជីកែ សង្កាត់វិហារហ្លួង[61] ក្រុងសួង ខេត្តត្បូងឃ្មុំ(**រូបលេខ៖៣៣-៣៥**)។ អ្នកតាបេងនេះមានកិត្តិនាមល្បីល្បាញ ហើយអ្នកស្រុកគោរពបូជាណាស់ ជាពិសេសចៅហ្វាយខេត្ត ឬចៅហ្វយស្រុកត្បូងឃ្មុំ ដែលទើបឡើងកាន់ដំណែងថ្មីត្រូវធ្វើពិធី "ឡើងអ្នកតាបេង"។ រឿងព្រេងអ្នកតាបេងនេះក៏មានជាប់ទាក់ទងទៅនឹងរឿងព្រេងនៃការហៅឈ្មោះ "ខេត្តត្បូងឃ្មុំ" ផង។ អ្នកស្រុក ជាពិសេសចាស់ទុំនៅចេះចាំរឿងព្រេងអ្នកតាបេងនេះ មិនចាញ់ការចេះចាំរឿង "ទុំទាវ" និង "ហ្លួងព្រះស្តេចកន" ឡើយ។ ជាធម្មតា ការនិទានតៗគ្នាពីមាត់មួយទៅមាត់មួយច្រើនតំណមកហើយ គឺតែងមានភាពខុសគ្នាខ្លះដៀសពុំរួចឡើយ ហើយក៏ពុំមានអ្នកណាខុសឬត្រូវទេ(**រូបលេខ៖៣៦-៣៧**)។ ដូចពោលពីខាងលើមក អ្នកតាបេងមានឈ្មោះល្បី រហូតដល់លោកឧកញ៉ា កែវ ហង្ស[62] ជាចាងហ្វាងចូលនិវត្តន៍នៅឃុំសួង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម បានសរសេររឿងនេះ ហើយយកទៅបោះពុម្ពផ្សាយក្នុង "ប្រជុំរឿងព្រេងខ្មែរ"(ភាគ៨)ដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ។ ម្ល៉ោះហើយ រឿងអ្នកតាបេងនៅទីនេះ គឺដកស្រង់តាមច្បាប់បោះពុម្ពនេះ ព្រមទាំងបន្ថែមរឿងរ៉ាវរបស់អ្នកស្រុកដែលពុំមាននៅក្នុងសំណេររបស់លោក កែវ ហង្ស នៅក្នុងកំណត់ពន្យល់ (**នៅខាងចុងជំពូក**)។ សេចក្តីដំណាល[63]នោះមានដូចតទៅ៖

ដើមឡើយ មានវត្តមួយនៅក្នុងឃុំវិហារហ្លួង ស្រុកត្បូងឃ្មុំហៅថា "វត្តទួលក្តី[64]" ។ លោកគ្រូចៅអធិការវត្តនេះមានប្អូនស្រីក្រមុំម្នាក់។ វត្តនេះមានរូបអ្នកតាធ្វើពីសំរឹទ្ធិមួយ មានឫទ្ធិខ្លាំងពូកែណាស់ អាចប្រែកាឡាខ្លួនជាមនុស្សបាន។ នៅពេលមានពិធីបុណ្យ ឬថ្ងៃសីល អ្នកតានោះតែងក្លែងខ្លួនជាប្រុសកំលោះ ស្លៀកពាក់ស្អាតបាត មានកាន់ផ្ដិលនិងវ៉ែកសំរឹទ្ធិ ដាក់បាយទៅរាប់បាត្រជាមួយអ្នកស្រុក។ រាល់ពេលក្រោយដាក់បាត្ររួច កំលោះនោះចុះពីលើសាលា ហើយក៏បាត់ខ្លួនមួយរំពេច។ អ្នកស្រុកមានការងឿងឆ្ងល់ជាខ្លាំង ហើយតែងសួរនាំគ្នាថា តើប្រុសកំលោះនោះមានផ្ទះសម្បែងនៅឯណា បានជាតែងឃើញនៅវត្ត ហើយគ្រាន់តែចុះពីសាលាក៏ស្រាប់តែបាត់ខ្លួនមួយរំពេច។

---

[61] បច្ចុប្បន្នគេសរសេរដោយច្រឡំទៅជា «វិហារលួង» តែបើតាមចាស់ទុំក្នុងស្រុកស្នើថាគួរសរសេរ "វិហារហ្លួង" វិញទើបត្រឹមត្រូវជាង។

[62] លោកតា អឹម អៀន អាយុ៨៨ឆ្នាំ រស់នៅភូមិជីកែ សង្កាត់វិហារហ្លួង ក្រុងសួងដែលផ្ដល់សម្ភាសន៍ទាក់ទងនឹងរឿងអ្នកតាបេងបានចេះដឹងរឿងព្រេងនោះពីលោក កែវ ហង្ស នេះដែរ ដែលកាលនោះលោកតាអៀនទើបតែមានអាយុប្រហែលជាង១០ឆ្នាំ។

[63] កែវ ហង្ស, ២០០៩៖ ៤០-៤១។

[64] បើតាមឯកសារសំណេរដៃរបស់លោកតា ជួប សំអឿន គណៈកម្មការវត្តវិហារហ្លួង ថាវត្តនោះឈ្មោះ "វត្តវិហារហ្លួង"។ ចំណែកលោកតា អឹម អៀន ថាវត្តនោះឈ្មោះ "វត្តអន្លុងជ្រៃ"។

ក្រោយមក អ្នកតានោះបានទៅលបលួចរួមរស់ជាមួយនឹងប្អូនក្រមុំលោកគ្រូមេវត្ត[65]។ លុះដឹងថាប្អូនស្រីមានប្រុសសាហាយលោកគ្រូក៏ហៅប្អូនមកសាកសួរតាមដំណើរ។ នាងនោះក៏ទទួលសារភាពថាបានស្រឡាញ់ប្រុសម្នាក់មែន គឺឲ្យតែដល់ពេលយប់ស្រាប់តែឃើញប្រុសនោះចូលទៅដេកជាមួយខ្លួនតែម្តង។ ឯខ្លួននាងចាប់ពាល់ខ្លួនបុរសនោះមិនត្រូវសោះ ហាក់ដូចជាស្រមោល[66]។ លុះឮប្អូនស្រីរ៉ាយរ៉ាប់ដូច្នោះ លោកគ្រូមេវត្តក៏ជ្រាបភ្លាមថា ជាអ្នកតាសំរឹទ្ធិ ដែលមានឫទ្ធិខ្លាំងពូកែ។ លោកគ្រូខ្ទាល់នឹងអ្នកតាសំរឹទ្ធិនោះជាខ្លាំង ក៏ប្រើក្មេងឲ្យដីករណ្តៅ នៅទួលមួយស្ថិតនៅជ្រុងអាគ្នេយ៍វត្តចម្ងាយប្រហែល២០០ម.-៣០០ម៉ែត្រ ហើយលោកគ្រូក៏ឲ្យយករូប សំរឹទ្ធិនោះ ទៅកប់ផ្តាប់ក្បាលចុះក្រោម រួចយកដើមបេងទៅដាំសង្កត់លើរូប នោះ។ ម្ល៉ោះហើយ បានជាអ្នកស្រុកហៅទួលនោះថា "ទួលអ្នកតាបេង"។

ក្រោយមក លោកគ្រូមេវត្តក៏អនិច្ចធម្មទៅ នៅសល់តែភិក្ខុសាមណេរតិចអង្គនៅវត្តទួលក្តីនោះ។ មានយាយចាស់ម្នាក់[67]ឈ្មោះកែ ឥតមានប្តីនិងបងប្អូនទេ ហើយក៏ឃ្លីជាដូនជីនៅវត្តទួលក្តីនោះ។ តមកខាងក្រោយទៀត លោកសង្ឆក្នុងវត្ត ចេះតែចាកចេញម្តងមួយអង្គ១ៗរហូតអស់ពីវត្ត គឺនៅសល់តែយាយជីកែនោះម្នាក់ឯង។ ឯដើមបេងដែលលោកមេវត្តដាំសង្កត់ លើអ្នកតានោះ ក៏លូតលាស់ធំឡើង ហើយមានសត្វឃ្មុំធ្វើសម្បុកនៅលើដើមនោះផង[68]។ ឃ្មុំនោះធំហើយកាចណាស់ ផ្ទ្រីតវាធ្លាក់ស្ពោកប៉ប្រះដី។ គ្រាន់តែ

---

[65] នៅក្នុងសំណេរដៃរបស់លោកតា ជួប សំអឿន និងលោក ហាស់ សារ៉ន (មន្ត្រីការិយាល័យអ.យ.ក.ស្រុក) មាននិយាយដល់អ្នកតាសំរឹទ្ធិបានកាឡាខ្លួនជាមនុស្សទៅលេងវាយកូនគោលភ្លើងជាមួយយុវជនក្នុងភូមិ ហើយក្រុមរបស់គាត់តែងឈ្នះគេរាល់លើក។ មិនតែប៉ុណ្ណោះ ក្នុងសំណេររបស់លោកតា ជួប សំអឿន មាននិយាយដល់អ្នកភូមិបានទៅហូបបាយនៅផ្ទះ (ខ្ទម) អ្នកតាសំរឹទ្ធិ ដែលមានម្ហូបឆ្ងាញ់ៗ និងចានក្បានល្អៗដែលក្រោយមក អ្នកស្រុកបាននាំគ្នាទៅខ្ចីចាន-ឆ្នាំងពីខ្ទមអ្នកតាសំរឹទ្ធិមកប្រើប្រាស់នៅពេលមានពិធីបុណ្យទាន។

[66] តាមប្រសាសន៍របស់លោកតា អឹម អៀន ថានាងនោះជាកូយស្រីសង្ក្រាជវត្ត ហើយរួមរស់ជាមួយអ្នកតាបេងរហូតដល់មានទាំងកូនផង។ លោកតា អៀន ប្រាប់ទៀតថា កូនចៅដែលជាសែស្រឡាយរបស់អ្នកតាបេងនៅរស់បន្តដល់សព្វថ្ងៃ។ ហេតុនេះបើតាមទំនៀមបុរាណ គឺមានតែអ្នកដែលអ្នកស្រុកជឿថា ជាប់សែស្រឡាយជាមួយអ្នកតាបេងទេ ទើបអាចមានសិទ្ធិចងដៃចៅហ្វាយស្រុក ឬចៅហ្វាយខេត្តក្នុងពិធីឡើងអ្នកតានេះ។

[67] តាមអត្ថបទសំណេររបស់លោកតា ជួប សំអឿន ថាប្អូនស្រីរបស់លោកគ្រូសង្ក្រាជវត្តបានបួសជាដូនជីនៅវត្តវិហារហ្លួង ដើម្បីកែប្រែខ្លួនដែលបាន ប្រព្រឹត្តខុសគន្លងប្រពៃណី។ ហេតុនេះអ្នកស្រុកប្រសិទ្ធនាមឲ្យគាត់ថា "ដូនជីកែ (ឬកេ្ម)"។ ក្រោយមកអ្នកស្រុកហៅកាត់ត្រឹមតែ "ជីកែ" ហើយក្លាយជាឈ្មោះភូមិមួយនៅទីនោះ គឺ"ភូមិជីកែ"។ រីឯអត្ថបទសំណេររបស់លោក ហាស់ សារ៉ន ថាដោយកើតទុក្ខព្រាត់ប្រាស់សង្សារ និងចង់កសាង ខ្លួនឲ្យល្អឡើងវិញ ប្អូនស្រីនោះក៏បួសជាដូនជី ហើយអ្នកស្រុកក៏ប្រសិទ្ធនាមនាងថា "ដូនជីកែប្រែ"។ ក្រោយមក វត្តទួលក្តីក៏ត្រូវគេបោះបង់ចោល ហើយដូនជីនោះក៏ទៅរស់នៅភូមិមួយស្ថិតនៅខាងលិចវត្ត ទើបអ្នកស្រុកហៅភូមិនោះថា "ភូមិដូនជីកែប្រែ"។ពាក្យនេះត្រូវហៅកាត់ខ្លីបន្តិចម្តង១ៗនៅត្រឹមតែ "ភូមិជីកែ" រហូតមកទល់សព្វថ្ងៃ។

[68] តាមប្រសាសន៍របស់លោកតា អឹម អៀន ថាឃ្មុំធ្វើសម្បុកលើដើមអំពិល។

ខ្យល់បក់នាំក្លិនមនុស្សមកដល់ មេវានាំគ្នាហើរទាំងហ្វូងទៅទិចទាល់តែស្លាប់។ ហេតុដូចនោះ ទើបនៅខែកត្តិក-មិគសិរ-បុស្ស ដែលជារដូវខ្យល់ខ្លាំងបក់មកពីទិសខាងជើង យាយកែតែងតែប្រាប់អ្នកដំណើរឲ្យដើរពីខាងត្បូងឃ្មុំ ព្រោះបើដើរពីខាងជើង ខ្យល់បក់នាំក្លិនមនុស្ស ហើយឃ្មុំនឹងហើរមកទិចស្លាប់ពុំខាន។ ពាក្យថា "ដើរខាងត្បូងឃ្មុំ" នេះហើយ ដែលជាដើមកំណើតឈ្មោះនៃខេត្តត្បូងឃ្មុំនេះ មិនមែនគង់ឃ្មុំម្យ៉ាង ដែលគេប្រើធ្វើត្បូងចិញ្ចៀននោះទេ។

រូបលេខ៣៣៖ ខ្ទមអ្នកបេងដែលទើបសាងថ្មី
(ប្រភពរូប៖ សាន ផល្លា, ២០១៥)

រូបលេខ៣៤៖ រូបអ្នកតាបេងចាស់
(ប្រភពរូប៖ សាន ផល្លា, ២០១៥)

រូបលេខ៣៥៖ រូបអ្នកតាបេងថ្មីដែលសាងដំណាលគ្នានឹងខ្ទមថ្មីនោះដែរ(រូប៖ សាន ផល្លា, ២០១៥)

រូបលេខ៣៦៖ សម្ភាសន៍លោកតា អឹម អៀន អាយុ៨៨ឆ្នាំ អំពីរឿងព្រេងអ្នកតាបេង (ប្រភពរូប៖ សាន ផល្លា, ២០១៥)

រូបលេខ៣៧៖ ជួបសំណេះសំណាលជាមួយលោកតា ជួប សំអឿន អតីតមន្ត្រីការិយាល័យវប្បធម៌និងវិចិត្ត សិល្ប:ស្រុកត្បូងឃ្មុំ។ សព្វថ្ងៃជាគណ:កម្មការវត្តវិហារហ្លួង (ប្រភពរូប៖ សាន ផល្លា, ២០១៥)

ឃ. ពិចារណាអំពីឈ្មោះ "ត្បូងឃ្មុំ"

ជាទូទៅឈ្មោះទីកន្លែងផ្សេងៗនៅប្រទេសកម្ពុជា ច្រើនតែទាក់ទងនឹងធម្មជាតិដូចមានឈ្មោះខេត្ត "ត្បូងឃ្មុំ" ជាឧទាហរណ៍ស្រាប់ គឺយកតាមបរិស្ថានធម្មជាតិនៃតំបន់នោះ ពីព្រោះបើតាមអ្នកស្រុកថា តំបន់នោះពីដើមសម្បូរណ៍ឃ្មុំណាស់។ ពាក្យត្បូងឃ្មុំ ជាការផ្សំនាមពីរបញ្ចូលគ្នា គឺ "ត្បូង + ឃ្មុំ"។ ពាក្យ "ត្បូង" ជាពាក្យខ្មែរដែលសព្វថ្ងៃគេស្ទើរតែលែងស្គាល់ទៅហើយ ហើយបែរមកប្រើពាក្យសំស្ត្រឹត"ក្បាល"(កបាល) ជំនួសវិញ។ ប៉ុន្តែ ពាក្យត្បូងនេះគឺនៅតែឃើញសេសសល់នៅក្នុងពាក្យខ្លះដែរ ឧទាហរណ៍ខ្មែរនៅតែហៅថា"ត្បូងចប" គឺពុំដែលប្រើ "ក្បាលចប" ទេ ហើយសូម្បីតែនៅក្នុងព្រះបរមរាជវាំងដែលភាគច្រើនប្រើពាក្យសំស្ត្រឹតសម្រាប់ព្រះមហាក្សត្រនោះ ក៏ពាក្យត្បូងនេះត្រូវគេយកទៅប្រើប្រាស់ដែរ ឧទាហរណ៍នៅពេលគាល់ព្រះមហាក្សត្រ គេនិយាយថា "ព្រះករុណាជាម្ចាស់ជីវិតលើត្បូង..."។ ចំណែកនៅឯខេត្តតាកែវ មានភូមិមួយឈ្មោះ "ត្បូងដំរី" ស្ថិតនៅក្នុងឃុំក្រាំងធ្នង់ ស្រុកបាទី។ល។

ជាប្រពៃណី ខ្មែរតែងដេកបែរក្បាលទៅទិសទក្សិណ (ពាក្យសំស្ត្រឹត) ដើម្បីជាមង្គល ហើយជើងតម្រង់ទៅទិស"ឧត្តរ"។ ម្ល៉ោះហើយខ្មែរក៏ហៅទិសខាងក្បាលនោះថា"ទិសខាងត្បូង"(គឺទិសក្បាល) ហើយទិសដែលឈមនោះគឺ"ទិសខាងជើង" ពោលគឺសំដៅលើជើងមនុស្សយើងនេះឯង។ ចំណែកទិសកើតលិចគឺសំដៅដល់ដំណើរថ្ងៃរះនិងលិច ពីព្រោះខ្មែរបុរាណរំពឹងពេលវេលាតាមដំណើរព្រះអាទិត្យនិងព្រះចន្ទនោះឯង។ ក្បាល ឬត្បូងជាអវ:យវ:សំខាន់និងមានតម្លៃបំផុតរបស់ មនុស្ស ពោលគឺមនុស្សយើងអាចរស់នៅដោយអត់ដៃ ឬជើងបាន តែពុំអាចអត់ក្បាលបានឡើយ។ ហេតុដូច្នេះហើយ ទើបខ្មែរហៅកែវថ្មវិសេស

ច្រើនប្រភេទមានពេជ្រ, មរកត, កណ្តៀង, និល, ទទឹម ជាដើម ថាជា "ត្បូង"។ សរុបសេចក្តីមក ពាក្យត្បូងនេះគឺមានន័យតែមួយគឺ "ក្បាល"។

ចំណែកឯពាក្យឃ្មុំ គឺជាឈ្មោះសត្វល្អិតមួយប្រភេទក្នុងពួកភមរជាតិមានទឹកផ្អែមសំណុសសម្រាប់ធ្វើក្រមួន។ ឃ្មុំមានច្រើនយ៉ាង ដូចជាឃ្មុំផ្ទិត, ឃ្មុំធំ, ឃ្មុំត្រចៀកដំរី, ឃ្មុំចង្អេរ, ឃ្មុំអាចម៍ឆ្កែនិងឃ្មុំបូកគោ[69]។

ប្រជាជនដែលមិនធ្លាប់បានសិក្សាប្រវត្តិសាស្ត្រភាគច្រើនតែងចាត់ទុករឿងព្រេងថាជាប្រវត្តិសាស្ត្រ ឬជារឿងពិត ដែលតាមពិតមិនមែនដូច្នោះឡើយ។ រឿងព្រេងគឺកើតឡើងក្រោយព្រឹត្តិការណ៍ជាក់ស្តែងនោះយូរឆ្នាំ ឬអាចរាប់សតវត្សផងក៏ថាបាន ហើយតែងនិយាយថែមថយពីមាត់មួយទៅមាត់មួយ និងពីគ្រាមួយទៅគ្រាមួយ។ ដោយសារតែរឿងរ៉ាវ ឬព្រឹត្តិការណ៍នោះពុំមានបន្សល់ទុកឯកសារកត់ត្រាត្រឹមត្រូវច្បាស់លាស់ ម្ល៉ោះហើយ មនុស្សក៏ភ្លេចព្រឹត្តិការណ៍នោះអស់រលីង។

តាមធម្មជាតិពិត គេពុំដែលប្រទះឃើញ "ត្បូង" ឬ "គជ់"[70] ដុះនៅលើសត្វឃ្មុំ ឬសម្បុកឃ្មុំ ឡើយ។ បើតាមវចនានុក្រមខ្មែរ គឺមានតែគជ់ខ្សង, គជ់ត្រ, គជ់ដំរី, គជ់ក្រៀល[71]។ ហេតុនេះ ពាក្យថាត្បូងឃ្មុំ ច្បាស់ជាពុំសំដៅលើត្បូងឬគជ់មានតម្លៃដែលដុះនៅលើសម្បុកឃ្មុំនោះឡើយ។

រឿងព្រេងបានដំណាលថា ក្នុងអំឡុងខែកត្តិក, មិគសិរ និងបុស្ស (វិច្ឆិកា-មករា) ជារដូវធ្លាក់ខ្យល់ពីជើង អ្នកស្រុកត្រូវធ្វើដំណើរពីខាងត្បូងដើម្បីកុំឲ្យឃ្មុំទិច។ ប្រសិនបើដូច្នោះមែន គឺគេអាចគេចពីឃ្មុំទិចនោះបានតែប្រហែល៣ខែប៉ុណ្ណោះ ពោលគឺអំឡុងខ្យល់រដូវបក់មកពីជើង។ ប៉ុន្តែ ចុះចំណែករដូវខ្យល់បក់ពីត្បូងវិញ ក្នុងអំឡុងខែអាសាឍ, ស្រាពណ៍ និងភទ្របទ (កក្កដា-តុលា) ដើម្បីកុំឲ្យឃ្មុំទិច អ្នកស្រុកត្រូវធ្វើដំណើរពីជើងទៅវិញ បើដូច្នោះ ក៏គួរតែមានពាក្យថា "ជើងឃ្មុំ" ដែរទើបសមហេតុផល។ រីឯក្នុងខែចេត្រ និងពិសាខ (មីនា-ឧសភា) ជារដូវខ្យល់រាល់ តើអ្នកស្រុកគួរដើរតាមទិសណាវិញ ទើបឃ្មុំមិនទិច?។ ម៉ាងវិញទៀត បើតាមធម្មជាតិរបស់សត្វឃ្មុំ គឺប្រសិនបើមនុស្ស មិនទៅរុកគួនរំខាន វាក៏មិនមកទិចមនុស្សវិញដែរ។ ម្ល៉ោះហើយ ពាក្យត្បូងឃ្មុំនៅទីនេះក៏ប្រហែលមិនសំដៅលើ "ទិសខាងត្បូង" នេះដែរ។

ផ្អែកលើភូមិសាស្ត្រខេត្តត្បូងឃ្មុំ កាលដើមឡើយ គឺសម្បូណ៌ព្រៃ។ ម្ល៉ោះហើយ សត្វព្រៃគ្រប់ប្រភេទ រួមទាំងឃ្មុំផង ចូលចិត្តអាស្រ័យនៅ ព្រោះសម្បូណ៌ផ្កាឈើព្រៃគ្រប់ប្រភេទ។ កាលពីព្រៃឈើនៅសម្បូណ៌ អ្នកស្រុកនៅតំបន់នោះ ក្រៅពីរបរធ្វើស្រែចម្ការ គឺគេដើររកឃ្មុំ។ វត្ថុដ៏មានតម្លៃរបស់ឃ្មុំដែលអ្នកស្វែងឃ្មុំប្រាថ្នាចង់បាននោះគឺ "ក្បាលទឹកឃ្មុំ" ជាទីប្រមូលផ្តុំដោយទឹកឃ្មុំមានរសផ្អែមឈ្ងុយឆ្ងាញ់ផង និងសម្រាប់

---

[69] វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ១៩៦៧៖ ១៦៣។

[70] វត្ថុជាដុំដូចជាពក មានសាច់រឹងដូចកែវ កើតមានក្នុងសរីរកាយ ឬក្នុងក្បាលនៃសត្វទាំងឡាយ។ សូមអាន៖ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ១៩៦៧៖ ១២៥។

[71] វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ១៩៦៧៖ ១២៥។

ជាឱសថផ្សេងៗផង។ ដូចពោលពីខាងលើរួចមកហើយថា "កបាល" ឬ "ក្ឌាល[72]" ជាពាក្យសំស្ក្រឹត ត្រូវគ្នានឹងពាក្យខ្មែរថា "ត្ឌង"។ ដូច្នេះ ពាក្យថា "ក្ឌាលទឹកឃ្មុំ" ដែលយើងប្រើសព្វថ្ងៃនេះ គឺប្រហែលជាអ្នកស្រុកនៅទីនោះហៅខ្លីថា "ត្ឌងឃ្មុំ" ដូច្នេះក៏មិនដឹង។ អ្វីៗដែលបានធ្វើសេចក្តីបកស្រាយខាងលើនេះ ពុំមែនប្រកាន់ជាច់ណាត់ថាពិតប្រាកដទាំងស្រុងឡើយ គឺគ្រាន់តែជាសេចក្តីសន្និដ្ឋានមួយដែលយើងពិចារណារកហេតុផលឲ្យបានប្រសើរឡើង។

ង. ពិធីឡើងអ្នកតាបេង ឬហែចៅហ្វាយស្រុក

ជំនឿសាសនាហូរចូលមកពីស្រុកក្រៅមានព្រហ្មញ្ញសាសនា និងពុទ្ធសាសនា(ទាំងមហាយាននិងហិនយាន) បន្ទាប់មកពុទ្ធសាសនាថេរវេទ បានវេញបញ្ចូលគ្នាជាមួយជំនឿក្នុងស្រុកដែលសព្វថ្ងៃគេសន្មត់ឈ្មោះថា "ជំនឿជីវចល" ហើយបង្កើតជាប្រព័ន្ធជំនឿតែមួយដែលខ្មែរគោរពប្រតិបត្តិតរៀងមក ដោយពុំមានផលរមាស់អ្វីឡើយ។ អ្នកតាស្ថិតនៅក្នុងជំនឿជីវចលនោះ។ អ្នកតាមិនមែនជាខ្មោចឬអមនុស្សកំបុិក កំប៉ុកទេ គឺជាទេពរក្សសំខាន់នៅឃុំគ្រងស្រុកភូមិ ហើយក៏ជាបាតុភូតុដែលពាក់ព័ន្ធនឹងសហគមន៍មួយឬក៏ប្រជាជនមួយភូមិតែម្តង[73]។ កង្វល់ធំរបស់អ្នកស្រុក គឺធ្វើយ៉ាងណាដើម្បីឲ្យមានភ្លៀងធ្លាក់គ្រប់គ្រាន់សម្រាប់ដំណាំដាំដុះក្នុងជីវភាពរបស់ខ្លួន។ ដូច្នេះក្នុងទស្សនៈជំនឿ ដើម្បីឲ្យមានភ្លៀងនិងទទួលបានភោគផល មនុស្សងាកទៅរកល្បិចឬកិច្ចអ្វីមួយ ពោលគឺ "ពិធីឡើងអ្នកតា" នោះឯង។

"ពិធីហែអ្នកតាបេង" ឬ "ហែចៅហ្វាយស្រុក" ក៏ប្រារព្ធធ្វើក្នុងន័យដូចគ្នានេះដែរ។ តាមសម្តីចាស់-ទុំ នៅទីនោះរៀបរាប់ថា អ្នកតាបេងនេះមានឫទ្ធិបារមីខ្លាំងពូកែណាស់ ស្ត្រីមានផ្ទៃពោះឬអ្នកមានបណ្ណាស័ក្តិពុំហ៊ានដើរកាត់ពីមុខខ្ទមអ្នកតាបេងទេ ដ្បិតនឹងធ្វើឲ្យរលូតកូនឬធ្លាក់បុណ្យពុំខានឡើយ។ ម្ល៉ោះហើយអ្នកស្រុកត្ឌងឃ្មុំមានជំនឿលើអ្នកតាបេងនោះខ្លាំង។ កាលពីសម័យមុន តែកាលណាមានចៅហ្វាយស្រុកថ្មីដែលឡើងមកកាន់ការនៅស្រុកត្ឌងឃ្មុំនេះ គឺគេតែងប្រារព្ធពិធីហែអ្នកតាបេងនេះពុំដែលហ៊ានខកខានឡើយ ដ្បិតបើសិនជាមិនបានធ្វើពិធីនោះទេ គេជឿថានឹងកើតការក្តៅក្រហាយ ឈរជើងនៅស្រុកនេះមិនបានយូរឡើយ។ ចៅហ្វាយស្រុកត្ឌងឃ្មុំកាលពីមុនសម័យបារាំងមានងារជា "ឧកញ៉ាអជ៌ុន" (ហៅក្លាយជា

---

[72] ដូចជ្រាបស្រាប់ហើយថា កាលពីបុរាណពាក្យសំស្ក្រឹត គឺប្រើប្រាស់តែនៅក្នុងព្រះរាជវាំង ឬនៅក្នុងស្រទាប់អភិជនប៉ុណ្ណោះ ហើយបន្តិចម្តងៗទើបជ្រួតជ្រាបទៅក្នុងស្រទាប់ប្រជារាស្ត្រ។ ម្ល៉ោះហើយ នៅពេលដែលឈ្មោះ "ត្ឌងឃ្មុំ" កើត ប្រហែលជាអ្នកស្រុកនៅទីនោះពុំទាន់ស្គាល់ពាក្យ "ក្ឌាល" ជាភាសាសំស្ក្រឹតនេះនៅឡើយទេ។

[73] អាំង ដូលាន, ២០០០៖ ២។

"អរជូន")[74] តែសព្វថ្ងៃ ងារនេះប្រើតែនៅក្នុងវេលាធ្វើពិធីហែអ្នកតាបេងនេះប៉ុណ្ណោះ។ ទំនៀមហែអ្នកតាបេងនេះបានបន្តមកទល់នឹងសព្វថ្ងៃ។

ការកំណត់ឫក្សវេលា

តាមការបែងចែកភូមិសាស្ត្ររដ្ឋបាលសព្វថ្ងៃ ស្រុកត្រូវមកស្ថិតក្រោមចំណុះខេត្តវិញ[75] ម្ល៉ោះហើយទាំងចៅហ្វាយខេត្ត និងចៅហ្វាយស្រុកក៏ធ្វើពិធីហែអ្នកតាបេងនេះដែរ។ ក្រោយពេលពិធីប្រកាសចៅហ្វាយខេត្ត ឬចៅហ្វាយស្រុកថ្មីចូលកាន់តំណែងស្របច្បាប់តាមផ្លូវអាណាចក្ររួចរាល់ គឺនៅមានពិធីសំខាន់មួយទៀតតាមបែបជំនឿ ពោលគឺពិធីហែអ្នកតាបេង (រូបលេខ៖ ៣៨)។ អ្វីដែលសំខាន់ក្នុងការប្រារព្ធពិធីនេះគឺដើម្បីប្រកាសឲ្យអ្នកតាដែលរក្សាទឹកដីស្រុកត្បូងឃ្មុំនេះទទួលស្គាល់។ ពិធីហែអ្នកតាបេងនេះពុំប្រកាន់ថាខែមាឃ, ចេត្រ ឬពិសាខ ដូចពិធីឡើងអ្នកតានៅតំបន់ដទៃទៀតឡើយ ពោលគឺកំណត់រកឫក្ស វេលាបានកាលណាគឺគេធ្វើពិធីពេលនោះ។ របៀបរកឫក្សវេលាគឺដូចនឹងការរកឫក្សវេលាមង្គលការដូច្នោះដែរ ពោលគឺឲ្យអាចារ្យ ឬហោរាគន់គូរ រកឫក្សរាសី តាមរាសីចៅហ្វាយខេត្ត ឬចៅហ្វាយស្រុក។ បន្ទាប់ពីរកបានវេលាមង្គលពីអាចារ្យហើយ ចៅហ្វាយស្រុក ឬចៅហ្វាយខេត្តថ្មីក៏នាំវេលានោះទៅជួបរូបស្នង ដើម្បីអញ្ជើញអ្នកតាបេងមកឆ្លងឆ្លើយកំណត់វេលាហែ។ ត្រង់នេះប្រសិនបើវេលាដែលអាចារ្យកំណត់នោះពុំត្រូវគ្នានឹងវេលារបស់រូបស្នងអ្នកតាទេ គឺនឹងត្រូវរកម្តងទៀត ធ្វើយ៉ាងណាទាល់តែឫក្សវេលាត្រូវគ្នាទាំងសងខាង។

---

[74] ប្រទេសកម្ពុជាកាលពីអតីតបែងចែកជាដែនដី (ឬស្រុក) ធំៗចំនួន៥ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ស្តេចត្រាញ់៥ដែរ ពោលគឺស្រុកកំពង់ស្វាយ ស្ថិតក្រោមការគ្រប់គ្រងរបស់ឧកញ៉ា តេជោ, ស្រុកទ្រាំង គឺឧកញ៉ា ពិស្ណុលោក, ស្រុកត្បូងឃ្មុំ គឺឧកញ៉ាអជ្ញុន, ស្រុកបាភ្នំ គឺឧកញ៉ាធម្មាតេជោ និងស្រុកពោធិ៍សាត់ គឺឧកញ៉ា សួគ៌ាលោក។ ថ្វីដ្ឋិតតែគេមិនដឹងប្រាកដថាការបែងចែកនេះចាប់ផ្តើមឡើងនៅពេលណា តែតាមរយៈឯកសាររបស់លោក ម៉ក់ ភឿន ធ្វើឲ្យគេយល់ថា ការបែងចែកនេះមិនទាន់កើតមាននៅឡើយទេនៅដើមសតវត្សទី១៧ (សូមអាន MAK Phoeun, 1981ដកស្រង់ក្នុង VICKERY Michael, 1999, "The 16th – 17th centuries..., p. 12)។ ដូច្នេះ សូមចងចាំថា កាលពីអតីតពាក្យថា "ស្រុក" គឺមានវិសាលភាពភូមិសាស្ត្រនោះធំធេងណាស់ ពោលគឺធំជាង វិសាលភាព "ខេត្តសព្វថ្ងៃ"រាប់សិបដង។

[75] ការបែងចែករចនាសម្ព័ន្ធភូមិសាស្ត្ររដ្ឋបាលនេះប្រហែលកើតឡើងនៅក្នុងសម័យអាណាព្យាបាលបារាំង (ចុងស.វ.ទី១៩)។

រូបលេខ៣៨៖ ពិធីប្រកាសតំណែងចៅហ្វាយស្រុកថ្មីគឺ អ្នកស្រី សឹក ណៃសយកាលពីឆ្នាំ២០១០ (ប្រភពរូប៖ សឹក ណៃសយ, ២០១០)

អ្នកជ្រោមជ្រែង

បន្ទាប់ពីកំណត់វេលាត្រឹមត្រូវហើយ តាអាចារ្យ សាច់ញាតិ និងសាមីខ្លួនក៏រៀបចំចាត់ចែងពិធីនៅផ្ទះ។ កិច្ចការសំខាន់ដែលត្រូវរៀបចំ គឺស្វែងរកក្រុមភ្លេងអារក្ស ហើយអ្វីដែលសំខាន់ទៀតនោះ គឺរកអ្នកសែងគ្រែស្នែងចំនួន៨នាក់ និងពេជ្ឈឃាដ ដែលទាំងអ្នកសែង និងអ្នកពិឃាដនោះត្រូវតែជា "អ្នកងារ[76]" ។ ចំណែករូបស្នង និងអ្នកភូមិទាំងចាស់ក្មេងជួយរៀបចំសម្អាត និងតុបតែងរោងពិធីនៅទួលអ្នកតាបេង។ ការងារទាំងនេះពុំមាននរណាមកបញ្ជាឲ្យធ្វើឡើយ តែជាទំនៀមពីបុរាណមកដែលអ្នកស្រុកតែងតែមកជួយបែបនេះ។ គ្រឿងរណ្ដាប់គេច្បាស់ជាឆ្ងល់ថា ហេតុអ្វីត្រូវរកពេជ្ឈឃាដ? នេះបើតាមចាស់ៗនៅតួងឃ្ញុំនៅចងចាំ និងនិយាយប្រហាក់ប្រហែលគ្នាអំពីរឿងដំណាលតៗមកថា កាលពីសម័យបុរាណ ពេលឡើងអ្នកតាម្ដងៗ គេតែងធ្វើពិធីសែនព្រេនដោយមានកាប់មនុស្សថ្វាយអ្នកតា។ មនុស្សដែលយកមកសម្លាប់ថ្វាយអ្នកតានោះ គឺជាអ្នកទោសអស់ ជីវិត។ នៅប៉ុន្មានថ្ងៃមុននឹងយកមកថ្វាយអ្នកតា គេរៀបចំឲ្យអ្នកទោសនោះផឹកស៊ីម្ហូបឆ្ងាញ់ៗតាមអំពើចិត្ត។ ដល់ថ្ងៃប្រហារជីវិត អ្នកទោសនោះតុបតែងកាយស្អាតបាតព្រមទាំងពាក់ធ្មេញមាសពេញមាត់។ គេឲ្យអ្នកទោសនោះអង្គុយនៅកណ្ដាលចំណោមមនុស្សពីមុខអ្នកតា

[76] តាមសម្ដីអ្នកស្រុកនិយាយតាមបែបរឿងព្រេងថា "អ្នកងារ" គឺជាអ្នកដែលត្រូវព្រះរាជាដាក់ទោស ដ្ឋិតទៅចូលរួមស៊ីការនាងទាវនិងម៉ឺនងួននិងអ្នកទាំងឡាយណាដែលគេទូងស្គរឮទៅដល់។ អ្នកស្រុកជឿថា ពូជពង្សអ្នកងារបានបន្តមានខ្លះមកទល់សព្វថ្ងៃ។

បេង។ ក្រោយពីរូបស្នងធ្វើកិច្ចសូត្រធម៌ចប់ គេក៏នាំអ្នកទោសនោះទៅប្រហារជីវិត។ សាកសពក្រោយពីប្រហារ គឺកប់នៅលើទួលអ្នកតាបេងនោះ ដោយមិនឲ្យសាច់ញាតិយកទៅណាឡើយ។

លុះក្រោយមកទៀត ទំនៀមនេះបានប្តូរពីការសម្លាប់មនុស្ស មកសម្លាប់សត្វក្របីវិញ ដែលអ្នកស្រុកហៅថា "ថ្វាយក្របីគ្រលែង"។ ក្របីនោះមានតុបតែងដោយចងផាហ៊ីមពណ៌ខ្មៅនៅនឹងក។ ក្រោយមកទៀត សូម្បីតែសត្វក្របីនោះក៏គេលែងសម្លាប់ដែរ គឺបន្ទាប់ពីចប់ពិធីគេបានប្រគល់សត្វក្របីនោះទៅឲ្យចៅអ្នកតាបេង[77]យកទៅប្រើ។ លំដាប់ក្រោយៗមកទៀតរហូតមកដល់សព្វថ្ងៃ តង្វាយសត្វក្របីនោះក៏បានបំព្រួញមកនៅត្រឹមថ្វាយសាច់ក្របីជ្រនួចប៉ុណ្ណោះ។

ក្រៅពីសំណែនសាច់ក្របីជ្រនួចគឺមានគ្រឿងរណ្តាប់ផ្សេងៗទៀតដូចជាបាយស្រី(បាយសី), ទៀន, ធូប, ម្ហូ-ស្លា, ស្រាជាដើម។ កាលពីឆ្នាំ២០០៤ ពេលគឺនៅពេលដែលលោក ស៊ីម ស៊ីថូវ ឡើងធ្វើជាចៅហ្វាយស្រុកនោះ រូបស្នងអ្នកតាបេងបានបង្គាប់ឲ្យរៀបទ្រនឹបដូចជា៖ សំពត់ហូល, ក្រណាត់ស, ក្រមា, មាស២ដី, ក្របី១ និងសាច់ជ្រនួចក្របីចំនួន៥២ចង្កាក់។ ក្នុងពិធីនោះក៏មានភ្លេងអារក្ស ដែលមានស្គពី៣ទៅ៦ សម្រាប់ប្រគុំឡើងរោង និងបញ្ជាន់មេសម្ងិង(ឬមេស្ទិង)។

ពិធីហែ

"ហែអ្នកតាបេង" ជាទំនៀមនៃកិច្ចពិធីមួយធ្វើចំពោះតែចៅហ្វាយស្រុក ឬចៅហ្វាយខេត្តដែលទើបឡើងកាន់ដំណែងថ្មី។ ពិធីហែនោះធ្វើជាឱឡារឹក ពេលគឺដើម្បីប្រកាសដំណឹងដល់ប្រជាពលរដ្ឋផង និងដល់ពពួកអមនុស្សដែលឃុំគ្រងរក្សានៅដែនដីស្រុកត្បូងឃ្មុំផង។ ពិធីហែអ្នកតាបេងប្រព្រឹត្តិទៅមានរយៈពេលពីរថ្ងៃ គឺនៅរសៀលថ្ងៃទីមួយសន្ទតជាថ្ងៃ"ចូលរោង" មានកិច្ចពិធីសូត្រមន្តតាមបែបព្រះពុទ្ធសាសនា និងពិធីប្រុងពលី(សែនក្រុងពលី) ដែលធ្វើនៅឯផ្ទះចៅហ្វាយស្រុក ឬចៅហ្វាយខេត្តថ្មី។ ដល់ស្អែកឡើងពេលព្រឹកជាថ្ងៃទី២ គឺជាកិច្ចពិធីហែចៅហ្វាយស្រុកឆ្ពោះទៅកាន់ទួលអ្នកតាបេង។ តាមប្រសាសន៍លោកតា ជួប សំអឿន ថាកិច្ចពិធីហែអ្នកតាបេងនេះ គឺរៀបចំនិងផ្តើមចេញដំណើរពីមុខបរិវេណខ្ទមអ្នកតាពោធ៍ធំ[78] ដែលស្ថិតនៅភូមិជីកែ(រូបលេខ៖ ៣៩)។ មុនពេលហែ គឺគេប្រគុំភ្លេងអារក្សចំនួន៣បទ និងមានបាញ់កាំភ្លើងវែង-ខ្លីចំនួន៣ គ្រាប់សំដៅទៅទិសខាងកើត។ បន្ទាប់មក ចៅហ្វាយស្រុក ឬចៅហ្វាយ

---

[77] អ្នកស្រុកជឿថា អ្នកតាបេងដែលភប់ប្រសព្ធជាមួយប្អូនស្រីលោកចៅអធិការវត្ត ក៏បានជាកូនចៅ ហើយបន្តពូជពង្សរបស់ខ្លួនរហូតមក។ ពិធីនោះកាលពីបុរាណ គឺកូនចៅអ្នកតាបេងនោះឯងដែលជាអ្នកចងដៃនិងប្រោះព្រំដល់ចៅហ្វាយស្រុកដែលធ្វើពិធីឡើងអ្នកតាបេង។

[78] ខ្ទមអ្នកតាពោធ៍ធំកាលពីបុរាណសង់នៅក្រោមដើមពោធ៍មួយស្ថិតនៅកណ្តាលភូមិជីកែ។ ត្រង់ដើមពោធ៍នេះ មានផ្លូវបែកជាបួន ចេញទៅរកទិសទាំងបួន (ទិសលិច, កើត, ជើង, ត្បូង)។ សព្វថ្ងៃ ពុំមានដើមពោធ៍ទៀតទេ គឺមានតែដើមជ្រៃដុះត្រង់ទីដើមពោធ៍នោះ ហើយអ្នកភូមិបានកសាងខ្ទមអ្នកតាពីបេតុង ស្ថិតនៅក្បែរដើមជ្រៃនោះ។

ខេត្តក៏ឡើងអង្គុយនៅលើគ្រែស្នែង ដែលសែងដោយអ្នកងារជាមនុស្សប្រុសចំនួន៨នាក់[79] ហើយហែចេញទៅ។ អ្នកងារទាំង៨នាក់ស្លៀកពាក់ពណ៌ក្រហម និងមានជួតក្បាល ដោយក្រណាត់ជាតីដូចៗគ្នា(រូបលេខ៖ ៤០-៤១)។ នៅពីមុខក្បួន មានមនុស្សប្រុសម្នាក់ដែលដៃខាងស្តាំកាន់ដាវវែងមួយ ដើរគ្រវីឆ្វេងស្តាំនាំមុខ។

រូបលេខ៣៩៖ ខ្ទមអ្នកតាពោធិ៍ធំជាទីដែលគេផ្តើមហែចៅហ្វាយស្រុក។
គេត្រូវរៀបចំសែនព្រេននៅទីនេះរួចរាល់ទើបហែចេញទៅ។(ប្រភពរូប៖ សាន ផល្លា)

រូបលេខ៤០៖ចៅហ្វាយស្រុកចេញពីបន់ស្រន់នៅវត្ត
(ប្រភពរូប៖ សឹក ណៃសយ, ២០១០)

រូបលេខ៤១៖ ចៅហ្វាយស្រុកតែងតាំងថ្មីអង្គុយលើគ្រែស្នែងដែលសែងដោយអ្នកងារ(ស្លៀកពាក់ពណ៌ក្រហម) ហែទៅកាន់ទីទួលអ្នកតាបេងដើម្បីប្រារព្ធពិធីឡើងអ្នកតាបេង (ប្រភពរូប៖ សិត ណៃសយ, ២០១០)

[79] តាមលោកតា ជួប សំអឿន ថា អ្នកងារទាំងនោះជ្រើសរើសមកពីភូមិជីកែ, ភូមិជ្រោយ ឬក្រុងសួង។

ក្ជួនដង្ហែចេញដំណើរឆ្ពោះទៅទិសខាងកើត សំដៅចេញទៅក្រៅភូមិ។ បន្ទាប់មកបត់អែបមកជ្រុងអាគ្នេយ៍។ តាំងពីបុរាណមក ពិធីហែអ្នកតាបេង ហាមដាច់ខាតមិនឲ្យហែកាត់តាមភូមិឡើយ គឺហែខាងក្រៅភូមិ និងកាត់តាមវាលស្រែ។ នៅតាមបណ្តោយផ្លូវហែចន្លោះអ្នកតាពោធិ៍ធំ និងអ្នកតាបេង មានអ្នកតាចំនួន៣ផ្សេងទៀត គឺអ្នកតាឫសច្រើន, អ្នកតាមាស (ឬអ្នកតាកំពូលមាស) និងអ្នកតាសាអ៊ុំ (ឬអ្នកតាអណ្តូងជ្រោយ) (រូបលេខ៖ ៤២-៤៣)។ ក្ជួនដង្ហែត្រូវឈប់ដើម្បីធ្វើពិធីបូងសួងនៅមុខខ្ទមអ្នកតាទាំងបីដែលមានរៀបចំគ្រឿងតង្វាយដូចៗគ្នារួចជាស្រេច។ នៅមុនពេលចេញដំណើរពីខ្ទមអ្នកតានីមួយៗ គេបាញ់កាំភ្លើងមួយគ្រាប់(ខ្លះថាបាញ់៣គ្រាប់) សំដៅទៅទិសខាងកើតដូចៗគ្នា។ នៅពេលក្ជួនដង្ហែទៅដល់ទួលអ្នកតាបេង គេមិនហែចូលពីខាងកើតត្រង់តែម្តងទេ ដ្បិតមិនហ៊ានកាត់ពីមុខអ្នកតាបេង ពោលគឺត្រូវវ៉ាងទៅទិសខាងត្បូង ហើយចូលពីខាងលិចខ្ទមអ្នកតាមកវិញ[80]។ មុនពេលហែចូល គេបាញ់កាំភ្លើងចំនួន១២គ្រាប់ទៅទិសខាងកើត។ បន្ទាប់មក ចៅហ្វាយស្រុកចុះពីគ្រែស្នែងមកធ្វើពិធីបូងសួងទៅតាមអ្វីដែលបង់បត់(តាមរយៈរូបស្នង)ប្រាប់។ នៅពេលនោះហើយដែលគេហៅចៅហ្វាយស្រុកថា "ឧកញ៉ាអរជូន"។ រូបស្នងនោះក៏ចាត់ចែងពិធីបូងសួងតាមទំនៀមពីបុរាណ ដោយមានទាំងការពិយាដមនុស្ស ឬសត្ត (កាលពីសម័យបុរាណ)។ រូបស្នងនោះក៏ប្រាប់ទៅចៅហ្វាយខេត្ត ឬចៅហ្វាយស្រុកថ្មីនោះឲ្យមើលស្រុកទេស និងប្រជាជន បានសុខសប្បាយ។ ចុងបញ្ចប់ ចៅអ្នកតាបេងក៏ចងដៃនិងប្រោះព្រំទឹកមន្តដល់ឧកញ៉ាអរជូន និងអ្នកហែហម ព្រមទាំងប្រជាជនដែលបានចូលរួម។ អ្នកចូលរួមទាំងអស់ក៏បរិភោគសាច់ក្របីនិងអាហារជុំគ្នានៅទីទួលអ្នកតាបេងនោះប្រកបដោយក្តីសប្បាយរីករាយនិងស្និទ្ធស្នាល។

[80] តាមប្រសាសន៍របស់លោកតា អ៊ីម អៀម ថា កាលពីមុន ខ្ទមអ្នកតាបេងសង់នៅកណ្តាលទួល បែរមុខទៅទិសខាងកើត។ ក្រោយមកមានគ្រូបង់បត់ម្នាក់ឈ្មោះ អ៊ីម ប្រុស ក៏បានសាងរូបអ្នកតាបេងនិងខ្ទមអ្នកតាថ្មីពីបេតុង ហើយដាក់បែរមុខឆ្ពោះទៅទិសខាងត្បូងវិញ។



រូបលេខ៤៤៖ ...បន្ទាប់ពីហែចេញពីអ្នកតាពោធិ៍
គឺត្រូវមកឈប់ធ្វើកិច្ចនៅខ្នមអ្នកតាឫសច្រើន
(ប្រភពរូប៖ សាន ផល្លា, ២០១៥)

រូបលេខ៤៥៖ ...ក្បួនដង្ហែក៏មកឈប់ដើម្បីធ្វើ
ពិធីបួងសួងនៅខ្នមអ្នកតាមាស ឬអ្នកតាកំពូលមាស
(ប្រភពរូប៖ សាន ផល្លា, ២០១៥)

រូបលេខ៤៦៖ ផ្លូវរ៉ាងភូមិចេញពីអ្នកតាមាស
មកកាន់អ្នកតាសាអ៊ុំ (ឬអ្នកតាអណ្តូងជ្រោយ)
(ប្រភពរូប៖ សាន ផល្លា, ២០១៥)

រូបលេខ៤៧៖ អ្នកតាសាអ៊ុំ (ឬអ្នកតាអណ្តូងជ្រោយ)។
បន្ទាប់ពីបន់ស្រន់រួច ពីមុនគេត្រូវហែរចៅហ្វាយស្រុក
តាមវាលស្រែនេះ(ប្រភពរូប៖ សាន ផល្លា, ២០១៥)

រូបលេខ៤៨៖ ...ប៉ុន្តែសព្វថ្ងៃ គេហែតាមផ្លូវថ្មីនេះវិញ (ប្រភពរូប៖ សាន ផល្លា, ២០១៥)។

រូបលេខ៤៩៖ ...រួចក៏ហែតាមផ្លូវនេះកាត់វាលស្រែតម្រង់ទៅកាន់ទីទួលអ្នកតាបេង (ប្រភពរូប៖ សាន ផល្លា, ២០១៥)។

ជំពូកទី៣

សាវតារខេត្តត្បូងឃ្មុំតាមរយៈឯកសារផ្សេងៗ

យោងលើឯកសារជាសំណេរនានា ទាំងភាសាខ្មែរ និង ភាសាសាសន៍ដទៃឃើញថា ត្បូងឃ្មុំធ្លាប់ជាស្រុកផងនិងជាខេត្តផង ក្នុងចំណោមស្រុកនិងខេត្តជាច្រើនទៀតរបស់ខ្មែរ ដែលគេស្គាល់ជាទូទៅចាប់ពីសម័យក្រោយអង្គរមក។ ឯកសារទាំងនោះមានដូចជាសិលាចារឹក, ព្រះរាជពង្សាវតារ, ទស្សនាវដ្ដី និងឯកសារដែលសរសេរឬនិពន្ធ ដោយជនបរទេស។ល។ ទាក់ទងនឹងឈ្មោះស្រុកឬខេត្តខាងលើ យើងសូមលើកយកប្រភពឯកសារសំខាន់ពីរមកអធិប្បាយត្រួសៗ ដើម្បីបញ្ជាក់ពីសាវតារនៃខេត្តនេះ។ ឯកសារទីមួយសរសេរជាភាសាខ្មែរ និងឯកសារទីពីរសរសេរជាភាសាបរទេស ដែលបានបោះពុម្ពផ្សាយមានកាលបរិច្ឆេទច្បាស់លាស់។

១. ឈ្មោះខេត្តត្បូងឃ្មុំតាមរយៈឯកសារជាភាសាខ្មែរ

សិលាចារឹកគឺជាឯកសារសំណេរដំបូងបង្អស់ ដែលរៀបរាប់អំពីរឿងរ៉ាវកើតមានពីអតីតកាល ដូចជាឈ្មោះរបស់ព្រះរាជា, កាលបរិច្ឆេទនៃការសាងប្រាសាទ, ការធ្វើអំណោយទៅដល់ប្រជារាស្ត្រ ព្រមទាំងព្រឹត្តិការណ៍សំខាន់ទាក់ទងការឡើងគ្រងរាជ្យរបស់ព្រះរាជា។ល។ហើយសិលាចារឹកទាំងនោះភាគច្រើនចារក្នុងសម័យអង្គរ។ នៅសម័យក្រោយអង្គរក៏មានសិលាចារឹកដែរ ដែលភាគច្រើនគេប្រទះឃើញនៅ ក្នុងប្រាសាទអង្គរវត្ត។ សិលាចារឹកទាំងនោះខ្លះចារដោយមន្ត្រី ហើយខ្លះទៀតចារដោយរាជវង្ស នៅពេលទៅកាន់អង្គរ ដើម្បីប្រារព្ធពិធីផ្សេងៗ បន្ទាប់ពីបានទទួលការតម្លើងបុណ្យសក្ដិ ឬលាភសក្ការៈផ្សេងៗ[81]។ តួយ៉ាងដូចជាសិលាចារឹកមួយមានលេខសម្គាល់ IMA ៣៨ ចារដោយលោក ជ័យនន្ទក្នុងឆ្នាំ១៧០១ គឺជាសិលាចារឹក៣ក្យកាព្យ ដែលរៀបរាប់ពីតួនាទីរបស់គាត់ កាលពីដំបូងគឺជាអភិបាល ខេត្តតូចមួយនៅព្រៃក្ដី[82]។ លុះក្រោយមកគាត់បានឡើងឋានៈជាអ្នកដឹកនាំនៅខេត្តត្បូងឃ្មុំ ដែលមានងារជាស្ដេចត្រាញ់ "**អរជ្ជុន**"[83] ។

បន្ទាប់ពីសិលាចារឹក ព្រះរាជពង្សាវតារគឺជាប្រភពឯកសារដ៏សំខាន់សម្រាប់ស្វែងយល់ពី រឿងរ៉ាវផ្សេងៗដែលបានកើតមានឡើងនៅក្នុងសង្គមខ្មែរនាសម័យ អតីតកាលពិសេសនៅក្នុង សម័យក្រោយ

---

[81] ម៉ាយឃើល វ៉ីកឃីរ៉ី, ប្រវត្តិសាស្ត្រ កម្ពុជា, ២០០៦-២០០៧. P. ២៣០-២៣១

[82] ក្នុងឆ្នាំ១៨៩៧ ខេត្តព្រៃក្ដីស្ថិតនៅជាប់ព្រំប្រទល់ជាមួយខេត្តកំពង់ស្វាយនិងខេត្តសន្ទុក ដោយមានស្ទឹងសែនជាខណ្ឌសីមា។ សព្វថ្ងៃខេត្តព្រៃក្ដី ប្រហែលស្ថិតក្នុងទឹកដីនៃខេត្តកំពង់ធំ។

[83] ដូចគ្នាជាមួយលេខ១៤២

អង្គរ។ បើទោះបីរឿងរ៉ាវខ្លះពិតឬប្រឌិតក្តី តែអ្នកនិពន្ធសរសេរឡើងដោយផ្អែកលើកត្តាសំខាន់ៗដូចកត្តាធម្មជាតិ ភូមិសាស្ត្រ ព្រឹត្តការណ៍ផ្សេងៗ រួមផ្សំជាមួយរឿងព្រេងនិទាន ហើយបង្កើតបានដំណើររឿង ដែលផ្សារភ្ជាប់ទៅនឹងស្ថានភាពជាក់ស្តែងនៅក្នុងសង្គម។ នៅក្នុងព្រះពង្សាវតារ គឺមានសរសេររៀបរាប់ទាក់ ទងទៅនឹងឈ្មោះភូមិ ស្រុក ខេត្ត ជាច្រើន តាមរយៈដំណើររឿង ដែលគេយល់ថារឿងរ៉ាវទាំងនោះ ទំនង ជាកើតមានពិតប្រាកដនៅតាមភូមិ ស្រុក ខេត្តទាំងនោះ។ តួយ៉ាងខេត្តត្បូងឃ្មុំគឺមានឈ្មោះបោះសំឡេងតាមរយៈរឿងទុំទាវ ដែលជាស្នាដៃអក្សរសិល្ប៍ដ៏ល្បីល្បាញ និងមានប្រវត្តិដ៏យូរលង់ ហើយមានមនុស្សស្ទើរពេញមួយនគរយល់ថា ជារឿងពិតកើតមាននៅលើទឹកដីខេត្តត្បូងឃ្មុំប្រាកដមែន។ រឿងពោរពេញដោយមនោសញ្ចេតនាដ៏ជ្រាលជ្រៅនិងមានប្រជាប្រិយភាពមួយនេះ គេយកមកចុះផ្សាយក្នុងព្រឹត្តបត្រ ឬទស្សនាវដ្ដីនានាដូចជា កម្ពុជសូរិយានិងឯកសារប្រវត្តិសាស្ត្រដទៃទៀតជាច្រើន។ មិនតែប៉ុណ្ណោះរឿងទុំទាវក៏ទទួលបានការចាប់អារម្មណ៍ពីអ្នកស្រាវជ្រាវមកពីបស្ចិមប្រទេស ហើយពួកគេបានប្រែសម្រួលខ្លឹមសារនៃខ្សែរឿងនេះ ពីភាសាខ្មែរទៅជាភាសារបស់គេថែមទៀត។ ព្រះរាជពង្សាវតារចាស់ជាងគេ ដែលមានរៀបរាប់អំពីឈ្មោះខេត្តត្បូងឃ្មុំ គឺចេញផ្សាយនៅឆ្នាំ១៨១៨ ក្នុងរាជព្រះបាទអង្គចន្ទទី២ (១៨០៦-១៨៣៤) និងព្រះរាជពង្សាវតារចេញផ្សាយចុងក្រោយនៅឆ្នាំ១៩៦៦ ក្នុងពេលដែលព្រះនរោត្តមសីហនុឡើងគ្រងរាជ្យសម្ផត្តិ(១៩៤១-១៩៧០)[84]។ ប៉ុន្តែមានឯកសារខ្លះបានលើកឡើងថា រឿងទុំទាវ បានតាក់តែងឡើងប្រហែលតាំងពីឆ្នាំ១៥៥៧ គឺមុនពេលបែកបន្ទាយលង្វែកនាឆ្នាំ១៥៩៤[85]។ ដូច្នេះ បើផ្អែកលើ ស្នាដៃនៃរឿងទុំទាវ យើងអាចសន្និដ្ឋានបានថា ខេត្តត្បូងឃ្មុំត្រូវបានគេស្គាល់យ៉ាងហោចណាស់ចាប់តាំងពីសម័យលង្វែកនាសតវត្សទី១៦ឯណោះ។

ក្រៅពីរឿងទុំទាវ នៅមានរឿងដទៃទៀត ដូចជារឿងហ្លួងព្រះស្ដេចកន ដែលជានិទានកថាបែបប្រវត្តិសាស្ត្រមួយដ៏ល្បីល្បាញ របស់ខ្មែរនាសម័យក្រោយអង្គរ ក៏មានរៀបរាប់អំពីខេត្តត្បូងឃ្មុំដែរ ដ្បិត នៅទីនោះគឺជារាជធានីមួយ ដែលតាមឯកសារមានឈ្មោះថា «បន្ទាយព្រៃនគរ»[86]។ រីឯឯកសារប្រវត្តិសាស្ត្រវិញមានច្រើនសន្ធឹកសន្ធាប់ មិនថាភាសាខ្មែរ ឬភាសាបរទេស ដែលសរសេរអំពីព្រឹត្តិការណ៍ដែលកើតមាននៅក្នុងប្រទេស ពិសេសចាប់ពីសម័យក្រោយអង្គរនៅរវាងសតវត្សទី១៥ដល់ដើមសតវត្សទី១៩ គឺ សុទ្ធតែមានលើកឡើងអំពីឈ្មោះខេត្តត្បូងឃ្មុំ។ បើទោះជាមានការលើកឡើងអំពីឈ្មោះស្រុកឬខេត្តត្បូងឃ្មុំ ក៏ពិតមែន ប៉ុន្តែពុំមានឯកសារណាមួយបញ្ជាក់ឲ្យច្បាស់លាស់ពីឯកសាររដ្ឋបាលស្ដីពីការបង្កើតខេត្តជាផ្លូវ ការ និងផែនទីនៃខេត្តនេះឡើយ។ លុះដល់ប្រទេសស្ថិតក្រោមអាណាព្យាបាលបារាំង ទើបឃើញមាន ឯកសារ និងផែនទីគូរដោយដៃបង្ហាញពីទីតាំងខេត្តត្បូងឃ្មុំ ព្រមទាំងខេត្តដទៃទៀតជាច្រើននាសម័យ កាលនោះ។

---

[84] GEORGE Chigas, 2005, 4

[85] *Ibit*

[86] សូមអាន រស់ ចន្ទ្រាបុត្រ, ហ្លួងព្រះស្ដេចកន

តាមព្រះរាជពង្សាវតារដដែល បើពិនិត្យទៅលើវិស័យរដ្ឋបាល និងនយោបាយវិញឃើញថា មុនពេលដាក់ប្រទេសឲ្យស្ថិតក្រោមការត្រួតត្រារបស់បារាំង ដែនដីខ្មែរទាំងមូលដែលកាលណោះមានទំហំធំធេងជាងសព្វថ្ងៃ មានការបែងចែកជាតំបន់ធំៗ ដែលមួយចំនួនហៅថា "ដី"[87] ហើយដីនីមួយៗ មានពី៦ទៅ១០ខេត្ត[88]គ្រប់គ្រងផ្ទាល់ដោយព្រះរាជា,ឧបរាជនិងព្រះរាជមាតា។ឧបរាជគ្រប់គ្រងដីដែលមាន៥ ខេត្ត ព្រះរាជមាតារបស់ព្រះរាជាគ្រប់គ្រងដីដែលមាន៣ខេត្ត។ ក្រៅពីនេះមានខេត្ត៤៩ផ្សេងទៀត ត្រូវបែងចែកជាដីចំនួន៦ ហើយស្ថិតក្រោមការគ្រប់គ្រងផ្ទាល់ដោយព្រះរាជា[89]។ បើតាមឯកសារខ្លះសរសេរថា នៅមុនពេលមានការវាយដណ្តើមកាន់កាប់ទឹកដីពីសំណាក់សៀមនិងយួន ព្រះរាជាណាចក្រទាំងមូលមានជាង១០តំបន់ លុះដល់ឆ្នាំ១៨៧៥ មានត្រឹមតែ៥តំបន់ប៉ុណ្ណោះ[90] រីឯខេត្តវិញមានទៅដល់ជាង៧០ ខេត្ត ឯណោះ[91]។ ស្ថិតនៅក្រោមអំណាចត្រួតត្រារបស់ខ្សែរាជវង្សនាសម័យនោះ ដីនីមួយៗគឺត្រូវព្រះរាជាប្រគល់ទៅឲ្យមន្ត្រីជាន់ខ្ពស់ ដែលកាលណោះគេហៅថា«ស្តេចត្រាញ់»[92]ជាអ្នកគ្រប់គ្រង៖ ជាក់ស្តែងនៅក្នុងរាជ្យរបស់ព្រះបាទស្រីធម្មរាជា(១៦២៩-១៦៣០) បានតែងតាំងស្តេចត្រាញ់៥រូបឲ្យត្រួតត្រាដែន ដីចំនួន៥គឺ៖ ដីត្បូងឃ្មុំគ្រប់គ្រងដោយឧកញ៉ាអរជួន, ដីកំពង់ស្វាយគ្រប់គ្រងដោយឧកញ៉ាតេជោ, ដីទ្រាំងត្រួតត្រាដោយឧកញ៉ាពិស្ណុលោក, ដីពោធិ៍សាត់ត្រួតត្រាដោយឧកញ៉ាសួគ៌ាលោក និងដីបាភ្នំត្រួតត្រាដោយឧកញ៉ាធម្មាតេជោ[93]។ នៅក្នុងរាជ្យព្រះបាទអង្គឌួង ស្តេចត្រាញ់មានសិទ្ធិអំណាចកាន់តែខ្លាំងឡើង ត្បិតជាអ្នកចាត់ចែងនិងបញ្ជាផ្ទាល់លើចៅហ្វាយខេត្តទាំងអស់ស្ថិតក្នុងដីដែលខ្លួនកាន់កាប់។ សិទ្ធិអំណាច នេះបានជំរុញឲ្យស្តេចត្រាញ់ពង្រីកឥទ្ធិពលនៅក្នុងដីដែលខ្លួនគ្រប់គ្រងកាន់តែធំឡើងៗពីមួយថ្ងៃទៅមួយថ្ងៃ។ ព្រឹត្តិការណ៍ បែបនេះបានបង្កជាក្តីកង្វល់ដល់ព្រះរាជា ព្រោះស្តេចត្រាញ់ទាំងនោះអាចនឹង ងើបបះបោរប្រឆាំងនឹងបញ្ជារបស់ព្រះអង្គនាពេលណាមួយជាមិនខាន។ ដើម្បីចៀសវាងគ្រោះថ្នាក់ដល់ រាជបល្ល័ង្ក ព្រះ

---

[87] ដីកាលណោះមានន័យថា ជាអង្គភាពរដ្ឋបាលធំមួយ ដែលព្រះរាជាប្រគល់មន្ត្រីជាន់ខ្ពស់គ្រប់គ្រង ដើម្បីជាប្រយោជន៍ ដល់រាជសម្បត្តិ ហើយស្ថិតក្រោមការត្រួតពិនិត្យពីមន្ត្រីរបស់ស្តេច។

[88] ភាសាសំស្ក្រឹត «ក្សេត្រ» មានន័យថាមានដែនកំណត់ឬព្រំ ខណ្ឌ ច្បាស់លាស់។ ភាសាខ្មែរបុរាណមានន័យថា" ស្រែ វិស័យ វិស័យទេព (ប្រាសាទ) ទីគោរពសក្តារ: ទេពជាដើម" (សេចក្តីពន្យល់ទាំងអស់ខាងលើដកស្រង់ចេញពីអត្ថបទរបស់លោក Grégory MIKAELIAN ស្តីអំពី Note sur la première cartographie provincial Cambodgienn (c. 1897) បោះពុម្ពទស្សនាវដ្ដី Péninsule no 54-2007(1)

[89]

[90] គឹម ណារិន, ប្រវត្តិស្ថាប័នខ្មែរ, ឆ្នាំ?

[91] ពៅ សារឿន, ប្រវត្តិស្ថាប័នខ្មែរ, ឆ្នាំ២០១១

[92] ពាក្យត្រាញ់ឬក្រាញ់ ក្លាយមកពីពាក្យបុរាណថា ម្រតាញ ដែលមានចារនៅសិលាចារឹកខ្មែរនាសម័យអង្គរ(ត្រឹង ងារ: ១៧៦)

[93] អេង សុត ១៩៦៩, ម៉ាយឃើល រ៉ូកឃ្លីរ ២០០១-២០០២, Mak Phoeun 1984

រាជាបានចាប់ផ្តើមដកហូតអំណាចពីញាតិវង្សានុវង្សនិងស្តេចត្រាញ់បន្តិចម្តងៗ ហើយប្រគល់សិទ្ធិអំណាចទៅឲ្យមន្ត្រីជាន់ខ្ពស់ដែលមានកក្តីភាពជាមួយព្រះអង្គជាអ្នកគ្រប់គ្រងវិញ។ដូច្នេះហើយ នៅដើមសតវត្សទី ១៩ ស្តេចត្រាញ់បានបាត់បង់ឥទ្ធិពលនៅលើដែនដីដែលខ្លួនគ្រប់គ្រង ហើយចាប់តាំងពីនោះមកស្តេចត្រាញ់គ្រាន់តែមានឋានៈខ្ពង់ខ្ពស់ជាកិត្តិយសពីលើចៅហ្វាយខេត្តប៉ុណ្ណោះ។

១.២. ឯកសារជាភាសាបរទេស

ឯកសារជាភាសាបរទេសមានច្រើនណាស់ដែលសរសេររៀបរាប់អំពីព្រឹត្តិការណ៍សំខាន់ៗកើតមាននៅលើទឹកដីនៃខេត្តត្បូងឃ្មុំ ស្រដៀងទៅនឹងការពិពណ៌នា នៅក្នុងព្រះរាជពង្សាវតារខ្មែរដែរ។ ឯកសារទាំងនោះ មានដូចជាសៀវភៅរបស់លោក ហ្សង់ ម៉ូរ៉ា, លោក អាដេម៉ារ ឡឺក្លែរ, លោក អេជេន អ៊ែម៉ូនីញ៉ែនិង លោក អាឡាំង ហ្វ័ររ៉ ជាដើម។ សៀវភៅរបស់លោក ហ្សង់ ម៉ូរ៉ា មានចំណងជើងថា "Le Cambodge" ដែលមានពីរភាគបោះពុម្ពនៅទីក្រុងប៉ារីស នាឆ្នាំ១៨៨៣ គឺមានរៀបរាប់ខ្លះៗអំពីឈ្មោះខេត្តត្បូងឃ្មុំ។ ក្នុងសៀវភៅភាគទី២ ទំព័រទី៥៣ សរសេរថា៖ នៅក្នុងឆ្នាំ១៥៨៤ សម្តេចព្រះបរម មហិន្ទរាជា ដែលបានដាក់រាជ្យក្នុងឆ្នាំ១៥៧៤ ព្រះអង្គបានសោយទិវង្គតនៅខេត្តស្ទឹងត្រែងក្នុងព្រះជន្មាយុ៤០ព្រះវស្សា។ បន្ទាប់មកព្រះដំយដេដ្ឋា ដែលត្រូវជាព្រះបុត្រាបានឡើងសោយរាជ្យបន្តពីព្រះបិតា ហើយក៏បានចូលទិវង្គតនៅឆ្នាំដដែល ក្នុងព្រះជន្ម២០ព្រះវស្សានៅទីនោះដែរ។ ដោយសារជួបរឿងអកុសលឥតឈប់ឈរបែបនេះ ទើបព្រះបរមរាជា និងព្រះមហេសី សម្រេចប្តូររាជធានីពីខេត្តស្ទឹងត្រែងមកគង់នៅខេត្តត្បូងឃ្មុំវិញ[94]។ ការលើកឡើងត្រង់ចំណុចនេះនៅក្នុងសៀវភៅរបស់លោកហ្សង់ម៉ូរ៉ា គឺពុំឃើញមានបញ្ជាក់នៅក្នុងព្រះរាជពង្សាវតារទេ រីឯនៅក្នុងសៀវភៅរបស់លោកអាដេម៉ារ ឡឺក្លែក៏ពុំឃើញមានលើកឡើងដែរ។ ការដែលពុំមានលើកឡើងអំពីព្រឹត្តការណ៍ខាងលើនៅក្នុងឯកសារទាំងពីរអាចមានមូលហេតុច្រើនយ៉ាង។ ប៉ុន្តែការដែលដកស្រង់រឿងរ៉ាវខាងលើមកបញ្ចូលត្រង់ចំណុចនេះ ព្រោះចង់បង្ហាញឲ្យឃើញប្រវត្តិនៃខេត្តត្បូងឃ្មុំដែលជាប្រធានបទសំខាន់នៃសៀវភៅនេះ ហើយត្រូវបានជនបរទេសលើកយកមករៀបរាប់នៅក្នុងសៀវភៅរបស់ពួកគេតាំងពីចុងសតវស្សទី១៨មកម្ល៉េះ។

នៅចន្លោះឆ្នាំ១៨៥០-១៩៦០ គឺមុនពេលដែលបារាំងដាក់អាណានិគមមកលើខ្មែរ ឃើញមានព្រឹត្តិការណ៍នយោបាយសំខាន់ៗមួយចំនួនកើតមាននៅលើដែនដីត្បូងឃ្មុំ។ នៅឆ្នាំ១៨៥៨ ពួកចាម និងម៉ាឡេរស់នៅត្បូងឃ្មុំ ដឹកនាំដោយទួន ស៊ូ, ទួន អ៊ិត និងទួន ហ៊ីម បានធ្វើបះបោរប្រឆាំងនឹងរាជការខ្មែរនាសម័យនោះ។ មន្ត្រីម្នាក់ដែលព្រះរាជាបញ្ជូនទៅបង្ក្រាបចលនាបះបោរនាពេលនោះត្រូវបានក្រុមគេសម្លាប់។ ទទួលបានដំណឹងនេះ ព្រះបាទអង្គដួង បានដឹកនាំកងទ័ពដោយផ្ទាល់ធ្វើដំណើរតាមទន្លេធំ

[94] JEAN Moura, 1883. Le Royaume du Cambodge. Tome Deuxéme.

(ទន្លេមេគង្គ) រហូតដល់ពាមជីលាំង។ នៅតាមផ្លូវព្រះអង្គបានជួបប្រយុទ្ធជាមួយពួកបះបោរនៅរកាប្រាំ បណ្តាលឲ្យស្លាប់ទាហានច្រើន ហើយក្រុមបះបោរត្រូវបង្ក្រាបទាំងស្រុង រួមទាំងទួន ស៊ូផង។ ចំណែកទួន អ៊ិត និងទួន ហ៊ីម បានរត់គេចខ្លួនទៅចូវដុក។ រីឯពួកចាម និងម៉ាឡេនៅតួងឃ្មុំភាគច្រើនត្រូវចាប់ខ្លួន ហើយបញ្ជូនទៅកាន់ខេត្តពោធិ៍សាត់, លង្វែក, កំពង់ហ្លួង និងទីផ្សេងៗទៀត[95]។

ក្នុងឆ្នាំ១៨៦១ ព្រះអង្គម្ចាស់វ៉ុត្តា ជាបុត្រទីបីរបស់ព្រះបាទអង្គឌួង មានបំណងដណ្តើមអំណាចពីរាជបុត្រច្បងទាំងពីរ របស់ទ្រង់គឺនរោត្តម និងស៊ីសុវត្ថិ។ ពេលនោះព្រះអង្គម្ចាស់វ៉ុត្តាវាយដណ្តើមយកបានខេត្តតួងឃ្មុំ ហើយធ្វើការប្រឆាំងជាមួយព្រះបាទនរោត្តម ដែលពុំទាន់បានរៀបអភិសេកឡើងគ្រងរាជតែមាននាទីជាស្តេចតាំងពី២ឆ្នាំមកហើយ។ ព្រះបាទនរោត្តម បានបញ្ជូនទាហានទៅតទល់ជាមួយបុរសម្នាក់ឈ្មោះស្នងសរ ដែលកំពុងស្នាក់នៅឯខេត្តបាភ្នំ ជាកន្លែងគាត់ដឹកនាំក្រុមបះបោរ ជាបក្ខពួករបស់ព្រះអង្គម្ចាស់វ៉ុត្តា។ អ្នកគាំទ្រព្រះអង្គម្ចាស់វ៉ុត្តា បានបង្កចលាចលក្នុងប្រទេសពិសេសនៅភាគខាងតួងនៃទន្លេ។ ទាហានដែលប្រយុទ្ធនៅតួងឃ្មុំ បានទទួលបញ្ជាឲ្យលើកទ័ពមករំដោះព្រះរាជានៅឯភ្នំពេញ។ ចុងបញ្ចប់ចលនាបះបោរត្រូវបង្ក្រាបទូទាំងប្រទេស លើកលែងតែខេត្តកំពង់សៀមមួយប៉ុណ្ណោះ ដែលក្រុមបះបោរនៅបន្តសកម្មភាពមិនព្រមចុះញ៉ូម។ ក៏ប៉ុន្តែក្រោយមក ដោយមានកិច្ចសហការជាមួយសាសន៍អឺរ៉ុប រាជការបានបង្ក្រាបពួកបះបោរដែលនៅសេសសល់បានទាំងស្រុង។ នៅឆ្នាំ១៨៦៣ ព្រះបាទនរោត្តមបានយល់ព្រមចុះព្រះហត្តលេខាឲ្យបារាំងត្រួតត្រាស្រុកខ្មែរ ដើម្បីរក្សាស្ថេរភាពនយោបាយនិងសន្តិសុខក្នុងប្រទេស ហើយព្រះអង្គបានរៀបអភិសេកឡើងគ្រងរាជ្យនៅឆ្នាំ១៨៦៤ ដោយមានការជួយជ្រោមជ្រែងពីមន្ត្រីជាន់ខ្ពស់របស់បារាំង ដែលជាអាណាព្យាបាលនាពេលនោះ។

បន្ទាប់ពីប្រទេសធ្លាក់ក្រោមការត្រួតត្រារបស់បារាំង គេសង្កេតឃើញមានចលនាបះបោរកក្រើកឡើងវិញជាថ្មីទៀតនៅលើដែនដីតួងឃ្មុំ។ នៅឆ្នាំ១៨៦៨ ឈ្មោះអាច្រែង ដែលជាអតីតមេបះបោរមួយរូបបានដឹកនាំបក្ខពួកវាយសម្រុកចូលកាន់កាប់ដែនដីតួងឃ្មុំ ដើម្បីកែនប្រជាជន និងរឹបអូសសត្វ៣ហាន: សម្រាប់ជាមធ្យោបាយពង្រឹងនិងពង្រីកចលនាបះបោររបស់ខ្លួន។ ក្នុងឆ្នាំ១៨៧២ អាច្រែងបានចាប់ផ្តើមបង្កចលនាបះបោរជាថ្មីទៀត តែត្រូវទទួលបរាជ័យរត់បែកខ្ទេចចូលព្រៃ ដោយសារការបង្ក្រាបពីកម្លាំងរាជការនិងប្រជាជន។ ចំណែក អាច្រែង ជាមេបះបោរបានរត់គេចខ្លួនបាត់។

ក្រោយពីលាក់ខ្លួនអស់រយៈពេល១៥ឆ្នាំ ព្រះអង្គម្ចាស់វ៉ុត្តា បានបង្ហាញខ្លួនម្តងទៀតនៅលើទឹកដីតួងឃ្មុំនាឆ្នាំ១៨៧៦។ នៅខែកុម្ភៈ ឆ្នាំ១៨៧៧ កងទ័ពបារាំងបានមកដល់កោះសូទិន ដោយទូក រួចបន្តដំណើរទៅបាភ្នំ។ គ្រានោះសភាពការណ៍ទាំងនៅបាភ្នំ និងតួងឃ្មុំ មានភាពស្ងប់ស្ងាត់ ដោយក្រុមបះបោរពុំធ្វើសកម្មភាពទៀតឡើយ។ ប៉ុន្តែក្រោយមក មានចលនាបះបោរថ្មីមួយកើតឡើង នៅឯតួងឃ្មុំ ដែលដឹក

95

នាំដោយព្រះអង្គម្ចាស់វ៉ាត្ថា។ ការបះបោរនាពេលនោះ ពុំទទួលបានជោគជ័យឡើយ ហើយព្រះអង្គម្ចាស់បានសាងព្រះផ្នួស។ ចាប់ពីពេលនោះមក គេពុំមានពត៌មានអំពីទ្រង់ឡើយ រហូតដល់ឆ្នាំ១៨៨៥[96]។

នៅពេលប្រទេសស្ថិតក្រោមអាណាព្យាបាលបារាំងនៅឆ្នាំ១៨៦៣ បារាំងបានលប់បំបាត់ទាំងស្រុងការបែងចែង ដី ហើយរៀបចំចាត់ចែងបង្កើតជាខេត្តថ្មីឡើងវិញ។ បន្ទាប់មកប្រទេសបារាំងបានបង្កើតនិវេសដ្ឋាន(រ៉ូស៊ីដង់)ប្រចាំខេត្តនីមួយៗ ដើម្បីរក្សារបៀបរៀបរយ គ្រប់គ្រងកិច្ចការហិរញ្ញវត្ថុ និងបច្ចេកទេស ពិសេសគ្រប់គ្រងការទារពន្ធដារពីប្រជាកសិករខ្មែរ។ ខេត្តកំពង់ចាមបង្កើតឡើងនៅថ្ងៃទី១ ខែមករា ឆ្នាំ១៨៨៥ គ្រប់គ្រងដោយមន្ត្រីបារាំងឈ្មោះ ហ្ស្ង់ស័រ បូឌាន់ ដែលក្រោយមកគាត់បានក្លាយជាមន្ត្រីជាន់ខ្ពស់នៃអាណាព្យាបាលបារាំងប្រចាំនៅកម្ពុជា។ ខេត្តកំពង់ចាមកាលណោះមានចំនួនដប់ស្រុកគឺ៖ ស្រុកកំពង់សៀម, ក្រូចឆ្មារ, ព្រៃឈរ, ជើងព្រៃ, កងមាស, កោះសូទិន, ស្រីសន្ធ, មេមត់, ស្ទឹងត្រង់និងស្រុកត្បូងឃ្មុំ[97]។ ទន្ទឹមគ្នានោះ មានផ្ទុះចលនាបះបោររបស់ប្រជារាស្ត្រខ្មែរទូទាំងប្រទេស ប្រឆាំងតវ៉ានឹងការគាបសង្កត់ និងបង្ហាប់បញ្ជារបស់បារាំង។ ស្ថានភាពសេដ្ឋកិច្ចនាពេលនោះ ធ្លាក់ដុនដាបខ្លាំង ហើយព្រះមហាក្សត្រត្រូវជាប់ឃុំក្នុងព្រះបរមរាជវាំង។ រដ្ឋបាលបារាំងក៏ចុះថមថយឥទ្ធិពលនិងកម្លាំង ហើយបានស្នើឲ្យព្រះមហាក្សត្រជួយទប់ស្កាត់និងបញ្ចប់កុំឲ្យមានចលនាដើបប្រឆាំងតទល់ជាមួយបារាំងតទៅទៀត នោះបារាំងនឹងសុខចិត្តអនុវត្តឲ្យបានទន់ភ្លន់នូវសន្ធិសញ្ញាឆ្នាំ១៨៨៤។ មូលហេតុខាងលើ បានជំរុញឲ្យរដ្ឋាភិបាលបារាំងនាសម័យនោះ ធ្វើការកែទម្រង់រដ្ឋបាលកណ្តាលរបស់ខ្លួនជាបន្ទាន់ ដោយប្រកាន់ឥរិយាបថខុសពីមុន ហើយមានការប្រុងប្រយ័ត្នខ្ពស់ រាល់កិច្ចការដែលត្រូវអនុវត្តក្នុងប្រទេសកម្ពុជា។ បន្ទាប់ពីមានព្រឹត្តការណ៍ប្រឆាំងតទល់ជាមួយរដ្ឋបាលបារាំងនាពេលនោះ បានជំរុញឲ្យរបបអាណាព្យាបាលបារាំងបានធ្វើការកាត់បន្ថយចំនួនរ៉ូស៊ីដង់ឲ្យមកនៅត្រឹម៤ទៅ៥ប៉ុណ្ណោះក្នុងទូទាំងប្រទេស[98]។

លោក អេដែន អ៊ីម៉ូនីញ៉ូ ចូលមកប្រទេសកម្ពុជាក្នុងឆ្នាំ១៨៦៩ ក្នុងនាមជាសមាជិកកងនាវានៃអាណាព្យាបាល បារាំង។ លុះដល់ឆ្នាំ១៨៧៣ គាត់បានក្លាយជាតំណាងអាណាព្យាបាលបារាំងប្រចាំទីក្រុងភ្នំពេញ។ ក្នុងតួនាទីសំខាន់នេះ បានតម្រូវឲ្យលោកធ្វើដំណើរទៅកាន់ភូមិ ស្រុកគ្រប់ច្រកល្ហកក្នុងប្រទេសកម្ពុជា ហើយថែមទាំងជំរុញឲ្យគាត់ត្រូវសិក្សាពីវប្ផធម៌និងអារ្យធម៌ខ្មែរតាមរយៈការបកប្រែសាស្ត្រាស្លឹកឫតនិងសិលាចារឹកនៅតាមប្រាសាទនានា។ ដូចបានពោលពីខាងលើរួចមកហើយ រឿងទុំទាវគឺជា

[96] 1907, Monographie de la Circonscription Résidentielle de Kompong-Cham. Sociéte des Edutes Indo-Chinoises, Saigon, Scneide

[97] ?, 1907, Monographie de la Circonscription Résidentielle de Kompong-Cham. Sociéte des Edutes Indo-Chinoises, Saigon, Schneider

[98] ?, 1907, Monographie de la Circonscription Résidentielle de Kompong-Cham. Sociéte des Edutes Indo-Chinoises, Saigon, Schneider

ស្នាដៃប្រលោមលោក ដ៏ល្បីល្បាញរបស់ខ្មែរ ដែលធ្វើឲ្យលោកអ៊ីម៉ូនីញ៉ូ មានការចាប់អារម្មណ៍យ៉ាងខ្លាំង។ ហេតុដូច្នោះ ដើម្បីស្វែងយល់ឲ្យបានស៊ីជម្រៅអំពីខ្សែរឿងនេះ លោកព្យាយាមធ្វើដំណើរទៅកាន់ស្រុកត្បូងឃ្មុំដែលជាប្រភពនៃរឿងក្នុងឆ្នាំ១៨៨៣។ បន្ទាប់មកគាត់បានបកប្រែរឿងទុំទាវទៅជាភាសាបារាំងនៅឆ្នាំ ១៨៨៨ ដោយរួមបញ្ចូលនូវព័ត៌មានច្រើនទៀតដែលគាត់ប្រមូលបានក្នុងពេលបំពេញបេសកកម្មរបស់គាត់[99]។ ដូច្នេះ នៅរវាងទសវត្ស១៨៨០ ទឹកដីត្បូងឃ្មុំ គឺជាស្រុកមួយរបស់ខេត្តកំពង់ចាមនៅឡើយ។

ចាប់តាំងពីចុងសតវត្សទី១៩មក ការកែទម្រង់វិស័យរដ្ឋបាលបានធ្វើឡើងជាញឹកញាប់ ពិសេសក្នុងរាជរបស់ព្រះបាទអង្គឌួង និងនរោត្តម ហើយពេលនោះមានការរើរុះរចនាសម្ព័ន្ធរដ្ឋបាល ដោយតម្រូវឲ្យបង្កើតខេត្តថ្មីឡើងវិញដែលមានចំនួន៥៧ខេត្ត[100] ព្រមទាំងមានការបែងចែករចនាសម្ព័ន្ធដឹកនាំថ្នាក់ខេត្ត ស្រុក និងឃុំ។ បើទោះជាមានការបង្កើតខេត្តក៏ពិតមែន ប៉ុន្តែក្នុងផ្នត់គំនិតខ្មែរ នៅតែយល់ថាស្រុកគឺធំជាងខេត្ត។ ដូច្នេះហើយទើបអ្នកស្រុកភាគច្រើននៅតែបន្តហៅស្រុកដដែលទោះជាមានការកែរប្រែក្តី។

នៅឆ្នាំ១៨៩៧ ដោយមានការគាំទ្រពីក្រុមប្រឹក្សារដ្ឋមន្ត្រីនៅទីក្រុងប៉ារីស បានតម្រូវឲ្យរបបអាណាព្យាបាលបារាំងនៅកម្ពុជាបញ្ជូនមន្ត្រីបារាំងទៅគ្រប់គ្រងនិងត្រួតត្រាតាមបណ្តាខេត្តនីមួយៗរបស់ខ្មែរ។ ពេលនោះកំពង់ចាមលែងជាខេត្តទៀតហើយ គឺគេច្របាច់បញ្ចូលជាមួយខេត្តផ្សេងទៀត ដែលជាអតីតស្រុករបស់ខេត្តនេះ។ ចាប់ពីពេលនោះហើយ ដែលរដ្ឋអំណាចនៃអាណាព្យាបាលបារាំងបានស្នើសុំចៅហ្វាយខេត្តខ្មែរដែលគ្រប់គ្រងខេត្តនីមួយៗបង្កើតផែនទីដើម្បីបង្ហាញពីទំហំដែនដី ដែលខ្លួនគ្រប់គ្រង។ ក្នុងចំណោមខេត្តទាំង៥៧ យើងសង្កេតឃើញមានខេត្តចំនួន៥៤[101]ប៉ុណ្ណោះដែលមានផែនទីគូរដោយដៃបង្ហាញពីវិសាលភាព ភូមិ ស្រុក និងទីតាំងសំខាន់ៗក្នុងខេត្ត ក្នុងនោះក៏មានខេត្តត្បូងឃ្មុំមួយដែរ(រូបលេខ ៥០)។ ខេត្តត្បូងឃ្មុំកាលណោះមានជាង៣០០ភូមិ។ ភូមិមួយចំនួនធំនៅរក្សាឈ្មោះរហូតដល់សព្វថ្ងៃ ភូមិខ្លះគ្រាន់តែជូរសំណេរដើមមកជាសំណេរសព្វថ្ងៃ។ ប៉ុន្តែភូមិខ្លះបាត់ទាំងស្រុង ហើយក៏ឃើញមានភូមិថ្មីខ្លះទើបបង្កើតដែរ។ សព្វថ្ងៃខេត្តត្បូងឃ្មុំ មានស្រុកចំនួន៦ និងក្រុងមួយ ចែកចេញជា៦៤ឃុំ ហើយមាន ៨៧២ភូមិ។ ដូច្នេះចំនួនភូមិបានកើនឡើងជាង៣ក់កណ្តាលបើប្រៀបជាមួយចំនួនភូមិកាលពីជាង១០០ឆ្នាំមុន។

---

[99] Aymonier, Étienne, 1878. Textes Khmers. Saigon (lithograph)
1904. Le Cambodge. 3 vols. Pairs: E. Leroux.

[100] ភាសាសំស្ក្រឹត ក្សេត្រ មានន័យថាមានដែនកំណត់ឬព្រំ ខណ្ឌ ច្បាស់លាស់។ ភាសាខ្មែរបុរាណមានន័យថា" ស្រែ វិស័យ វិស័យទេព (ប្រាសាទ) ទីគោរពសក្ការៈ ទេពជាដើម" (សេចក្តីពន្យល់ទាំងអស់ខាងលើដកស្រង់ចេញពីអត្ថបទរបស់លោក Grégory MIKAELIAN ស្តីអំពី Note sur la première cartographie provincial Cambodgienn (c. 1897) បោះពុម្ពទស្សនាវដ្ដី Péninsule n° 54-2007(1)

[101] GRÉGORY Mikaelian, NOTE SUR LA PREMIÈRE CARTOGRAPHIE PROVINCIALE CAMBODGIENNE (c. 1897), Péninsule n° 54 –2007 (1)

ព្រះបាទអង្គឌួង ព្យាយាមដាក់បញ្ជាទៅលើចៅហ្វាយខេត្តនីមួយៗ ត្រូវរៀបចំរចនាសម្ព័ន្ធរដ្ឋបាលនៅក្នុងខេត្តរបស់ខ្លួន ដោយត្រូវជ្រើសរើសបាឡាត់[102]ខេត្តម្នាក់ យោកប្ដ័តម្នាក់ ស្មៀនបួននាក់និងអ្នករត់សំបុត្រម្នាក់[103]។

ចៅហ្វាយខេត្តក៏ត្រូវតែងតាំង «សុភាស្ងង» និង «ក្រឡាពាស» ជាមន្ត្រីមានមុខនាទីប្រែប្រួលតាមការចាត់តាំងរបស់ចៅហ្វាយខេត្ត ជួលកាលជាអ្នកទទួលខុសត្រូវក្នុងស្រុកតាមព្រំដែន។ អ្នកខ្លះបានលក់មុខដំណែងរបស់ខ្លួន ជាថ្នូរនឹងផលប្រយោជន៍ផ្សេងៗ។ កំណែទម្រង់នៅពេលនោះ ដំណើរទៅក្នុងស្ថានភាពអាក់អ្ងួលនៅឡើយ ដ្បិតដែនកំណត់រវាងខេត្តនីមួយៗពុំទាន់បែងចែកច្បាស់លាស់។



រូបលេខ៥០៖ ផែនទីខេត្តត្បូងឃ្មុំដំបូង គូរនៅពីឆ្នាំ១៨៩៧(ប្រភព៖ សាលាបារាំងចុងបូព៌ា)

[102] បាឡាត់ និងយោកប្ដ័ត គឺជាពាក្យមានឥទ្ធិពលមកពីសៀម។ បាឡាត់ស្មើនឹងពាក្យខ្មែរថាបន្ទាស់។ ដូច្នេះបាឡាត់ខេត្ត គឺជាមនុស្សដែលត្រូវមកជួសឬជំនួសចៅហ្វាយខេត្តនៅថ្ងៃអនាគត ហើយសព្វថ្ងៃគេហៅអភិបាលរងខេត្ត។ រីឯយោកប្ដ័តវិញ មានន័យថាជំនួយការឬលេខា។

[103] ?1907, Monographie de la Circonscription Résidentielle de Kompong-Cham. Sociéte des Edutes Indo-Chinoises, Saigon, Schneider

រដ្ឋបាលខេត្តត្បូងឃ្មុំ ដែលមានចាប់តាំងពីអំឡុងឆ្នាំ១៨៩៨ គឺមានភាពស្មុគស្មាញខ្លាំង ដោយសារការជ្រៀតជ្រែកពីប្រព័ន្ធរដ្ឋបាលកណ្តាលទៅលើតួនាទីនិងអំណាយរដ្ឋបាលនៅថ្នាក់មូលដ្ឋាន។ ដូច្នេះ ដើម្បីឲ្យកិច្ចការរដ្ឋបាលនៅថ្នាក់ក្រោមមានប្រសិទ្ធិភាព គេបានបែងចែកខេត្តត្បូងឃ្មុំជាបួនផ្នែកគឺ៖

- ត្បូងឃ្មុំខាងស្តាំ៖ គិតចាប់ពីស្រុកក្រូចឆ្មារ រហូតដល់ព្រំប្រទល់ស្រុកឆ្លងនៃខេត្តក្រចេះ។ កិច្ចការរដ្ឋបាលនៅក្នុងដែនដីនៃផ្នែកនេះ គ្រប់គ្រងដោយមនុស្សម្នាក់ ហើយតួនាទីជាអ្នកធ្វើរបាយការណ៍អំពីសភាពការណ៍និងបញ្ហាផ្សេងៗដែលកើតមាននៅ ក្នុងដែនដីដែលខ្លួនមើលការខុសត្រូវជូនទៅរដ្ឋមន្ត្រីសង្គ្រាម។

- ត្បូងឃ្មុំខាងឆ្វេង៖ លាតសន្ធឹងពីពាមជីលាំង រហូតដល់ព្រំប្រទល់ខេត្តស្រីសន្ធរ និងជាតំបន់មួយគត់ដែលពឹងផ្អែកនិងស្ថិតក្រោមការគ្រប់គ្រងផ្ទាល់ដោយចៅហ្វាយខេត្តត្បូងឃ្មុំ ដែលកាលណោះមានងារជា "ឧញ្ញាអរជូន"។

- ត្បូងឃ្មុំព្រៃលើ៖ ស្ថិតនៅជាប់តំបន់មួយនៃប្រទេសវៀតណាម។ ការងាររដ្ឋបាលនៅត្បូងឃ្មុំព្រៃលើគឺគ្រប់គ្រងដោយមនុស្សពីរនាក់ ដែលអ្នកទាំងពីរនោះមានភារកិច្ចគ្រប់គ្រងនិងមើលការខុសត្រូវចំពោះប្រជាជនដែលជាប់កាតព្វកិច្ចបង់ពន្ធជូនឧបរាជ និងមន្ត្រីក្រមការដទៃទៀតនៅឯភ្នំពេញ។

- ត្បូងឃ្មុំព្រៃក្រោម៖ មានព្រំប្រទល់ជាប់ជាមួយតំបន់មួយចំនួនដូចជារមាសហែក, រំដួល, ព្រៃវែង និងតែនិញនៃប្រទេសវៀតណាម ហើយការងាររដ្ឋបាលនិងគ្រប់គ្រងតំបន់នេះត្រូវបែងចែករវាងមន្ត្រីនៅតាមស្ថាប័នតូចៗមួយចំនួនតាមស្ថានភាពជាក់ស្តែង[104]។ នៅក្រោយសង្គ្រាមលោកលើកទី២ រដ្ឋបាលនៃអាណាព្យាបាលបារាំងបានកែទម្រង់ជាថ្មីអំពីរចនាសម្ព័ន្ធនៃការដឹកនាំរបស់ខ្លួននៅទូទាំងឥណ្ឌូចិន។ ដោយឡែកនៅក្នុងប្រទេសកម្ពុជា រដ្ឋបាលកណ្តាលនៃអាណាព្យាបាលបារាំងបានសម្រេចធ្វើការកែទម្រង់រចនាសម្ព័ន្ធគ្រប់គ្រងរបស់ខ្លួនដោយធ្វើការកែប្រែចំនួនខេត្តជាថ្មីពី៥៧ខេត្តនៅឆ្នាំ១៨៩៧ មកនៅត្រឹម៥១ ខេត្តវិញនៅក្នុងឆ្នាំ១៩១៧[105](រូបលេខ៥១)។ យើងសង្កេតឃើញថាខេត្តចំនួន៤៣ ដែលមានតាំងពីឆ្នាំ១៨៩៧គឺនៅរក្សាដដែលនៅឆ្នាំ១៩១៧។ ខេត្តចំនួន១៤ មាននៅឆ្នាំ១៨៩៧បានបាត់ ហើយមានខេត្តចំនួន៨ ត្រូវបង្កើតថ្មីនៅក្នុងឆ្នាំ១៩១៧។

[104] ALAIN Forest, 1980: p. 20
[105] SORN Samnang, 1995: p. 30-40

ខេត្តខ្មែរក្នុងឆ្នាំ១៨៩៧				ខេត្តខ្មែរក្នុងឆ្នាំ១៩១៧			
ល.រ	ឈ្មោះខេត្ត	ល.រ	ឈ្មោះខេត្ត	ល.រ	ឈ្មោះខេត្ត	ល.រ	ឈ្មោះខេត្ត
១	បន្ទាយមាស	៣០	លង្វែក	១	បន្ទាយមាស	៣០	លង្វែក
២	ជីក្រែង	៣១	ស្នោង	២	ជីក្រែង	៣១	ស្នោង
៣	គងពិសី	៣២	កំពង់លែង	៣	គងពិសី	២៣	កំពង់លែង
៤	កំពង់ស្វាយ	៣៣	ស្ទឹងត្រង់	៤	កំពង់ស្វាយ	៣៣	ស្ទឹងត្រង់
៥	ស្វាយទាប	៣៤	ឆ្លូង	៥	ស្វាយទាប	៣៤	ឆ្លូង
៦	ស្រីសន្ធរ	៣៥	ខ្សាច់កណ្តាល	៦	ស្រីសន្ធរ	៣៥	ខ្សាច់កណ្តាល
៧	ត្បូងឃ្មុំ	៣៦	កំពត	៧	ត្បូងឃ្មុំ	៣៦	កំពត
៨	បាភ្នំ	៣៧	មុខកំពូល	៨	បាភ្នំ	៣៧	មុខកំពូល
៩	រំដួល	៣៨	ព្រៃវែង	៩	រំដួល	៣៨	ព្រៃវែង
១០	កំពង់សោម	៣៩	ក្រចេះ	១០	កំពង់សោម	៣៩	ក្រចេះ
១១	ទ្រាំង	៤០	ក្រគរ	១១	ទ្រាំង	៤០	ក្រគរ
១២	រលាប្អៀរ	៤១	បរិបូណ៌	១២	រលាប្អៀរ	៤១	បរិបូណ៌
១៣	ជើងព្រៃ	៤២	ស៊ីធរ៣ពារ៉ាំង	១៣	ជើងព្រៃ	៤២	៣ពារ៉ាំង
១៤	ល្វាឯម	៤៣	កណ្តាលស្ទឹង	១៤	ល្វាឯម	៤៣	កណ្តាលស្ទឹង
១៥	កំពង់សៀម	៤៤	ព្រហ្មទេព	១៥	កំពង់សៀម	៤៤	ស្ទឹងត្រែង
១៦	ស៊ីធរកណ្តាល	៤៥	៣មជរ	១៦	ស៊ីធរកណ្តាល	៤៥	បាត់ដំបង
១៧	ភ្នំស្រួច	៤៦	កងមាស	១៧	ភ្នំស្រួច	៤៦	ស៊ីសុផុន
១៨	កៀនស្វាយ	៤៧	កោះធំ	១៨	កៀនស្វាយ	៤៧	សៀមរាប
១៩	ភ្នំពេញ	៤៨	ស្វាយ	១៩	ភ្នំពេញ	៤៨	[illegible]

[redacted]

ចំនួនខេត្តខ្មែរបង្កើតក្នុងឆ្នាំ១៨៩៧ និងឆ្នាំ១៩១៧



រូបលេខ៥១៖ ខេត្តខ្មែរបង្កើតនៅឆ្នាំ១៩១៧ (កែសម្រួលពី៖ ALAIN Forest, 1980)

បន្ទាប់ពីមានការកែទម្រង់តាមព្រះរាជបញ្ញាចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩២១ យើងសង្កេតឃើញថា ខេត្តខ្មែរត្រូវបង្រួមឲ្យមកនៅត្រឹមចំនួន១៣ប៉ុណ្ណោះ គឺស្មើនឹងចំនួនរ៉េស៊ីដង់របស់បារាំងដែលត្រួតនៅតាមខេត្តទាំងនោះ(រូបលេខ៥២)។ កាលណោះពុំទាន់មានខេត្តសៀមរាបទេ ត្បិតខេត្តមួយនេះគឺជាស្រុកមួយរបស់ខេត្តបាត់ដំបង[106]។ រីឯខេត្តត្បូងឃ្មុំ បានក្លាយឲ្យទៅជាស្រុកមួយរបស់ខេត្តកំពង់ចាមវិញ។ ការកែប្រែនេះមិនត្រឹមធ្វើនៅថ្នាក់ខេត្តទេ គឺធ្វើទាំងនៅថ្នាក់ក្រោមផងដែរ ដោយគេបង្កើតឲ្យមានខណ្ឌនៅតាម

[106] SORN Samnang, 1995: p. 30-40

ខេត្តនីមួយៗបន្ថែមពីលើរចនាសម្ព័ន្ធធ្លាប់មានពីមុនមក។ រចនាសម្ព័ន្ធដឹកនាំនៅតាមបណ្តាខេត្តនីមួយៗ គឺមានចៅហ្វាយខេត្ត ចៅហ្វាយស្រុក ចៅហ្វាយខណ្ឌនិងមេឃុំ ហើយអមដោយមន្ត្រីក្រោមឱវាទដូចជា បាឡាត់ខេត្ត បាឡាត់ស្រុក បាឡាត់ខណ្ឌ ជំទុប ស្មៀន និងអ្នករត់សំបុត្រ[107]។

សរុបមកឃើញថាដែនដីត្បូងឃ្មុំបានឆ្លងកាត់នូវកំណែទម្រង់ជាច្រើនដំណាក់កាលតាមបរិបទនៃនយោបាយនិងសង្គម។ យើងឃើញចាប់ពីក្រោយសម័យអង្គរត្បូងឃ្មុំជាស្រុកមួយគ្រប់គ្រងដោយស្តេចគ្រាញ់។ លុះចាប់ពីប្រទេសស្ថិតក្រោមការត្រួតត្រារបស់បារាំង រហូតដល់មុនឆ្នាំ២០១៤ ឃើញថាត្បូងឃ្មុំម្តងជាខេត្ត ម្តងជាស្រុកដោយមានផែនទីកំណត់ផង។ នៅឆ្នាំ២០១៤ត្បូងឃ្មុំត្រូវរាជរដ្ឋាភិបាលសម្រេចប្រែក្លាយឲ្យទៅជាខេត្តថ្មីឡើងវិញនៅលើទឹកដីចាស់។

ល.រ	ឈ្មោះខេត្ត	ថ្ងៃ ខែ ឆ្នាំបង្កើត
១	កណ្តាល	២៦ ធ្នូ ១៩២១
២	កំពង់ស្ពឺ	១៨ មីនា ១៩២២
៣	ពោធិ៍សាត់	៩ មេសា ១៩២២
៤	ស្វាយរៀង	៩ មេសា ១៩២២
៥	កំពង់ឆ្នាំង	១០ កញ្ញា ១៩២២
៦	ព្រៃវែង	១០ កញ្ញា ១៩២២
៧	តាកែវ	១០ កញ្ញា ១៩២២
៨	បាត់ដំបង	១៦ កុម្ភៈ ១៩២៣
៩	ស្ទឹងត្រែង	១៦ កុម្ភៈ ១៩២៣
១០	កំពត	៣០ មិថុនា ១៩២៣
១១	កំពង់ចាម	៣០ មិថុនា ១៩២៣
១២	កំពង់ធំ	៣០ មិថុនា ១៩២៣
១៣	ក្រចេះ	៣០ មិថុនា ១៩២៣

ខេត្តខ្មែរបង្កើតនៅទសវត្ស១៩២០ តាមព្រះរាជបញ្ញត្តិ ដំណាលគ្នានឹងការ
បង្កើតចំនួនរ៉ូស៊ីដង់បារាំងប្រចាំខេត្តនីមួយៗ(ប្រភព៖ SORN Samnang, 1995)

[107] SORN Samnang, 1995: p. 30-40

រូបលេខ៥២៖ ខេត្តខ្មែរក្នុងទសវត្ស១៩២០ (ប្រភពផែនទី៖ Pollacchi, Atlas colonial

២. ការប្រែក្លាយដែនដីត្បូងឃ្មុំឲ្យទៅខេត្តឡើងវិញ

ចាប់តាំងពីក្រោយការបោះឆ្នោតឆ្នាំ១៩៩៣ មករាជរដ្ឋាភិបាលបានបំបែកខេត្តចំនួន២ និងប្រែក្លាយក្រុងចំនួន៣ បង្កើតជាខេត្តថ្មីចំនួន៥រួចទៅហើយ។ ខេត្តទាំងនោះរួមមាន ខេត្តបន្ទាយមានជ័យបំបែកចេញពីខេត្តបាត់ដំបងនៅឆ្នាំ១៩៩៣, ខេត្តឧត្តរមានជ័យបំបែកចេញពីខេត្តសៀមរាប និងផ្នែកខ្លះនៃខេត្តព្រះវិហារនៅឆ្នាំ១៩៩៨, ក្រុងកែប ត្រូវបានប្រែក្លាយឲ្យទៅជាខេត្តកែបនៅឆ្នាំ២០០៨, ក្រុងព្រះសីហនុ ត្រូវបានប្រែក្លាយឲ្យទៅជាខេត្តព្រះសីហនុនៅឆ្នាំ២០០៨, ក្រុងប៉ៃលិន ត្រូវបានប្រែក្លាយឲ្យទៅ ខេត្តនៅឆ្នាំ២០០៨។ ផ្អែកលើបទពិសោធន៍ខាងលើ និងដោយមានការយកចិត្តទុកដាក់ពីប្រមុខរដ្ឋាភិបាលក្នុងការលើកកម្ពស់ជីវភាពប្រចាំថ្ងៃរបស់ប្រជាជន តាមរយៈការផ្តល់សេវារដ្ឋបាលសាធារណៈឲ្យខិតកាន់តែជិតដល់មូលដ្ឋាននិងកាន់តែមានប្រសិទ្ធិភាព ទើបរាជរដ្ឋាភិបាលបានសម្រេចប្រែក្លាយដែនត្បូងឃ្មុំឲ្យទៅជាខេត្តឡើងវិញ ដោយបំបែកចេញពីខេត្តកំពង់ចាម ដោយយកទន្លេមេគង្គជាព្រំសីមានៃខេត្តទាំងពីរ តាមរយៈ*ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៥ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៣* ។ ការប្រែក្លាយដែនដីត្បូងឃ្មុំឲ្យទៅជាខេត្តឡើងវិញដូចពីអតីតកាល គឺមានគោលបំណងចម្បងៗពីរ៖

១.ខេត្តកំពងចាមមានផ្ទៃដីធំមានចំនួនប្រជាជនច្រើន(ទាំងប្រជាជនដើម និងប្រជាជនចំណាកស្រុកមានចំនួនសរុបជាងពីរលាននាក់)។ ព្រោះតែទំហំផ្ទៃដីធំនិងមានប្រជាជនច្រើនដូច្នេះ ទើបធ្វើឲ្យការគ្រប់គ្រងរដ្ឋបាល និងការផ្តល់សេវាសាធារណៈជូនប្រជាជនពុំអាចឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៃជីវភាពប្រចាំថ្ងៃ ពិសេសប្រជាជនរស់នៅតាមជនបទ ហើយភាពចន្លោះប្រហោងក្នុងការផ្តល់សេវាសាធារណៈគឺតែងកើតមានជាហូរហែ។ ដូច្នេះ ការលើកកម្ពស់ការផ្តល់សេវារដ្ឋបាល និងសេវាសាធារណៈដទៃទៀតឲ្យកៀកជិតប្រជាជន ដើម្បីជំរុញការអភិវឌ្ឍឲ្យមានគុណភាពគឺជាតម្រូវការចាំបាច់។

២. បង្កើតមជ្ឈមណ្ឌលសេដ្ឋកិច្ច សង្គមនៅតំបន់ជនបទ ដើម្បីទាក់ទាញវិនិយោគវិស័យឧស្សាហកម្មកែច្នៃផលិតផលកសិកម្មនៅតំបន់ជនឲ្យបានច្រើនដែលអាចបង្កើតការងារជូនប្រជាជននៅមូលដ្ឋាន កាត់បន្ថយការធ្វើចំណាកស្រុក ព្រមទាំងលើកស្ទួយជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនឲ្យបានកាន់តែល្អប្រសើរ។

ដូចបានបញ្ជាក់ពីខាងលើម្តងរួចមកហើយ ខេត្តត្បូងឃ្មុំសព្វថ្ងៃមានផ្ទៃដីទំហំ៥២៥០,៥១គីឡូម៉ែត្រក្រឡា ចែកជាស្រុកចំនួន៦ស្រុកគឺ ត្បូងឃ្មុំ, អូររាំងឪ, ក្រូចឆ្មារ, តំបែរ, ពញាក្រែកនិងស្រុកមេមត់ ហើយមានក្រុងចំនួនមួយគឺក្រុងសួងដោយចែកជា២សង្កាត់។ ចំណែកឃុំវិញគឺមានចំនួន៦៤ឃុំ និង

ភូមិចំនួន៨៧២ភូមិ។ ខេត្តត្បូងឃ្មុំ ដឹកនាំដោយអភិបាលចំនួនមួយរូប គណៈអភិបាលខេត្តចំនួន៧រូបនិង ក្រុមប្រឹក្សាខេត្តចំនួន១៩រូប។

២.១. បុរីរដ្ឋបាលសាលាខេត្ត

បុរីរដ្ឋបាលសាលាខេត្តត្បូងឃ្មុំ ដែលបានស្ថាបនាឡើង បើទោះជានៅលើដែនដីចាស់ក៏ពិតមែន តែជាទីតាំងថ្មីស្រឡាង ខុសពីបណ្តាខេត្តមុនៗដែលបង្កើតក្រោយឆ្នាំ១៩៩៣ ព្រោះខេត្តទាំងនោះបង្កើតឡើងដោយយកទីរួមស្រុក ឬទីប្រជុំជននៃក្រុងធ្វើជាបុរីរដ្ឋបាល ដែលមានហេដ្ឋារចនាសម្ព័ន្ធរួចស្រាច់ទៅហើយ ដោយគ្រាន់តែអភិវឌ្ឍន៍បន្ថែមទៅលើហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ប៉ុណ្ណោះ។ ផ្ទុយទៅវិញទីតាំងបុរីរដ្ឋបាលសាលាខេត្តត្បូងឃ្មុំ គឺពុំមានអ្វីទាំងអស់។ ព្រោះតែដូច្នោះហើយទើបយើងសម្រេចឲ្យឈ្មោះចំណងជើងសៀវភៅនេះថា ″**ត្បូងឃ្មុំ៖ ខេត្តថ្មីលើទឹកដីចាស់**″ ទីតាំងដែលរាជរដ្ឋាភិបាលបានសម្រេចជ្រើសរើសយកធ្វើជាបុរីរដ្ឋបាលសាលាខេត្តត្បូងឃ្មុំថ្មី គឺជាដីចំការម៉ែសាក់មានទំហំ៨ហិកតា ស្ថិតនៅក្នុងឃុំស្រឡប់ និងឃុំអញ្ចើម របស់ស្រុកត្បូងឃ្មុំ។ បុរីរដ្ឋបាលសាលាខេត្តថ្មីនេះ ស្ថិតនៅចម្ងាយប្រមាណ២០គីឡូម៉ែត្រខាងកើតក្រុងសួង និងប្រហែល១០គីឡូម៉ែត្រភាគ៣យព្យនៃរាជធានីឥន្ទ្របុរ ឬរាជធានីបន្ទាយព្រៃនគរ។ មានផ្លូវជាតិសំខាន់ពីរដែលអាចធ្វើដំណើរពីរាជធានីភ្នំពេញ ទៅកាន់ខេត្តត្បូងឃ្មុំគឺ៖ ទីមួយតាមផ្លូវជាតិលេខ៦ រួចបន្តទៅផ្លូវជាតិលេខ៧ត្រង់ស្ពាន់ ឆ្ពោះទៅក្រុងកំពង់ចាម មានចម្ងាយប្រហែល១២៥គីឡូម៉ែត្រ រួចឆ្លងស្ពានមិត្តភាពកម្ពុជា-ជប៉ុន(ស្ពានគីហ្សូណា) កាត់ក្រុងសួង រួចបន្តប្រហែល៣០គីឡូម៉ែត្រទៀតដល់រង្វង់មូលរូបហ្លួងព្រះស្តេចកន ហើយបត់ឆ្វេងដៃប្រមាណ២គីឡូម៉ែត្រនឹងដល់បុរីរដ្ឋបាលនៃខេត្តត្បូងឃ្មុំ។ ទីពីរ តាមផ្លូវជាតិលេខ៦ ឆ្លងស្ពានមិត្តភាពកម្ពុជា-ចិន(ស្ពានព្រែកតាមាក់)រួចបន្តដំណើរតាមផ្លូវជាតិលេខ៨ កាត់រង្វង់មូលស្វាយអន្ទរ(ខេត្តព្រៃវែង) និងឃុំអន្លង់ជ្រៃ ហើយបន្តទៅមុខរហូតដល់ផ្លូវជាតិលេខ៧ត្រង់ទីប្រជុំជនស្រុកពញាក្រែក រួចបត់ឆ្វេងឆ្ពោះទៅមុខរហូតផ្លូវបំបែកព្រះធាតុ ទើបបត់ស្តាំបន្តដំណើរតាមផ្លូវជាតិលេខ៧៨ចម្ងាយប្រមាណ៥គីឡូម៉ែត្រទៀត ក៏នឹងទៅដល់បុរីរដ្ឋបាលខេត្តត្បូងឃ្មុំដូចគ្នា។(រូបលេខ១៖ ផែនទីបង្ហាញទីតាំងបុរីរដ្ឋបាលខេត្ត)។

ផ្ទៃដីសម្រាប់សង់ទីរួមខេត្តត្រូវបានកំណត់ជាពីរតំបន់ធំៗគឺ៖ តំបន់ទីរួមខេត្តត្បូងឃ្មុំ និងតំបន់រដ្ឋបាលប្រមូលផ្តុំ។

ក. តំបន់ទីរួមខេត្តរួមមាន៖ តំបន់រដ្ឋបាលប្រមូលផ្តុំ, តំបន់ពាណិជ្ជកម្ម, តំបន់ឧស្សាហកម្ម, តំបន់ទេសចរណ៍, តំបន់លំនៅដ្ឋាន, តំបន់រមណីយដ្ឋានបៃតង និងសណ្ឋាគារ, ទីតាំងចំណតរថយន្តក្រុង

និងតាក់ស៊ី, ទីតាំងយានដ្ឋានជួសជុលយានយន្ត, ទីតាំងកោជនីយដ្ឋានដែលមានសំឡេងរំខានពេលយប់, ទីតាំងសារមន្ទីរវប្បធម៌, ទីតាំងអាងស្តុកកាកសំណល់រាវ, ទីតាំងចាក់(កប់)កាកសំណល់រឹង និងទីតាំងអនុញ្ញាតឲ្យមានការអភិវឌ្ឍកសិកម្ម។

ខ. **តំបន់រដ្ឋបាលប្រមូលផ្តុំរបស់ខេត្តមាន៖** ទីតាំងសាងសង់សាលាខេត្ត្ស្ងងយ្ងុ, ទីតាំងមន្ទីរក្រោមឱ្យ៉ាទខេត្តទាំង២៥មន្ទីរ, ទីតាំងលំនៅដ្ឋានរបស់រដ្ឋសម្រាប់ថ្នាក់ដឹកនាំខេត្តក្នុងអាណត្តិការងារ, ទីតាំងផ្សារសម្រាប់បម្រើក្នុងតំបន់រដ្ឋបាលប្រមូលផ្តុំ, ទីតាំងសាលារៀន, ទីតាំងសាកលវិទ្យាល័យ និងសាលាបណ្តុះបណ្តាល និងបំប៉ន់ជំនាញ, ទីតាំងពហុកីឡាដ្ឋាន, ទីតាំងលំហរសាធារណៈសម្រាប់ការប្រារព្ធពិធីផ្សេងៗ, តំបន់សួនធម្មជាតិរុក្ខជាតិចម្រុះ, តំបន់សួនដាំថ្មី, ទីតាំងស្តុកកាកសំណល់រឹង និងស្ថានីយ៍វិទ្យុ និងទូរទស្សន៍។

២. ២. និម្មិតសញ្ញាខេត្ត

និមិត្តសញ្ញាខេត្តត្បូងឃ្មុំ គឺជាការច្របាច់បញ្ចូលគ្នានូវកត្តាសំខាន់៤គឺ៖

១. ភូមិសាស្ត្រ

២. បរិស្ថាន និងធម្មជាតិ

៣. ប្រវត្តិសាស្ត្រ

៤. រឿងព្រេងនិទាន

ការជ្រើសរើសយកកត្តាទាំង៤ខាងលើមកផ្សំបញ្ចូលគ្នាប្រសូត្រចេញជានិមិត្តសញ្ញាបែបនេះ គឺចង់រំលេចឲ្យឃើញពីសក្តានុពលរបស់ខេត្ត និងឆ្លុះបញ្ចាំងពីអត្តសញ្ញាណរបស់ខេត្តនេះតាមរយៈមរតកវប្បធម៌ប្រវត្តិសាស្ត្រនិងធនធានធម្មជាតិដែលមាននៅលើទឹកដីនៃខេត្តត្បូងឃ្មុំនាពេលសព្វថ្ងៃ ។

ទម្រង់ទូទៅនៃនិមិត្តសញ្ញា

និមិត្តសញ្ញានេះរាងមូលព័ទ្ធដោយខ្សែពណ៌ត្នោតពីរជាន់ ខាងក្រៅធំ, ខាងក្នុងតូច និងខណ្ឌដោយផ្ទៃពណ៌ស។ ផ្ទៃខាងក្នុងពណ៌ត្នោតស្រាលខណ្ឌដោយខ្សែពណ៌សរាងឆកោនតំណាងឲ្យសម្បុកឃ្មុំ។ នៅចំកណ្តាលមានរូបជើងពានពណ៌ត្នោត។ ចំណែកផ្នែកខាងលើមានរំលេចអក្សរពណ៌ខៀវថា"ខេត្តត្បូងឃ្មុំ"។ ចំណែកនៅខាងក្រោមជើងពានមានលម្អដោយចង្វាយក្បាច់អង្គរ ដែលមានផ្ទៃក្បាច់ពណ៌បៃតងរំលេចដោយទម្រង់ក្បាច់ពណ៌ស។

អត្ថន័យនៃនិមិត្តសញ្ញា

រង្វង់ព័ទ្ធជុំវិញ

រង្វង់ខ្សែពីរជាន់ព័ទ្ធជុំវិញតំណាងឲ្យស្ថានីយបុរេប្រវត្តិសាស្ត្រ"**បន្ទាយគូឬភូមិមូល**"។ ខ្សែខាងក្រៅធំតំណាងឲ្យកំពែងដីខាងក្រៅ ឯខ្សែតូចខាងក្នុងតំណាងដីទួលព័ទ្ធជុំវិញមាត់គូ ដែលអ្នកខ្លះហៅថាកំពែងខាងក្នុង។ ចំណែកខ្សែសខណ្ឌខ្សែពណ៌ត្នោតទាំងពីតំណាងឲ្យគូ។ តាមរយៈការស្រាវជ្រាវផ្នែកបុរាណវិទ្យាស្ថានីយ "បន្ទាយគូឬភូមិមូល" ជាកន្លែងមនុស្សរស់នៅតាំងពី១០០០ឆ្នាំមុនគ្រិស្តសករាជ។ បន្ទាយគូនេះគេបានរកឃើញភាគច្រើននៅក្នុងតំបន់ដីក្រហមក្នុងស្រុកមេមត់និងពញ្ញាក្រែកនៃខេត្តត្បូងឃ្មុំ ហើយមួយចំនួនទៀតរកឃើញនៅតំបន់ដីក្រហមក្នុងស្រុកស្ទ្រង ខេត្តក្រចេះ ព្រមទាំងនៅក្នុងតំបន់ដីក្រហមនៃប្រទេសវៀតណាមផងដែរ។ លោក ប៊ែណាហ្ស៊ីលីព ហ្ស្គ្រូសលីយេ អ្នកស្រាវជ្រាវជាតិបារាំង បានកំណត់ហៅឈ្មោះស្ថានីយនិងវត្ថុដែលរកឃើញនៅតាមតំបន់ខាងលើនេះថា "អារ្យធម៌មេមត់" ដែលជាអារ្យធម៌ចាស់ជាងគេនៅតំបន់ដីក្រហមនៅតំបន់អាស៊ីអាគ្នេយ៍។

ផ្ទៃខាងក្នុង

ផ្ទៃខាងក្នុងគឺតំណាងសំណុសឃ្ម៉ុ និងទឹកឃ្ម៉ុ។ វត្ថុដ៏មានតម្លៃរបស់ឃ្ម៉ុដែលអ្នកស្វែងឃ្ម៉ុប្រាថ្នាចង់បាននោះគឺ "ក្បាលទឹកឃ្ម៉ុ" ជាទីប្រមូលផ្តុំដោយទឹកឃ្ម៉ុមានរសផ្អែមឈ្ងុយឆ្ងាញ់ផង និងសម្រាប់ជាឱសថផ្សេងៗផង។ ប្រសិនយោងលើពាក្យ"កបាល" ឬ "ក្បាល[108]" ជាពាក្យសំស្ត្រឹតត្រូវគ្នានឹងពាក្យខ្មែរថា "ត្បូង" ។ ដូច្នេះ ពាក្យថា"ក្បាលទឹកឃ្ម៉ុ" ដែលយើងប្រើសព្វថ្ងៃនេះ គឺប្រហែលជាអ្នកស្រុកហៅខ្លីថា "ត្បូងឃ្ម៉ុ" ដូច្នេះក៏មិនដឹង។ ម្យ៉ាងទៀតឃ្ម៉ុស្ថិតក្នុងអម្ប្រសត្វល្អិតរស់នៅជាក្រុម ដែលមានការតស៊ូអត់ធ្មត់ និងឧស្សាហ៍ព្យាយាម មានសាមគ្គីគ្នាល្អ។ ហេតុនេះ ការយកឃ្ម៉ុមកដាក់នៅក្នុងនិមិត្តសញ្ញានេះក៏ចង់បង្ហាញពីនិមិត្តរូបនៃការតស៊ូនិងរួបរួមសាមគ្គីគ្នាជាធ្លុងមួយ។ ចំណែកទឹកឃ្ម៉ុជានិមិត្តរូបនៃការរស់នៅដ៏ផ្អែមល្ហែមក្នុងសហគមន៍ក៏ដូចសង្គមជាតិទាំងមូល។

រូបជើងពាននៅកណ្តាល

រូបសំខាន់បំផុតនៅចំកណ្តាល ដែលជ្រើសរើសធ្វើជានិមិត្តសញ្ញារបស់ខេត្តត្បូងឃ្ម៉ុនោះ គឺ"ជើងពានបុរាណ" ធ្វើពីដីដុត(កុលាលភាជន៍) ដែលរកឃើញពេលធ្វើកំណាយស្រាវជ្រាវនៅស្ថានីយបន្ទាយគូ ស្ថិតក្នុងក្រុមហ៊ុនចម្ការកៅស៊ូក្រែក កាលពីឆ្នាំ១៩៩៨។ បើសង្កេតទៅលើរូបរាងជើងពាននេះ គឺមានសណ្ឋានដូចជាជើងពានប្រដាប់ប្រើប្រាស់សព្វថ្ងៃនេះដែរ។ ផ្អែកលើលទ្ធផលសិក្សាវិភាគកំណត់អាយុកាលលើបុរាណវត្ថុជាច្រើន ដែលស្ថិតក្នុងជម្រៅដីជាមួយគ្នា ជើងពាននេះមានអាយុ ជាង៣០០០ឆ្នាំ។ ជើងពានជាប្រដាប់សម្រាប់ដាក់ទ្រវត្ថុមានតម្លៃ, គម្ពីរក្ឆ្ជនច្បាប់ផ្សេងៗ, គ្រឿងសក្តារៈបូជាសម្រាប់ថ្វាយព្រះ ឬវត្ថុខ្ពង់ខ្ពស់សម្រាប់ព្រះរាជាជាដើម។ ម្ល៉ោះហើយ ជើងពានជានិមិត្តរូបនៃចំណេះដឹង, ភាពខ្ពង់ខ្ពស់ និងភាពពិសិដ្ឋ។

អក្សរពណ៌ខៀវ «ខេត្តត្បូងឃ្ម៉ុ»

ជាប្រភេទអក្សរមូល ដែលវិវត្តន៍មកពីអក្សរខ្មែរសម័យអង្គរ។ ចាប់ពីសម័យក្រោយអង្គរ(ស.វ.១៤/១៥)មក គេច្រើនប្រើអក្សរមូលនេះដើម្បីចារលើសាស្ត្រា ឬក្រាំងផ្សេងៗ។ អក្សរនេះនៅតែមានប្រជាប្រិយភាពរហូតមកទល់នឹងសព្វថ្ងៃ។

---

[108] ដូចជ្រាបស្រាប់ហើយថា កាលពីបុរាណពាក្យសំស្ត្រឹត គឺប្រើប្រាស់តែនៅក្នុងព្រះរាជវាំង ឬនៅក្នុងស្រទាប់អភិជនប៉ុណ្ណោះ ហើយបន្តិចម្តងៗទើបជ្រួតជ្រាបទៅក្នុងស្រទាប់ប្រជារាស្ត្រ។ ម្ល៉ោះហើយ នៅពេលដែលឈ្មោះ "ត្បូងឃ្ម៉ុ" កើត ប្រហែលជាអ្នកស្រុកនៅទីនោះពុំទាន់ស្គាល់ពាក្យ "ក្បាល" ជាភាសាសំស្ត្រឹតនេះនៅឡើយទេ។

ចង្វាយក្បាច់អង្គរ

ចង្វាយក្បាច់នៅពីក្រោមជើងពាន គឺជាក្បាច់មួយប្រភេទហៅថា "ក្បាច់អង្គរ"។ ក្បាច់នេះឃើញបុព្វបុរសខ្មែរនិយមឆ្លាក់តុបតែងលម្អនៅតាមប្រាង្គប្រាសាទ និងទីសក្តារៈនានា ហើយបន្តឥតដាច់តាំងពីសម័យបុរាណរហូតមកទល់សព្វថ្ងៃ។ ក្បាច់លម្អទាំងឡាយគឺច្នៃប្រឌិតចេញពីធម្មជាតិ ជាពិសេសរុក្ខជាតិ មានដើម, ទង, ស្លឹក, ផ្លែ, ផ្កាជាដើម។ ម្ល៉ោះហើយ ក្បាច់មិនមែនគ្រាន់តែជាគ្រឿងសម្រាប់តុបតែងលម្អប៉ុណ្ណោះទេ តែក៏បង្ហាញឲ្យឃើញពីការចម្រើនលូតលាស់ភោគផល ធនធានធម្មជាតិ និងភាពសម្បូណ៌សប្បាយនៅក្នុងសង្គមដែរ។ ហេតុដូច្នេះហើយ ចង្វាយក្បាច់ អង្គរដែលលើកយកលម្អនៅក្នុងនិមិត្តសញ្ញានេះជានិមិត្តរូបនៃស្ពានតភ្ជាប់រវាងអារ្យធម៌រុងរឿងពីអតីតកាលមកបច្ចុប្បន្នកាលផង និងជាសញ្ញាណនៃកសិ-ឧស្សាហកម្មមានដូចជាកៅស៊ូ ដំឡូងមី ស្វាយចាន់ទី និងម្រេចជាដើម ដែលជាសក្តានុពលសេដ្ឋកិច្ចរបស់ខេត្តតែម្តង។

ពណ៌

រង្វង់មូលពីរជាន់ព័ទ្ធជុំវិញផ្នែកខាងក្រៅនៃនិមិត្តសញ្ញានេះ មានពណ៌ត្នោតគឺតំណាងឲ្យតំបន់ដីក្រហមរបស់ខេត្តត្បូងឃ្មុំ។ ផ្ទៃរបស់និមិត្តសញ្ញារាង៦ជ្រុងតូច គឺចម្លងចេញពីសំណុសឃ្មុំ។ ជើងពាននៅកណ្តាលរំលេចដោយពណ៌ដី គឺតំណាងឲ្យដីក្រហមនៃខេត្តត្បូងឃ្មុំផង និងពណ៌ដើមរបស់ភាជន៍។ រីឯអក្សរ "ខេត្តត្បូងឃ្មុំ" មានផ្ទៃពណ៌ខៀវ គឺតំណាងឲ្យសេរីភាពផង និងតំណាងឲ្យអាកាសធាតុមូសុងផង។ ចំណែក ចង្វាយក្បាច់អង្គរពណ៌បៃតង គឺតំណាងឲ្យសក្តានុពលនៃដំណាំកសិ-ឧស្សាហ៍កម្មរបស់ខេត្ត មានដូចជាម្រេច ពិសេសដំណាំកៅស៊ូ ដែលគេបានចាត់ទុកជា "មាសសលើដីក្រហម"។